ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត




- ការិយាល័យទីប្រឹក្សាពិសេសទប់ស្កាត់អំពើប្រល័យពូជសាសន៍នៃអង្គការសហប្រជាជាតិ និងមជ្ឈមណ្ឌលឯកសារកម្ពុជាចុះហត្ថលេខាលើអនុស្សរណៈនៃកិច្ចសហការ រំលេចអំពីសារសំខាន់នៃកិច្ចសហប្រតិបត្តិការ ក្នុងការលើកកម្ពស់ការអនុវត្តកិច្ចខិតខំប្រឹងប្រែងនានាក្នុងការទប់ស្កាត់ និងការអប់រំពីអំពើប្រល័យពូជសាសន៍នៅក្នុងតំបន់អាស៊ីអាគ្នេយ៍, អាស៊ីខាងត្បូង និងទូទាំងសកលលោក

# ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

## មាតិកា


### សំបុត្រ
◆ ការិយាល័យទីប្រឹក្សាពិសេសទប់ស្កាត់អំពើប្រល័យពូជសាសន៍.............................. ១

### ផ្នែកឯកសារ
◆ រស់ យ៉ែន ហៅ យ៉េន អតីតអ្នកធ្វើការឱ្យស្ថានទូតឡាវ.....................................៤

### ផ្នែកប្រវត្តិសាស្ត្រ និងការស្រាវជ្រាវ
◆ គរុសិស្សភូមិភាគខេត្តព្រៃវែងសិក្សាឈ្វេងយល់អំពីប្រវត្តិសាស្ត្រកម្ពុជា ............ ៨
◆ សំរិទ្ធិ ថា ៖ ខ្មែរក្រហមចាប់ខ្ញុំធ្វើទាហាន ...... ១១
◆ កិច្ចពិភាក្សា អំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ..... ១២
◆ មាស អឿន ៖ ខ្ញុំធ្វើស្រែទឹកស៊ីជើងឡើងរលួយ ខ្មែរក្រហមមិនឱ្យខ្ញុំសម្រាក ....................១៤
◆ មុត សុភា ៖ ខ្មែរក្រហមចាប់បងថ្លៃខ្ញុំយកទៅសម្លាប់ ..................................១៦
◆ ព្រះរាជបណ្ណាល័យ ហ្វូងម៉ែ ចូលរួមតាំងពិព័រណ៍ផលិតផលសូត្រចាម......................... ១៨
◆ អតីតនារីពេទ្យប្រចាំតំបន់ក្រចេះ (៥០៥) .. ២១
◆ មជ្ឈមណ្ឌលឯកសារកម្ពុជាចូលរួមដាក់តាំងរុក្ខជាតិលម្អ ......................... ២៤
◆ ស្នង នឿន ៖ ខ្មែរសុរិនជម្លៀស ...............២៧
◆ លោកជំទាវ ហ្វ៊ូរីដា អាន កាមីឡេ ភីម៉ៃយ៉ូ ឯកអគ្គរដ្ឋទូតហ្វីលីពីន ប្រចាំនៅកម្ពុជា.......៣១
◆ អតីតអ្នកបើកឡានតាម៉ុក..................... ៣៤
◆ ខ្ញុំត្រូវខ្មែរក្រហមបង្ខំឱ្យហូបសាច់មនុស្ស .... ៣៨

### ផ្នែកវេទិកាពិភាក្សាសាធារណៈ
◆ ឆាយ ធឿន ៖ ធ្វើការនៅរោងចក្រផលិតរំសេវក្នុងរបបខ្មែរក្រហម .....................៤១
◆ អ៊ុក សៀត ៖ រត់គៀសខ្លួនទៅនៅជំរុំក្នុងខេត្តតាយនីញ ប្រទេសវៀតណាម ............ ៤៤





លោកស្រី អាលីស វ៉ៃរីមូ ង៉េរីទូ អគ្គលេខាធិការរងអង្គការសហប្រជាជាតិ និងជាទីប្រឹក្សាពិសេសទទួលបន្ទុកការទប់ស្កាត់អំពើប្រល័យពូជសាសន៍ ថ្លែងសុន្ទរកថា នៅក្នុងពិធីចុះហត្ថលេខា រវាងអង្គការសហប្រជាជាតិ និងមជ្ឈមណ្ឌលឯកសារកម្ពុជា លើអនុស្សរណៈនៃកិច្ចសហការ រំលេចអំពីសារសំខាន់នៃកិច្ចសហប្រតិបត្តិការ ក្នុងការលើកកម្ពស់ការអនុវត្តកិច្ចខិតខំប្រឹងប្រែងនានាក្នុងការទប់ស្កាត់ និងការអប់រំពីអំពើប្រល័យពូជសាសន៍នៅក្នុងតំបន់អាស៊ីអាគ្នេយ៍ អាស៊ីខាងត្បូង និងទូទាំងសកលលោក នៅទីក្រុងគីហ្គាលី ប្រទេសរ៉ាន់ដា ថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០២៤។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)


◆ គ្រូបង្រៀនកុមារនៅក្នុងរបបខ្មែរក្រហម..... ៤៨
◆ ការពិភាក្សាពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)............................៥១

### ផ្នែកស្រាវជ្រាវរកក្រួសារ
◆ ហ៊ីប សារីម ៖ ប្ដីខ្ញុំត្រូវអង្គការចោទថាក្បត់ និងយកទៅសម្លាប់ .................. ៥៧



**រក្សាសិទ្ធិ**
មជ្ឈមណ្ឌលឯកសារកម្ពុជា


អនុញ្ញាតឱ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ៣៧៥៣.មប្រក
ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៨
រូបថតឯកសារ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា

**ស្មេរលេខនេះ ៖** សូ ហ្វារីណា, ជុន ស្រីពេជ្រ, ទូច ស្រីទីន, ដេង ពង្សរ៉ាស៊ី, យន់ ឃីម, អ៊ី រក្សា, ដារ៉ារដ្ឋ មេត្តា, ឡាំ ស្រីនីត, ស្រេង លីដា, រស់ សំពៅ, ចាន់ ណារិទ្ធ និង ម៉ាប់ ស៊ីណា
**អ្នកនិពន្ធ និងស្រាវជ្រាវ៖** មីន សាណាស់ **អ្នកបកប្រែ៖** លឹម អ៊ីភីង និង ជ័យ ចាន់ស៊ីណែត **និពន្ធនាយកទូទៅ៖** សោម ប៊ុនថន
**ជំនួយការនិពន្ធនាយក៖** ដារ៉ារដ្ឋ មេត្តា **ក្រាហ្វិកកុំព្យូទ័រ៖** លី សេនសុនីឡា **គ្រប់គ្រងការចែកផ្សាយ៖** ផេង ពង្ស
Email: dccam@online.com.kh, Homepage: www.dccam.org, www.cambodiasri.org

# ការិយាល័យទីប្រឹក្សាពិសេសទប់ស្កាត់អំពើប្រល័យពូជសាសន៍នៃអង្គការសហប្រជាជាតិ

## និងមជ្ឈមណ្ឌលឯកសារកម្ពុជាចុះហត្ថលេខាលើអនុស្សរណៈនៃកិច្ចសហការ រំលេចអំពីសារសំខាន់នៃកិច្ចសហប្រតិបត្តិការ ក្នុងការលើកកម្ពស់ការអនុវត្តកិច្ចខិតខំប្រឹងប្រែងនានាក្នុងការទប់ស្កាត់ និងការអប់រំពីអំពើប្រល័យពូជសាសន៍នៅក្នុងតំបន់អាស៊ីអាគ្នេយ៍, អាស៊ីខាងត្បូង និងទូទាំងសកលលោក

*សូ ហ្វារីណា*




*លោកស្រី អាលីស វ៉ៃរីម៉ូ ឌីរីទូ អគ្គលេខាធិការរងអង្គការសហប្រជាជាតិ និងជាទីប្រឹក្សាពិសេស ទទួលបន្ទុកការទប់ស្កាត់អំពើប្រល័យពូជសាសន៍ និងលោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា ចុះហត្ថលេខាលើអនុស្សរណៈនៃកិច្ចសហការ រំលេចអំពីសារសំខាន់នៃកិច្ចសហប្រតិបត្តិការ ក្នុងការលើកកម្ពស់ការអនុវត្តកិច្ចខិតខំប្រឹងប្រែងនានាក្នុងការទប់ស្កាត់ និងការអប់រំពីអំពើប្រល័យពូជសាសន៍នៅក្នុងតំបន់អាស៊ីអាគ្នេយ៍, អាស៊ីខាងត្បូង និងទូទាំងសកលលោក នៅទីក្រុងគីហ្គាលី ប្រទេសរ៉្វាន់ដា ថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០២៤។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

(ថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០២៤, ទីក្រុងគីហ្កាលី) ការលើកកម្ពស់ការយល់ដឹងអំពីបុសគល់ និងកម្លាំងជំរុញឱ្យកើតមាននូវអំពើប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មអន្តរជាតិធ្ងន់ធ្ងរនានា (ដូចជា ឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិជាដើម), ការក្រើនរំឭកដល់តួអង្គពាក់ព័ន្ធអំពីហានិភ័យនៃឧក្រិដ្ឋកម្មប្រភេទនេះនៅទីតាំងណាមួយ និងការគាំទ្រក៏ដូចជាដាក់ចេញជាសកម្មភាពសមស្រប តាមរយៈបែបផែននៃអង្គការសហប្រជាជាតិ គឺជាឧបករណ៍ដ៏ចាំបាច់ប្រកបដោយប្រសិទ្ធភាព ឈានទៅសម្រេចបានការទប់ស្កាត់អំពើប្រល័យពូជសាសន៍, ឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក៏ដូចជាដើមចមនៃឧក្រិដ្ឋកម្មទាំងនេះថែមទៀតផងៗ

ដើម្បីពង្រឹងកិច្ចខិតខំប្រឹងប្រែងបម្រើដល់បុព្វហេតុខាងលើ ការិយាល័យទីប្រឹក្សាពិសេសទប់ស្កាត់អំពើប្រល័យពូជសាសន៍នៃអង្គការសហប្រជាជាតិ និងមជ្ឈមណ្ឌលឯកសារកម្ពុជា បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងដ៏សំខាន់មួយ ក្នុងគោលបំណងរឹតបន្តឹងកិច្ចសហប្រតិបត្តិការរបស់ខ្លួនលើការទប់ស្កាត់អំពើប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មអន្តរជាតិធ្ងន់ធ្ងរនៅទូទាំងពិភពលោកៗ



មេដឹកនាំស្ត្រីមកពីស្ថាប័ន អង្គការ និងសមាគម ចូលរួមវេទិកាសហគមន៍ស្ត្រី នៅទីក្រុងគីហ្កាលី ប្រទេសរ៉្វាន់ដា នៅថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០២៤ ថតរូបជុំគ្នាជាមួយលោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជាៗ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)




លោក ឆាំង យុ មជ្ឈមណ្ឌលឯកសារកម្ពុជា ថ្លែងនៅក្នុងពិធីចុះហត្ថលេខា រវាងមជ្ឈមណ្ឌលឯកសារកម្ពុជា និងអង្គការសហប្រជាជាតិ លើអនុស្សារណៈនៃកិច្ចសហការរំលេចអំពីសារសំខាន់នៃកិច្ចសហប្រតិបត្តិការ ក្នុងការលើកកម្ពស់ការអនុវត្តកិច្ចខិតខំប្រឹងប្រែងនានាក្នុងការទប់ស្កាត់ និងការអប់រំពីអំពើប្រល័យពូជសាសន៍នៅក្នុងតំបន់អាស៊ីអាគ្នេយ៍, អាស៊ីខាងត្បូង និងទូទាំងសកលលោក នៅទីក្រុងគីហ្កាលី ប្រទេសរ៉្វាន់ដា ថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០២៤ៗ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

កិច្ចសហការនេះ បង្ហាញអំពីការឆ្ពោះទៅមុខមួយកម្រិតទៀតនៃកិច្ចខិតខំប្រឹងប្រែងជាសកល ក្នុងការដោះស្រាយ និងរារាំងការញុះញង់បង្កប់នូវចេតនាស្អប់ខ្ពើមៗ កិច្ចខិតខំប្រឹងប្រែងនេះ គឺពិតជាមានសារសំខាន់ក្នុងការបញ្ចៀសហានិភ័យ និងនៅចុងបញ្ចប់ទប់ស្កាត់វត្តមាននៃឧក្រិដ្ឋកម្មប្រភេទនេះៗ

"កិច្ចសហការនេះ សបញ្ជាក់អំពីជំហានដ៏ចាំបាច់មួយនៃកិច្ចខិតខំប្រឹងប្រែងបន្តបន្ទាប់របស់យើងក្នុងការទប់ស្កាត់អំពើប្រល័យពូជសាសន៍, ឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ" ដែលអគ្គលេខាធិការង នៃការិយាល័យទីប្រឹក្សាពិសេសទប់ស្កាត់អំពើប្រល័យពូជសាសន៍នៃអង្គការសហប្រជាជាតិ លោកស្រី អាលីស វ៉ៃរីមូ ឌីរីទូ បានលើកឡើង "តាមរយៈការប្រុងប្រាច់បញ្ចូលគ្នាជាធ្លុងមួយរវាងវិសាលភាពនៅទូទាំងសកលលោករបស់អង្គការសហប្រជាជាតិ និងជំនាញជាន់ខ្ពស់ព្រមទាំងចំណេះដឹងក្នុងតំបន់របស់មជ្ឈមណ្ឌលឯកសារកម្ពុជា យើងអាចពង្រឹងសមត្ថភាពរបស់

ខ្លួនក្នុងការកំណត់ និងឆ្លើយតបចំពោះសញ្ញាអាសន្ននៃអំពើប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មអន្តរជាតិធ្ងន់ធ្ងរនានា បានឆាប់រហ័សបំផុត ក៏ដូចជារៀបចំ និងអនុវត្តសកម្មភាពទប់ស្កាត់ប្រកបដោយប្រសិទ្ធភាព និងនិរន្តរភាព"។

កិច្ចព្រមព្រៀងនេះ បានគូសបញ្ជាក់អំពីសារសំខាន់ក្នុងការអភិរក្ស និងថែរក្សាកំណត់ត្រាប្រវត្តិសាស្រ្តស្តីពីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅក្នុងរបបខ្មែរក្រហម (១៩៧៥-១៩៧៩) ដោយប្រើប្រាស់ព្រឹត្តិការណ៍នេះ ជាមេរៀនក្នុងការពង្រឹងកិច្ចខិតខំប្រឹងប្រែងទប់ស្កាត់វត្តមាននៃឧក្រិដ្ឋកម្មប្រភេទនេះ នៅក្នុងតំបន់អាស៊ីអាគ្នេយ៍ និងតំបន់ដទៃទៀត។ "ការយល់ដឹងអំពីអតីតកាល គឺពិតជាចាំបាច់ណាស់សម្រាប់ការទប់ស្កាត់អំពើឃោរឃៅនាថ្ងៃអនាគត" ដែលលោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា បានលើកឡើង។ មជ្ឈមណ្ឌលឯកសារកម្ពុជា គឺជាស្ថាប័នមិនមែនរដ្ឋាភិបាល, មិនលម្អៀង និងឯករាជ្យមួយ ដែលមានទីស្នាក់ការនៅក្នុងប្រទេសកម្ពុជា។ "កិច្ចសហប្រតិបត្តិការនេះ គាំទ្រចំពោះកិច្ចខិតខំប្រឹងប្រែងរបស់យើង ក្នុងការធានាតាមរយៈពាក្យស្លោកថា "លែងកើតមានទៀត" គឺមិនមែនត្រឹមតែជាការនិយាយឱ្យពិរោះពិសាប៉ុណ្ណោះទេ ក៏ប៉ុន្តែគឺជាកិច្ចប្តេជ្ញាចិត្តក្នុងការផ្លាស់ប្តូរ និងជួយសង្គ្រោះជីវិតរបស់មនុស្សជាតិទាំងនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ និងនៅទូទាំងសកលលោក"។

កិច្ចសហប្រតិបត្តិការរវាងស្ថាប័នទាំងពីរចាប់ផ្តើមតាំងពីឆ្នាំ២០២០ ហើយនៅក្នុងរយៈពេលប្រមាណបួនឆ្នាំកន្លងមកនេះ ការិយាល័យទីប្រឹក្សាពិសេសទប់ស្កាត់អំពើប្រល័យពូជសាសន៍ និងមជ្ឈមណ្ឌលឯកសារកម្ពុជា បានបង្កើតជាកម្មវិធីអប់រំពិស្តារស្តីពីការទប់ស្កាត់អំពើប្រល័យពូជសាសន៍ដែលមានគោលបំណងទប់ស្កាត់អំពើប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មអន្តរជាតិធ្ងន់ធ្ងរនានានៅក្នុងតំបន់អាស៊ីអាគ្នេយ៍។ កម្មវិធីសិក្សានេះ ត្រូវបានអនុវត្តសាកល្បងជាមួយនឹងគ្រូបង្រៀនមកពីប្រទេសកម្ពុជា, ប្រទេសវៀតណាម និងប្រទេសថៃ។

អនុស្សរណៈនៃកិច្ចសហការដែលត្រូវបានចុះហត្ថលេខាដោយមជ្ឈមណ្ឌលឯកសារកម្ពុជា និងការិយាល័យទីប្រឹក្សាពិសេសទប់ស្កាត់អំពើប្រល័យពូជសាសន៍នេះ នឹងរឹតបន្តឹងកិច្ចសហការគ្នា ឈានទៅសម្រេចបានការលើកកម្ពស់ការទប់ស្កាត់អំពើប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មអន្តរជាតិធ្ងន់ធ្ងរនានានៅទូទាំងសកលលោក។



មេដឹកនាំស្ត្រីមកពីស្ថាប័ន, អង្គការ និងសមាគម ចូលរួមវេទិកាសហគមន៍ស្ត្រី នៅទីក្រុងគីហ្គាលី ប្រទេសរ៉ាន់ដា នៅថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០២៤ ថតរូបជុំគ្នា។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# រស់ យ៉ែន ហៅ យ៉េន អតីតអ្នកធ្វើការឱ្យស្ថានទូតឡាវក្នុងសម័យ លន់ នល់ ប្រចាំនៅប្រទេសឡាវ

*មីន សាណាស់*



*ព្រះអង្គម្ចាស់ សុផានុវង្ស ប្រធានាធិបតីនៃសាធារណរដ្ឋប្រជាមានិត ឡាវ (រូបខាងស្តាំ) អមដំណើរដោយ ខៀវ សំផន គណៈប្រធានរដ្ឋនៃរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) នៅព្រលានយន្តហោះពោធិ៍ចិនតុង នៅខែធ្នូ ឆ្នាំ១៩៧៧។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

*នៅក្នុងកំណត់ហេតុចម្លើយសារភាពលេខ J00៤៣៣ គឺឃើញមានចំណារទឹកប៊ិចពណ៌ក្រហមជារបាយការណ៍របស់អតីតប្រធានមន្ទីរ ស-២១ ឈ្មោះ ឌុច (សម្គាល់ដោយហត្ថលេខា) ជូនថ្នាក់លើអំពីករណីឈ្មោះ រស់ យ៉ែន ហៅ យ៉េន អតីតធ្វើការនៅទូតប្រចាំប្រទេស ឡាវ ក្នុងរបបសាធារណរដ្ឋខ្មែរ លន់ នល់។ រស់ យ៉ែន ហៅ យ៉េន និងគ្រួសារបានជិះយន្តហោះចេញពីប្រទេស ឡាវក្នុងគោលបំណងត្រឡប់ចូលមកប្រទេសខ្មែរវិញតាមច្រកក្រុងប៉ាក់សេ និងបន្តដំណើរមកកាន់ខេត្តស្ទឹងត្រែង។ តែដោយសារប្រទេសស្ថិតក្នុងសភាពអសន្តិសុខ មានគ្រាប់ផ្លោងតាមព្រំដែន យន្តហោះមិនអាចធ្វើការចុះចតបាន ក៏ហោះសំដៅមកដល់ក្រុងភ្នំពេញនៅម៉ោង១១ថ្ងៃត្រង់ដល់ម៉ោង២រសៀល ក៏ត្រូវអង្គការចាប់ខ្លួននៅថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៨។ ខាងក្រោមនេះជាកំណត់ហេតុចម្លើយសារភាពរបស់ រស់ យ៉ែន ហៅ យ៉េនបន្ទាប់ពីអង្គការចាប់ខ្លួន៖*

រស់ យ៉េន ហៅ យ៉េន ភេទប្រុស អាយុ៣៣ឆ្នាំ (១៩៧៨) ជាជនជាតិខ្មែរ កើតនៅភូមិខ្ទោ ឃុំរមាំងថ្កោល ស្រុករំដួល ខេត្តស្វាយរៀង។ កាលពីតូច យ៉េនរស់នៅធ្វើស្រែជាមួយឪពុកម្តាយ ដល់មានអាយុ៩ឆ្នាំ ទើបឪពុកម្តាយ បញ្ជូនចូលរៀននៅសាលាខ្លាយ ស្ថិតក្នុងឃុំរមាំងថ្កោល។ អាយុ១២ឆ្នាំ យ៉េនបានឈប់រៀនត្រឹមថ្នាក់ទី១០ រួច ត្រឡប់មកនៅភូមិកំណើត និងធ្វើស្រែជាមួយឪពុកម្តាយវិញ។ ដល់ឆ្នាំ១៩៦២ យ៉េនមានអាយុ១៧ឆ្នាំ ក៏ចេញទៅរកស៊ីរត់ពន្ធ លក់មាន់ និងស្បែកជើង នៅតាមច្រកព្រំដែនវៀតណាមកម្ពុជា ដោយមានការអនុញ្ញាតពីឈ្មោះ សូ ខ្មៅ មានតួនាទីជាមេឃុំរមាំងថ្កោល។ យ៉េនស្គាល់ សូ ខ្មៅ តាមរយៈបងប្រុសជីដូនមួយឈ្មោះ ឃ្លាំង ថូ មានតួនាទីជាមេភូមិខ្ទោ។ ឆ្នាំ១៩៦៣-១៩៦៤ យ៉េនចាប់ផ្តើមធ្វើគិញឱ្យមេឃុំ សូ ខ្មៅ តាមរយៈឈ្មោះ មាស ស៊ុត។ មាស ស៊ុតជាមិត្តភក្តិរបស់យ៉េនតាំងពីនៅរៀន ព្រមទាំងទាក់ទងខ្សែរយៈគិញឈ្មោះ ឡឹក អុន ជាប្រជាជនរស់នៅភូមិខ្លាយ ឃុំរមាំងថ្កោល បច្ចុប្បន្នក្តាប់មិនបាន និង អាំ សេង ជាប្រជាជនរស់នៅភូមិទន់លាង ឃុំរមាំងថ្កោល បច្ចុប្បន្នក្តាប់មិនបាន។ សកម្មភាពដែល សូ ខ្មៅ ប្រគល់ឱ្យ យ៉េន ធ្វើគឺ ចុះស៊ើបយកព័ត៌មានចលនារបស់ខ្មែរក្រហមនៅឃុំគគីរសោម ស្រុករំដួល និង ឃោសនាបាចខិតប័ណ្ណ បំផុសប្រជាជនក្នុងឃុំរមាំងថ្កោល ឱ្យប្រឆាំងខ្មែរក្រហម រួចរាយការណ៍ឱ្យមេឃុំ សូ ខ្មៅ។ ឆ្នាំ១៩៦៤-១៩៦៨ យ៉េនដាច់ខ្សែរយៈគិញពីមេឃុំ សូ ខ្មៅ ព្រោះត្រូវចូលបួសនៅវត្តខ្លាយ តាមការស្នើសុំពីឪពុកម្តាយ។ ក្រោយសឹកពីបួស យ៉េន មកធ្វើស្រែជាមួយឪពុកម្តាយ និងធ្វើជាគិញឱ្យ សូ ខ្មៅ តាមដានសកម្មភាពខ្មែរក្រហមក្នុងឃុំស្វាយរំពា ឃុំរមាំងថ្កោល។

ក្រោយមកចៅហ្វាយស្រុករំដួលឈ្មោះ ប៊ុនថេង បានប្រកាសឱ្យតាមបណ្តាឃុំជ្រើសរើសកម្លាំងយកទៅធ្វើទាហានរយៈពេល១៨ខែ នៅចំណុចផ្សារកំពង់ចក ខេត្តស្វាយរៀង។ សូ ខ្មៅ ក៏ចាត់តាំង យ៉េន ឱ្យទៅធ្វើជាទាហាន ដែលមានឈ្មោះ អ៊ឹម ឈូដេត សក្តិ៤ ជាមេបញ្ជាការនៅកំពង់ចក។ នៅកំពង់ចកបានមួយរយៈ យ៉េនក៏ត្រូវផ្លាស់មកបន្ទាយស៊ុប ដែលមានឈ្មោះ ស ចាន់ ជាសក្តិ៤ ជាអ្នកគ្រប់គ្រង។

ឆ្នាំ១៩៦៩ ស ចាន់ បានបញ្ចូល យ៉េន ជាសេ-អ៊ី-អា នៅខេត្តស្វាយរៀង រួចអប់រំថា សេ-អ៊ី-អា គឺជាអ្នកស្នេហាជាតិ ស្នេហាទឹកដី វាយយៀកកុង និងវាយខ្មែរក្រហមឱ្យអស់ពីទឹកដីខ្មែរ នឹងតទៅមុខទៀតក្រុម សេ-អ៊ី-អា មានលុយកាក់បុណ្យសក្តិធំជាងនេះទៅទៀត។ ឈ្មោះអ្នកដែលបានចូលជា សេ-អ៊ី-អា ជាមួយ យ៉េន មានដូចជា សិតធី ជាទាហានពាក់ដោយ៣ជាន់ បច្ចុប្បន្នក្តាប់មិនបាន, យ៉េន ជាទាហានពលទោ បច្ចុប្បន្នក្តាប់មិនបាន, ទិត ក្តាប់តួនាទីមិនបាន, ណាគ្រី ទាហានកាប៉ូរ៉ាល់សេពុនៅស្វាយរៀង បច្ចុប្បន្នក្តាប់មិនបាន និង សាមិត្ត ទាហានកាប់ប៉ូរ៉ាល់សេពុនៅស្វាយរៀង បច្ចុប្បន្នក្តាប់មិនបាន។ ក្រោយពីចូលជា សេ-អ៊ី-អា យ៉េន ទទួលភារកិច្ចមានដូចជា៖ ដើរឃោសនាប្រជាជនតាមជនបទ និង ក្នុងទីក្រុងកុំឱ្យមានជំនឿជាមួយក្រុមខ្មែរក្រហម និង កសាងកម្លាំង សេ-អ៊ី-អា ក្នុងចំណោមយុវជនក្នុងក្រុងស្វាយរៀង។ ចុងឆ្នាំ១៩៦៩ យ៉េន ត្រូវផុតកំណត់ឈប់ធ្វើជាទាហាន១៨ខែ ក៏វិលត្រឡប់មករស់នៅស្រុកកំណើតវិញ រួចបន្តទាក់ទងខ្សែរយៈចាស់។ ទន្ទឹមនេះ មេឃុំ សូ ខ្មៅ បានឱ្យ យ៉េន ទាក់ទងខ្សែថ្មី២នាក់ទៀត គឺ ទៀង ជិន អតីតសិស្សថ្នាក់ទី៦ នៃវិទ្យាល័យស្វាយរៀង និង សួស សាបាន អតីតអ្នករត់ពន្ធ ឱ្យទៅតាមដានចលនារបស់ខ្មែរក្រហម បានឃើញជំរំខ្មែរក្រហមនៅភូមិកំពោតទូក។

ខែកញ្ញា ឆ្នាំ១៩៧០ ស ចាន់ បានឱ្យឈ្មោះ សាញ់ មកយក យ៉េន ពីភូមិខ្ទោ ទៅនៅបន្ទាយស៊ុប ខេត្តស្វាយរៀង។ ដល់ខែវិច្ឆិកា ស ចាន់ ក៏ចាត់តាំងកម្លាំងមួយចំនួនឱ្យទៅរស់នៅជាមួយចៅហ្វាយខេត្តស្វាយរៀងឈ្មោះ កោះ ឈួន។ យ៉េន ត្រូវបាន កោះ ឈួន យកមកនៅជិតខ្លួន ចាំបម្រើផ្ទាល់ និង មាន

ភារកិច្ចរត់សំបុត្រទាក់ទងមកខាងក្រសួងមហាផ្ទៃភ្នំពេញ និងទៅខាងសក្តិ៣ ឃឹម សំអុល, សក្តិ២ នេត សែព និង នួរុន ស៊ីវិល នៅការិយាល័យរបស់ កោះ ឈួន ក្រុងភ្នំពេញ ដែលសម្រាប់ទាក់ទងទៅគ្រប់ក្រសួង និង អង្គការអាមេរិកនៅភ្នំពេញ។

ដើមឆ្នាំ១៩៧១ ដល់ឆ្នាំ១៩៧៣ យ៉េន ត្រូវទៅបម្រើប្រពន្ធ កោះ ឈួន ដែលមានផ្ទះនៅជិតសាលា ១៨ មីនា ក្រុងភ្នំពេញ។ បន្ថែមពីការងារអ្នកបម្រើ យ៉េន គឺត្រូវរត់សំបុត្រ ពីភ្នំពេញបញ្ជូនទៅខេត្តស្វាយរៀង។ ក្រៅពីនេះ យ៉េន នៅតែបន្តកសាងកម្លាំងថ្មីបន្ថែម។ ខែកក្កដា ឆ្នាំ១៩៧៣ កោះ ឈួន ទៅធ្វើឯកអគ្គរដ្ឋទូតនៅប្រទេស ឡាវ ជាហេតុនាំ យ៉េន ទៅជាមួយ គ្រាន់បាននៅបម្រើប្រពន្ធ។ ស្ថិតនៅប្រទេស ឡាវ កោះ ឈួនបានទាក់ទងឈ្មោះ អ៊ុយ សយ ដើម្បីឱ្យជួយចាត់តាំងខ្មែរធ្វើសកម្មភាពនៅក្រៅប្រទេស។

អ៊ុយ សយ បានទាក់ទងឈ្មោះ សុខ គឹមគូ ជាអាណិកជនខ្មែរ ឡាវ បច្ចុប្បន្នធ្វើជំនួញពីសៀមចូលមក ឡាវ, អ៊ុង ស៊ីម ជាស្មៀនទូត, លឿង ជាអ្នកជំនួញនាំពី ឡាវទៅសៀម, សុ សាខន់, សេងតូច ជាអ្នករកស៊ីជាមួយជនជាតិបារាំងនៅ ឡាវ, ផែង ព្រឿង និង សេងធំ ជាអ្នកបើក ឡានឱ្យទូត ឡាវ សព្វថ្ងៃរស់នៅប្រទេស ឡាវ។ ឈ្មោះទាំងប៉ុន្មានខាងលើនេះ នាំគ្នាដើររកឈ្មោះប្រជាពលរដ្ឋខ្មែររស់នៅប្រទេស ឡាវ ដើម្បីរៀបចំជាសមាគមសម្រាប់ឃោសនាពីរបបកុម្មុយនីស្តនៅកម្ពុជា។

ក្រោយថ្ងៃរំដោះឆ្នាំ១៩៧៥ កោះ ឈួន និងភ្នាក់ងារទូតទាំងអស់ប្រមូលគ្នារត់ទៅបរទេស។ ចំណែក សុខ គឹមគូ, លឿង និង សុក សាខន ត្រូវទទួលគ្រប់គ្រង ឈ្មោះដែលមិនរត់ទៅបរទេសរស់នៅស្រុក ឡាវ និង ទាក់ទងទូតអាមេរិកនៅ ឡាវឈ្មោះ វិលល័រស្តី និង ទូតយួននៅ ឡាវឈ្មោះ វ៉ាន់ដុង និង លីខ្វាន់យូ និងបន្តសហការជាមួយ សេ-អ៊ី-អា នៅសៀមឈ្មោះ ដេត ឆាំ ជាសក្តិ៣ និង ឈ្មោះ មាស ដំ ជាសក្តិ៤។ ឈ្មោះអ្នកដែលមិនរត់ទៅបរទេសមានដូចជា៖ យ៉េន, សុខ គឹមគូ, លឿង, ផែង ព្រឿង, អ៊ុង ស៊ីម, សុខ សាខន, សេងធំ និង សេងតូច។ ក្រោយមកអ្នកទាំងនេះបាននាំគ្នាចុះទៅស៊ើបរកជនភៀសខ្លួនមកពីប្រទេសកម្ពុជាដើម្បីក្តាប់សភាពការណ៍បដិវត្តន៍នៅកម្ពុជា តើមានការសម្លាប់មនុស្សយ៉ាងម៉េច ជីវភាពរស់នៅស៊ីចុកយ៉ាងម៉េចពិសេសចំណុចលំបាក ដើម្បីយកទៅរាយការណ៍ឱ្យខាងអាមេរិកឈ្មោះ វិលល័រស្តី និងយួនឈ្មោះ វ៉ាន់ដុង និង លី ខ្វាន់យូវ។ ក្រោយពីស្តាប់ការរាយការណ៍រួច សុខ គឹមគូ, លឿង និង ស្ថានទូតទាំងពីរ បានដាក់ផែនការឱ្យចុះធ្វើសកម្មភាពដូចជា៖ ១) ឃោសនាប្រជាជនឱ្យក្រោកវាយរបបកុម្មុយនីស្តកម្ពុជានៅ ឡាវ ដោយលើកពីផលលំបាកប្រជាជនបដិវត្តន៍នៅកម្ពុជា យកមនុស្សអូសនង្គ័ល និង មិនឱ្យបរិភោគគ្រប់គ្រាន់។ ២) បំផុសប្រជាជននៅ ឡាវឱ្យរត់ទៅខាងប្រទេសសៀម ដើម្បីរៀបចំធ្វើទ័ពសៀម។ ៣) បំផុសឱ្យខ្មែរនៅបរទេសចូលមកកម្ពុជាវិញតាមការអំពាវនាវរបស់ទូត ឡាវ។ ៤) ប្រជាជនខ្មែរ សួររកទូតកម្ពុជានៅ ឡាវ គឺកុំប្រាប់ទីតាំង។ យ៉េន និងបក្ខពួកបានបំផុសប្រជាជនជាង១០០នាក់ឱ្យរត់ទៅប្រទេសសៀម ដើម្បីបង្កើតជាកងសេរីកា។ មួយវិញទៀតចាំយកព័ត៌មានពីទុក្ខលំបាកប្រជាជនខ្មែរដែលរស់នៅក្នុងរបបខ្មែរក្រហម ដែលរត់ចេញពីខេត្តស្ទឹងត្រែង និង កំពង់ស្រឡៅមក ឡាវ ដើម្បីយកទៅរាយការណ៍ជូនដល់ស្ថានទូតអាមេរិក និង យួន។

ឆ្នាំ១៩៧៦ បក្ខពួក យ៉េន នៅតែបន្តសកម្មភាពពីឆ្នាំ១៩៧៥ ដែលក្រោមបញ្ជារបស់ វិលល័រស្តី។ លើសពីនេះ គឺត្រូវបំផុសប្រជាជនខ្មែរដែលរស់នៅ ឡាវ ឱ្យរត់ទៅប្រទេសសៀម ក្នុងខេត្តណងខាយ ដែលមានជ័យ ប្រាសិទ្ធជាអ្នកទទួល ក្នុងគោលបំណងរៀបចំជាកងសេរីកា ដែលមានអាមេរិក និង បារាំងធានាផ្គត់ផ្គង់។ ផ្នែកមួយទៀត គឺត្រូវសហការជាមួយ ឡាវស្តាំ (ស្ថិតក្រោមការគ្រប់គ្រងសៀម) ដែលមានឈ្មោះ ស៊ុំ ហាក់ ជាមេឃុំ និង ទី ឃី គណៈ

ស្រុកស៊ីសត្តគាណា អតីតជារដ្ឋការចាស់ និងរដ្ឋការ ឡាវជាច្រើនកន្លែងទៀត ដើម្បីបំផុសប្រជាជនឱ្យរកវិធីប្រឆាំង និងរដ្ឋអំណាច ឡាវថ្មីបច្ចុប្បន្នជាបន្តបន្ទាប់ នៅក្នុងស្រុកស៊ីសត្តគាណា ក្រុងវៀងចន្ទ។

ឆ្នាំ១៩៧៧ យ៉េន ចេញទៅរកស៊ីជួញ មាន់ សាច់ជ្រូក និង សាច់គោ នៅផ្សារសន់មាន់ ក្រុងវៀងចន្ទ តែនៅតែបន្តសកម្មភាពជាមួយខ្សែចាស់ៗ នៅ ក្រុងវៀងចន្ទ។ សកម្មភាពដែលត្រូវបន្តធ្វើគឺមាន ៧ផ្នែក៖ ១) ទាក់ទងខ្សែ សេ-អ៊ី-អា ចាស់ដែលធ្លាប់ធ្វើសកម្មភាពរួមគ្នានៅស្រុកខ្មែរ តាមរយៈជនភៀសខ្លួនពីកម្ពុជាទៅ ឡាវ ដើម្បីក្តាប់ពីសភាពការរស់នៅប្រជាជនកម្ពុជាដែលត្រូវអង្គការគាបសង្កត់។ ២) ទាក់ទង ឡាវស្តាំ និងរដ្ឋការចាស់ដើម្បីធ្វើសកម្មភាពប្រឆាំងរបបថ្មីៗ ក្នុងកំឡុងឆ្នាំនេះ ស្ថានទូតខ្មែរនៅ ឡាវ ដែលមានឈ្មោះ មាក ទូច និង ប្រពន្ធឈ្មោះ ថុល មិនមានអ្នកបកប្រែភាសា ឡាវពេលមានទូតផ្សេងៗ ទាក់ទងមកម្តងម្កាលជាហេតុនាំឱ្យឈ្មោះ ផែង ព្រឿង ដែលចេះនិយាយភាសា ឡាវ បារាំង និង អង់គ្លេស មិនមានការងារអ្វីពិតប្រាកដ ចូលធ្វើការជាអ្នកបកប្រែ និង បើក ឡានឱ្យឈ្មោះ ថុល (ប្រពន្ធ មាក ទូច)។ ថុល បានឱ្យ ផែង ព្រឿង ជួយរកកូនឈ្នួលម្នាក់ទៀត ដើម្បីទៅបម្រើក្នុងស្ថានទូត ជាហេតុនាំឱ្យ យ៉េនបាន ទៅធ្វើការក្នុងស្ថានទូតខ្មែរ ឡាវរយៈពេលកន្លះខែ កំឡុងធ្វើការនៅស្ថានទូត យ៉េន និង ផែង ព្រឿង បាន ធ្វើសកម្មភាព ស៊ើបព័ត៌មានពីប្រទេសកម្ពុជា តាមរយៈស្ថានទូតអំពីស្ថានភាពការរស់នៅរបស់ប្រជាជន ដែលត្រូវជម្លៀសចេញពីទីក្រុង, តើនៅខ្មែរមិនមានការចាយលុយមែនឬមិនមែន?, តើកម្ពុជាបានកសាងប្រទេសឱ្យជឿនលឿនមហាលោតផ្លោះ មហាអស្ចារ្យ មែនឬមិនមែន ព្រោះស្ថានទូតអាមេរិកមិនជឿ ព្រោះឃើញថាកម្ពុជាកសិកម្មអន់ថយ និងមួយទៀត យ៉េន ត្រូវលួចឯកសារទស្សនាវដ្តីរបស់ទូតកម្ពុជា យកទៅឱ្យខាងស្ថានទូតអាមេរិកតាមរយៈ សុខ គឹមគូ។ ប្រហែលជាខែមិថុនា ឆ្នាំ១៩៧៧ ថុល ត្រូវផ្លាស់មកកម្ពុជា ហើយទូតថ្មីផ្លាស់ទៅប្រចាំនៅ ឡាវវិញ។ ដើមខែធ្នូ ឆ្នាំ១៩៧៧ ប្រទេស ឡាវ ចាប់ផ្តើមដេញជនជាតិខ្មែរឱ្យត្រឡប់មកកម្ពុជាវិញ។ យ៉េនបានសុំស្ថានទូតយួន ចុះឈ្មោះជាសញ្ជាតិយួន ដើម្បីស្នើសុំរស់នៅប្រទេស ឡាវបន្តទៀត ប៉ុន្តែត្រូវបានភាគីខាងស្ថានទូតវៀតណាមបដិសេធ។ លុះដល់ថ្ងៃទី១៧ ក្នុងខែធ្នូដដែល យ៉េនបានទទួលដែនការពី ក្រសួងមហាផ្ទៃ ឡាវ ដោយសន្យាថា និងធ្វើសំបុត្រយន្តហោះឱ្យ យ៉េនមកកាន់ក្រសួងមហាផ្ទៃប្រទេសកម្ពុជា។ ពេលបានមកដល់កម្ពុជា គឺតម្រូវឱ្យ យ៉េន ចុះស៊ើបការពីបញ្ហាក្នុងប្រទេសកម្ពុជា និងចំណុចស្ថិតក្នុងនៅខេត្តចំនួន៣ គឺ ស្ទឹងត្រែង មណ្ឌលគិរី និងរតនគិរី ដូចជា៖ ១) ផ្នែកយោធាក្នុងខេត្តស្ទឹងត្រែង ត្រូវក្តាប់យកចំណុចខ្លាំង និងខ្សោយ។ ២) រឿងស្បៀង និង សេដ្ឋកិច្ចទូទាំងប្រទេស តើខេត្តមួយណាដែលសំបូរជាងគេ។ ៣) សម្ភារសឹក និងរោងចក្រធ្វើសម្ភារសឹក ក្នុងខេត្តស្ទឹងត្រែង និងទូទាំងប្រទេស។ គោលដៅ យ៉េន ត្រូវធ្វើយ៉ាងម៉េចស៊ើបការឱ្យបានសម្រេចត្រឹមរយៈពេល ២ ទៅ៣ខែ ដោយរាយការណ៍ជូនទៅកាន់ស្ថានទូតយួន និង ឡាវប្រចាំនៅកម្ពុជា ឬ តាមរយៈ ថុល (ប្រពន្ធ មាក ទូច)។ យ៉េន ធ្វើការងារបានសម្រេចនឹងទទួលបានប្រាក់រង្វាន់ចំនួន២០០ដុល្លារ ពីភ្នាក់ងារទូតយួន។

ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៨ យ៉េន និង គ្រួសារ បានធ្វើដំណើរតាមរយៈយន្តហោះពីក្រុងវៀងច័ន្ទន៍ មកចុះនៅ ទីក្រុងប៉ាក់សេ ក្នុងបំណងធ្វើដំណើរមកខេត្តស្ទឹងត្រែង តែដោយសារនៅតំបន់ព្រំដែនស្ទឹងត្រែងមានបញ្ហាអសន្តិសុខ ព្រោះមានការបាញ់គ្នារវាងទាហានខ្មែរក្រហម និង យោធា ឡាវស្តាំ ទើបយន្តហោះ ត្រូវហោះសំដៅមកចុះចតនៅប្រលាន ទីក្រុងភ្នំពេញនៅវេលាម៉ោង១១ថ្ងៃត្រង់ រហូតដល់ម៉ោង ២ រសៀល អង្គការចាប់ខ្លួន និងបញ្ជូនមកកាន់មន្ទីរស-២១។

# គរុសិស្សភូមិភាគខេត្តព្រៃវែងសិក្សាឈ្វេងយល់អំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និងទស្សនាខ្សែភាពយន្តឯកសារ «កុំស្មានបងភ្លេច» នៅមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង

ថុន ស្រីពេជ្រ



គរុសិស្សភូមិភាគខេត្តព្រៃវែង មកសិក្សាឈ្វេងយល់អំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និងទស្សនាខ្សែភាពយន្តឯកសាររឿង «កុំស្មានបងភ្លេច» នៅមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង នៅថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០២៤។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅព្រឹកថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០២៤ មជ្ឈមណ្ឌលឯកសារខេត្តព្រៃវែងបានទទួលស្វាគមន៍គរុសិស្សឆ្នាំទី១ ជំនាញអង់គ្លេស-កុំព្យូទ័រ, សីលធម៌ពលរដ្ឋ-ខ្មែរ, គណិតវិទ្យា-រូបវិទ្យា និងរូបវិទ្យា-គីមីវិទ្យា មកពីសាលាគរុកោសល្យភូមិភាគខេត្តព្រៃវែងចំនួន១៥នាក់។ គោលបំណងរបស់គរុសិស្សដែលមកទស្សនកិច្ចការិយាល័យមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង គឺដើម្បីសិក្សាឈ្វេងយល់អំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និងទស្សនាខ្សែភាពយន្តឯកសារ «កុំស្មានបងភ្លេច» ។

មុននឹងចាប់ផ្តើមកម្មវិធី គរុសិស្សទាំងអស់បានទស្សនាពិព័រណ៍រូបភាពសម័យខ្មែរក្រហម និងបានចំណាយពេលវេលាប្រមាណជា៣០នាទីដើម្បីអានសៀវភៅ ទាក់ទងទៅនឹងព្រឹត្តិការណ៍ ក្នុងសម័យខ្មែរក្រហម រួមមាន ៖ សៀវភៅសាក្សីប្រវត្តិសាស្ត្រ, សាលក្រមក្នុងសំណុំរឿង០០១, សៀវភៅរឿងទម្លាយភាពស្ងៀមស្ងាត់, សៀវភៅអំពើប្រល័យពូជសាសន៍សំណុំរឿង០០២, រឿង"រាវនៅក្នុងភូមិក្នុងសម័យខ្មែរក្រហម, សៀវភៅ



គរុសិស្សភូមិភាគខេត្តព្រៃវែង ទស្សនាខ្សែភាពយន្តឯកសាររឿង «កុំស្មានបងភ្លេច» នៅមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង នៅថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០២៤។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ណែនាំគ្រូបង្រៀន, សៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និងទស្សនាវដ្តីស្វែងរកការពិត។

បន្ទាប់មក លោក ដេង ពង្សរ៉ាស៊ី នាយកមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង បានធ្វើការសំណេះសំណាលជាមួយគរុសិស្សទាំងអស់ និងបានបង្ហាញគ្រួសៗទាក់ទងទៅនឹងប្រវត្តិការិយាល័យមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង ដែលតម្កល់ទុកនូវឯកសារជាច្រើនជាពិសេសគឺជាឯកសារនៅក្នុងតំបន់ និងភូមិភាគបូព៌ា ក្នុងសម័យខ្មែរក្រហម។ លោក ដេង ពង្សរ៉ាស៊ី បានពន្យល់ពីនិយមន័យប្រវត្តិសាស្ត្រ និងលើកយកអត្ថបទមួយ «ហេតុអ្វីបានជាចាំបាច់ត្រូវរៀនអំពីប្រវត្តិសាស្ត្រ»? បន្ទាប់មក លោក ដេង ពង្សរ៉ាស៊ី បានបង្ហាញសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) បោះពុម្ពលើកទី២ នៅក្នុងឆ្នាំ២០២០ ដែលបានបន្ថែមមេរៀនទាក់ទងនឹងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ប៉ុសាលាក្តីខ្មែរក្រហម។

នៅក្នុងឱកាសនោះដែរ លោក ដេង ពង្សរ៉ាស៊ី ក៏បានលើកឡើងអំពីគោលបំណងនៃការផលិតខ្សែភាពយន្តឯកសារ «កុំស្មានបងភ្លេច» គ្រួសៗ ដើម្បីជាមូលដ្ឋានដល់សិស្សក្នុងការទស្សនា។ បទចម្រៀង និងភ្លេង នៅក្នុងខ្សែភាពយន្តឯកសារនេះ មិនត្រឹមតែធ្វើឱ្យអ្នកស្តាប់ពិរោះទេប៉ុន្តែថែមទាំងមានឥទ្ធិពលខ្លាំងលើបញ្ហានយោបាយ និងជាឧបករណ៍ដ៏មានប្រសិទ្ធភាពក្នុងការឃោសនា ផ្សព្វផ្សាយ និងបញ្ចុលមនោគមវិជ្ជាឱ្យមនុស្សដើរតាមទៀតផង។

គរុសិស្សបានទស្សនាខ្សែភាពយន្តឯកសារ «កុំស្មានបងភ្លេច» យ៉ាងស្ងៀមស្ងាត់រហូតដល់ចប់ នៅវេលាម៉ោង១១កន្លះព្រឹក ហើយបង្ហាញនូវចំណាប់អារម្មណ៍ដូចខាងក្រោម៖

១) ខ្ញុំឈ្មោះ ផល់ ភេត្រា ភេទប្រុស អាយុ ២៥ឆ្នាំ គឺជាគរុសិស្សឆ្នាំទី១ ជំនាញ អង់គ្លេស-កុំព្យូទ័រ។ ពេលខ្ញុំបានមកដល់ការិយាល័យនេះភ្លាម ខ្ញុំចាប់អារម្មណ៍ទៅលើបរិយាកាសនៅទីនេះស្រស់ស្រាយ ហើយមានការរៀបចំបានល្អ។ ខ្ញុំឃើញរូបភាព សៀវភៅ និងឯកសារជាច្រើនដែលតម្កល់ទុកនៅក្នុងការិយាល័យនេះ។ ខ្ញុំយល់ថា ខ្សែភាពយន្តឯកសារនេះ គឺជាការចងក្រងឡើងវិញទាក់ទងទៅនឹងប្រវត្តិសាស្ត្រតាំងពីសម័យសង្គម

រាស្ត្រនិយម រហូតដល់សម័យកម្ពុជាប្រជាធិបតេយ្យ និងបន្តរហូតមកដល់បច្ចុប្បន្ន។ ខ្ញុំបានទទួលចំណេះច្រើននៅក្នុងថ្ងៃនេះ ទាក់ទងទៅនឹងប្រវត្តិសាស្ត្ររបស់ប្រទេសកម្ពុជា។

២) ខ្ញុំឈ្មោះ រុន នរក្ស ភេទប្រុស អាយុ២០ឆ្នាំ គឺជានិស្សិតឆ្នាំទី១ ជំនាញ អង់គ្លេស-កុំព្យូទ័រ។ ខ្ញុំទទួលបាននូវចំណេះដឹងប្លែកៗជាច្រើនដូចជា ដឹងអំពីទុក្ខលំបាករបស់ប្រជាជននៅក្នុងរបបខ្មែរក្រហម ហើយអ្នកដែលរៀនជំនាញផ្សេងក៏អាចសិក្សាអំពីប្រវត្តិសាស្ត្របានដែរ។ យើងគួរតែសិក្សាប្រវត្តិសាស្ត្រដើម្បីឱ្យដឹងថាសង្គមរបស់យើងឆ្លងកាត់អ្វីខ្លះ ហើយតើយើងគួរធ្វើបែបណាដើម្បីជួយឱ្យប្រទេសយើងមានការអភិវឌ្ឍន៍ និងមិនឱ្យដើរតាមគន្លងចាស់ដែលធ្លាប់ខុសតទៅទៀត។

៣) ខ្ញុំឈ្មោះ កុយ ស្រីមា ភេទស្រី អាយុ១៩ឆ្នាំ គឺជានិស្សិតជំនាញ គណិតវិទ្យា-រូបវិទ្យា។ ខ្ញុំមានអារម្មណ៍ប្លែកពេលមកអានសៀវភៅ, ស្តាប់វាគ្មិនបកស្រាយ និងបានមកទស្សនាខ្សែភាពយន្តឯកសារនៅទីនេះ។ ខ្ញុំមិនធ្លាប់ទស្សនា ខ្សែភាពយន្តឯកសារ «កុំស្មានបងភ្លេច» ពីមុនមកទេ។ ខ្សែភាពយន្តនេះ បង្ហាញពីប្រវត្តិសាស្ត្ររបស់ប្រទេសយើងតាមសម័យកាលនីមួយៗ និងមានលាយ ឡំគ្នា មានដូចជា សិល្បៈ, តន្ត្រី, ការអភិវឌ្ឍន៍ប្រទេស ក៏ដូចជារឿងរ៉ាវផ្សេងៗនៅក្នុងប្រទេសកម្ពុជា។

៤) ខ្ញុំឈ្មោះ ផាត សុជាតា ភេទស្រី មានអាយុ១៩ឆ្នាំ គឺជានិស្សិតឆ្នាំទី១ នៃជំនាញ អក្សរសាស្ត្រខ្មែរ-សីលធម៌។ ខ្ញុំមានអារម្មណ៍រំភើបពេលដែលខ្ញុំបានមកដល់ទីនេះ។ ទស្សនកិច្ចសិក្សានេះអាចជួយឱ្យខ្ញុំយល់ដឹងពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យច្រើនជាងមុន ជាពិសេស ការតាំងបង្ហាញរូបភាពឯកសារ និងសៀវភៅជាច្រើន។ ប្រសិនបើខ្ញុំមានពេលទំនេរ ខ្ញុំនឹងមកអានសៀវភៅ ទស្សនារូបភាពនិងទស្សនាខ្សែភាពយន្តឯកសារម្តងទៀត។

៥) ខ្ញុំឈ្មោះ ហេង ចាន់រ៉ាសនា ភេទប្រុស អាយុ៣១ ឆ្នាំ គឺជានិស្សិតជំនាញ អក្សរសាស្ត្រអង់គ្លេស-កុំព្យូទ័រ។ ខ្ញុំគិតថាកម្មវិធីបណ្តុះបណ្តាលនិងបង្ហាញដល់សាធារណជនទាក់ទងប្រវត្តិសាស្ត្រគឺល្អ។ ខ្ញុំចង់ផ្តាំផ្ញើទៅក្មេងជំនាន់ក្រោយឱ្យសិក្សាឈ្វេងយល់អំពីប្រវត្តិសាស្ត្ររបស់ប្រទេសយើង ព្រោះប្រសិនបើយើងមិនស្គាល់ប្រវត្តិសាស្ត្ររបស់ប្រទេសយើងទេ យើងនឹងមិនមានអ្វីទាល់តែសោះ។





គរុសិស្សភូមិភាគខេត្តព្រៃវែងមកសិក្សាអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និងទស្សនាខ្សែភាពយន្តឯកសាររឿង «កុំស្មានបងភ្លេច» នៅមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង នៅថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០២៤។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# សំរិទ្ធិ ថា ៖ ខ្មែរក្រហមចាប់ខ្ញុំធ្វើទាហាន

**ធូច ស្រីធីន**



*សំរិទ្ធ ថា អាយុ៧៧ឆ្នាំ សព្វថ្ងៃរស់នៅភូមិអូរុន ឃុំអូរស្វាយ ស្រុកបុរីអូរស្វាយ-សែនជ័យ ខេត្តស្ទឹងត្រែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

ខ្ញុំឈ្មោះ សំរិទ្ធិ ថា ភេទប្រុស អាយុ៧៧ឆ្នាំ គឺជាជនជាតិខ្មែរ។ ពីមុនខ្ញុំរស់នៅភូមិបុស្សជ្រៃ ឃុំទ្រា ស្រុកសំរោង ខេត្តតាកែវ បច្ចុប្បន្នខ្ញុំរស់នៅភូមិអូររុន ឃុំអូរស្វាយ ស្រុកបុរីអូរស្វាយសែនជ័យ ខេត្តស្ទឹងត្រែង។

ឪពុកម្តាយខ្ញុំស្លាប់យូរណាស់មកហើយដោយសារជំងឺ។ ខ្ញុំមានបងប្អូនចំនួន៨នាក់ ហើយស្លាប់៤នាក់និងនៅរស់៤នាក់ហើយខ្ញុំគឺជាកូនច្បងគេបង្អស់។ ខ្ញុំមករស់នៅអូរស្វាយឆ្នាំ១៩៦៦។ ប្រជាជនមកនៅតំបន់អូរស្វាយនេះតាមរយៈ សម្តេចព្រះនរោត្តម សីហនុ ប្រកាសឱ្យប្រជាជនដែលស្ម័គ្រចិត្តមករស់នៅលើទឹកដីតំបន់អូរស្វាយ នឹងចែក គោ ក្របី ផ្ទះ ដីស្រែ ដីភូមិ ប្រជាជនរស់នៅបង្កបង្កើនផលដំណាំ កាប់ឆ្ការព្រៃ។ សម្តេចព្រះនរោត្តម សីហនុ បានឱ្យប្រជាជនរស់នៅតំបន់នេះសម្រាប់ជារបងការពារព្រំដែន ក៏សម្រាប់ប្រជាជនខ្វះខាត។ ប្រជាជនតំបន់នេះ ភាគច្រើនប្រកបរបរធ្វើស្រែចម្ការ។

អំឡុងឆ្នាំ១៩៧០ ខ្ញុំរៀបការចំពេលដែលខ្មែរក្រហមរំដោះតំបន់នេះបាន ដោយមិនមានការបង្ខិតបង្ខំឡើង។ ខ្មែរក្រហមចាប់ខ្ញុំធ្វើទាហានរយៈពេល១៨ខែ ដើម្បីឱ្យការពារទឹកដីជិតព្រំប្រទល់ឡាវ ការពារពីជនឈ្លានពាន ខ្មែរនិងខ្មែរ និងវៀតណាម។ សង្គ្រាមនៅតំបន់អូរស្វាយ បានកើតឡើងមុនសង្គ្រាមនៅទីក្រុងភ្នំពេញ។ ខ្ញុំចង់រត់តែមិនហ៊ានរត់ខ្លាចខ្មែរក្រហមបាញ់ប្រហារសម្លាប់ចោល។

ក្រោយពីបញ្ចប់សង្គ្រាម សម្តេច ព្រះនរោត្តម សីហនុ ទ្រង់បានមកចុះសួរសុខទុក្ខប្រជាជននៅសម័យក្រោយខ្មែរក្រហមដួលរលំដែលជួបទុក្ខវេទនាបែកបាក់ឪពុកម្តាយបងប្អូន។ ទ្រង់បានចែក គោ ក្របី សម្រាប់ឱ្យពលរដ្ឋប្រកបរបរធ្វើស្រែចម្ការ។ សព្វថ្ងៃប្រជាជននៅតំបន់នេះ មានការប្រកបរបរនេសាទត្រីដោយប្រើប្រាស់ឧបករណ៍ មង សំណាញ់។

ក្នុងអំឡុងពេលថ្មីៗនេះ មានការធ្វើពិធីរំឭកគុណដល់សម្តេចព្រះ នរោត្តម សីហនុ មានការរៀបចំជួសជុលស្តូបអនុស្សាវរីយ៍ដែលខូចខាត។

# កិច្ចពិភាក្សា អំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ជាមួយនិស្សិតនៅសាកលវិទ្យាល័យជាតិគ្រប់គ្រង

**ផេង ពង្សរ៉ាស៊ី**



និស្សិតសាកលវិទ្យាល័យជាតិគ្រប់គ្រងចំនួន៣៥នាក់ មកទស្សនកិច្ចសិក្សា នៅមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង នៅថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០២៤។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅព្រឹកថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០២៤ និស្សិតឆ្នាំទី៤នៃសាកលវិទ្យាល័យជាតិគ្រប់គ្រងចំនួន ៣៥ នាក់ បានជួបជុំគ្នាដើម្បីពិភាក្សាអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ជាមួយលោក ផេង ពង្សរ៉ាស៊ី នាយកកម្មវិធីអប់រំពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា នៃមជ្ឈមណ្ឌលឯកសារកម្ពុជា។ ការជួបជុំនេះបានប្រព្រឹត្តទៅតាមការរៀបចំរបស់សាស្ត្រាចារ្យ ជា សៀវម៉ី នៅក្នុងបន្ទប់សិក្សានៃសាកលវិទ្យាល័យជាតិគ្រប់គ្រង មានទីតាំងស្ថិតនៅរាជធានីភ្នំពេញ រយៈពេល២ម៉ោង គឺចាប់ពីម៉ោង៨ ដល់ ១០ព្រឹក។ គោលបំណងនៃការពិភាក្សានេះ គឺដើម្បីបង្កើនចំណេះដឹងបន្ថែមពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និងបង្កើនសមត្ថភាពស្រាវជ្រាវរបស់និស្សិត។ ដើម្បីសម្រេចបានគោលបំណងនេះ និស្សិតទាំងអស់ ទទួលបានចំណេះដឹងជាពិសេសប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និង ពីវិធីសាស្ត្រសម្ភាសន៍អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដើម្បីជាជំនួយដល់កិច្ចការងារសិក្សាស្រាវជ្រាវនៅក្នុងថ្នាក់។



*លោក ផេង ពង្ស៍រ៉ាស៊ី នាយកមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង ធ្វើបទបង្ហាញអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ដល់និស្សិតសាកលវិទ្យាល័យជាតិគ្រប់គ្រង នៅថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០២៤ ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

នៅក្នុងកិច្ចពិភាក្សានេះ និស្សិតទាំង៣៥នាក់ទទួលបានការបកស្រាយបង្ហាញពី៖ ១) អត្ថន័យនៃពាក្យ «ប្រវត្តិសាស្ត្រ» និងភាពចាំបាច់ក្នុងការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩), ២) ការពន្យល់ពីមាតិកាប្រវត្តិសាស្ត្រសង្ខេប ដោយផ្តោតសំខាន់លើគោលការណ៍៨ចំណុចដែលខ្មែរក្រហមបានអនុវត្តក្នុងរយៈពេលដែលខ្លួនដឹកនាំប្រទេស និង ៣) ការដោះស្រាយចម្ងល់ទាំងអស់របស់និស្សិត ទាក់ទងនឹងសំណួរអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)។ សូមបញ្ជាក់ថា មុននឹងចាប់ផ្តើមការធ្វើបទបង្ហាញ លោក ផេង ពង្ស៍រ៉ាស៊ី បានផ្តល់ពេលវេលាដល់និស្សិតទាំង៣៥នាក់ ឱ្យសរសេរសំណួរនៅលើក្រដាសម្នាក់មួយសំណួរ នូវចម្ងល់ផ្សេងៗពីប្រវត្តិសាស្ត្រខ្មែរក្រហម ដើម្បីទទួលបានចម្លើយពីវាគ្មិន។ ក្នុងចំណោមនិស្សិតទាំងអស់គឺមាននិស្សិតខ្លះបានសួរសំណួររហូតដល់ទៅ៤ ហើយសំណួរទាំងអស់ ត្រូវបានបកស្រាយនៅបន្ទាប់ពីការធ្វើបទបង្ហាញពីប្រវត្តិសាស្ត្រខ្មែរក្រហមត្រូវបានបញ្ចប់ទៅ។ ចុងបញ្ចប់នៃកិច្ចពិភាក្សានេះ និស្សិតទទួលបានទស្សនាវដ្តីស្វែងរកការពិត លេខពិសេសម្នាក់១ច្បាប់។ ក្រោយចប់កិច្ចពិភាក្សា និស្សិតទាំងអស់បានបង្ហាញពីការយល់ដឹងច្រើនជាងមុនទាក់ទងនឹងប្រវត្តិសាស្ត្រខ្មែរក្រហម។

តាមរយៈកិច្ចពិភាក្សាក្នុងថ្ងៃនេះដែរ លោក ផេង ពង្ស៍រ៉ាស៊ី និងសាស្ត្រាចារ្យ ជា សៀវម៉ី បានឯកភាពគ្នាក្នុងការដឹកនាំសិស្សទៅធ្វើទស្សនកិច្ចសិក្សា និងចុះសិក្សាស្រាវជ្រាវនៅមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង និងមជ្ឈមណ្ឌលឯកសារខេត្តតាកែវ ដែលជាសាខារបស់មជ្ឈមណ្ឌលឯកសារកម្ពុជា តាមពេលវេលាដែលបានព្រមព្រៀងគ្នា គឺនៅចុងខែវិច្ឆិកា និងដើមខែធ្នូ ឆ្នាំ២០២៤នេះ។ និស្សិតនឹងសិក្សាឈ្វេងយល់បន្ថែមពី (១) កិច្ចការងារ និងដំណើរការនៃការប្រមូលនិងចងក្រងឯកសារ ទាក់ទងនឹងរបបខ្មែរក្រហមរបស់មជ្ឈមណ្ឌលឯកសារកម្ពុជានៅតាមទីតាំងនីមួយៗ, (២) ប្រវត្តិសាស្ត្រខ្មែរក្រហមលម្អិតជាងមុន, (៣) វិធីសាស្ត្រសម្ភាសន៍អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម, (៤) ការចុះទៅជួប និងសម្ភាសន៍អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដោយផ្ទាល់ និង (៥) ការសិក្សាអំពីទីតាំងវាលពិឃាតខ្មែរក្រហមនៅក្នុងខេត្តដោយផ្ទាល់។

# មាស អឿន ៖ ខ្ញុំធ្វើស្រែទឹកស៊ីជើងឡើងរលួយ ខ្មែរក្រហមមិនឱ្យខ្ញុំសម្រាក

**យន់ ឃីម**

ខ្ញុំឈ្មោះ មាស អឿន ភេទប្រុស អាយុ៦៨ឆ្នាំ មានស្រុកកំណើតនៅភូមិសេសាន ឃុំកំភុន ស្រុកស្ទឹងត្រែង ខេត្តស្ទឹងត្រែង ហើយសព្វថ្ងៃរស់នៅភូមិអូររុន ឃុំអូរស្វាយ ស្រុកបុរីអូរស្វាយសែនជ័យ ខេត្តស្ទឹងត្រែង។ ឪពុកម្ដាយខ្ញុំបានស្លាប់កាលពីសម័យសង្គមរាស្ត្រនិយម។ ខ្ញុំរៀបការនៅឆ្នាំ១៩៨៨ និងមានកូនចំនួន៩ នាក់។



មាស អឿន អាយុ៦៨ឆ្នាំ សព្វថ្ងៃរស់នៅភូមិសេសាន ឃុំកំភុន ស្រុកស្ទឹងត្រែង ខេត្តស្ទឹងត្រែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅតំបន់អូរស្វាយកាលពីមុនគឺមានការយកប្រជាជននិងកងទ័ពមករស់នៅដើម្បីការពារព្រំដែន។ កាលនោះប្រទេសឡាវមានការឈ្លានពានយកទឹកដីខ្មែរជាច្រើនដូច្នេះ សម្ដេចព្រះ នរោត្តម សីហនុ ទ្រង់យកប្រជាជនមកនៅតំបន់នេះជារនាំងការពារព្រំដែន។ ប្រហែលជាឆ្នាំ១៩៦៥ ឬ ១៩៦៦ ប្រជាជនមកនៅទីនេះ ពេលស្តុបអនុស្សាវរីយ៍សាងសង់រួចរាល់មានកន្លែងរាំបាសាលារៀនព្រលានយន្តហោះ ផ្សារសម្រាប់ប្រជាពលរដ្ឋធ្វើជំនួញរកស៊ី។ ក្រោយសាងសង់រួចរាល់ទ្រង់តែងតែមកជួបសំណេះសំណាលជាមួយប្រជាជន ជួនកាលមួយឆ្នាំម្ដង ជួនកាលពីរឆ្នាំម្ដង។ ពេលទ្រង់មកមានយកក្រណាត់មកចែកឱ្យប្រជាពលរដ្ឋ។ កាលនោះ ខ្ញុំបានជួបទ្រង់តែមិនបានចាប់ព្រះហស្តនោះទេ ព្រោះកាលនោះមានមនុស្សច្រើនណាស់ប្រជ្រៀតគ្នាដើម្បីបានជួបទ្រង់និងបានប៉ះព្រះកាយទ្រង់។

មុនសង្គ្រាមតំបន់អូរស្វាយមានប្រជាជនទាហានរស់នៅហើយធ្វើផ្ទះថ្មសុទ្ធតែផ្ទះប្រក់ក្បឿងចែកសម្រាប់អ្នករស់នៅ តែបើសម្រាប់អ្នកដែលរស់នៅចាប់ពីស្ពានមកផ្ទះខ្ញុំនេះ គឺផ្ទះឈើធម្មតាហើយចែកដីឱ្យ៤០ម៉ែត្រសម្រាប់ប្រជាជន។ លុះដល់របប លន់ នល់ តំបន់នេះចាប់ផ្ដើមតឹងតែងមានសភាពរញ៉េរញ៉ៃ ដោយសាររមានរដ្ឋប្រហារទម្លាក់សម្ដេចព្រះ នរោត្តម សីហនុ មានការប្រើអំណាចគាបសង្កត់បង្កជាសង្គ្រាម។

នៅតំបន់អូរស្វាយខ្មែរក្រហមចូលមកនៅឆ្នាំ១៩៧០ កាលនោះចូលមកវាយ លន់ នល់ បន្ទាប់ពីវាយទាហាន លន់ នល់ ចេញខ្មែរក្រហមបានចូលកាន់កាប់តំបន់នេះម្ដង។ ពេលចូលមកមុនដំបូងគឺហូបបាយតាមផ្ទះ មិនដល់រយៈពេលមួយឆ្នាំ

ផងក៏ចាប់ផ្តើម ហូបរួមៗ ចូលដល់បាយរួមខ្មែរក្រហមចាប់ផ្តើមធ្វើបាបប្រជាជនធ្វើការតាំងពីម៉ោង៦រហូតដល់ម៉ោង១១ហើយបាយបានតែម្នាក់ពីរពេលៗ បាយក្នុងម្នាក់បានកន្លះកំប៉ុង ពីរនាក់បានមួយកំប៉ុង ហើយលាយតាំងពីដើមចេក ផ្លែល្ហុងពោត បើមានពោតលាយពោត មានផ្លែចេកលាយផ្លែចេក មានគល់ចេកលាយគល់ចេកៗ បើគល់ចេកវិញបកសំបកហើយ ឈូសលាយបាយមានមួយគ្រាប់ៗ បើសម្លក្នុងមួយខ្ទះត្នោតមានត្រីមួយកង់ពីរកង់បន្លែត្រកួនៗ ប្រជាជនមានសភាពទ្រុឌទ្រោម គ្មានកម្លាំងកំហែង ហើយជួនកាលម៉ោងបី ខ្ញុំនិងអ្នកដទៃទៀតត្រូវខ្មែរក្រហមប្រកាសអាសន្នថាមាន សេអ៊ីអា (CIA)ចូលមកក៏នាំគ្នាចល័តចេញទៅព្រៃៗ ពេលត្រឡប់មកវិញខ្មែរក្រហមឱ្យរើសខសត្រឡប់មកវិញយកមកដាក់ក្នុងសហករណ៍ៗ ចំណែកក្មេងៗគឺមិនមានអីហូបទេ ធំតែក្បាលពោះគ្មានខោគ្មានអាវសម្រាប់ស្លៀកពាក់ៗ នៅម៉ោង៦ល្ងាចចាប់ផ្តើមប្រជុំជីវភាព ពេលប្រជុំចប់ខ្ញុំ នឹងអ្នកភូមិត្រូវខ្មែរក្រហមបញ្ជូឱ្យទៅចម្ការ រហូតមកដល់ម៉ោង៩យប់បានត្រឡប់មកសម្រាកៗ ម៉ោង៣ព្រឹកចាប់ផ្តើមដើបគោរពទង់បក្សៗ ដល់ម៉ោង៦ព្រឹកទៅធ្វើការបន្តទៀតៗ ពេលថ្ងៃបន្ទាប់ពីបាយហើយក្លាមខ្មែរក្រហមចាប់ផ្តើមឱ្យចបម្នាក់មួយទៅកាប់ដីបូកតាមភ្លឺស្រែ ដល់ម៉ោង២រសៀល ឈប់រំលាយដីបូកចាប់ផ្តើមចុះស្ទូងស្រូវវិញម្តងៗ តែស្ទូងមិនមែនស្ទូងទាំងអស់គ្នាទេ មានខ្លះនៅស្ទូង ខ្លះទៅគ្រួសព្រៃៗ

ខ្ញុំធ្វើស្រែទឹកស៊ីដើងឡើងរលួយខ្មែរក្រហមមិនឱ្យខ្ញុំសម្រាកទេ ឱ្យខ្ញុំភ្ជួរស្រែបន្តៗ ដល់ភ្លឺឡើងត្រូវក្រោកទៅភ្ជួរឱ្យហើយមុនគេចុះទៅស្ទូងម៉ោង៧ព្រឹក ដល់ម៉ោង១០បានដោះក្របីលែងឱ្យស៊ីស្មៅហើយវេចបាយទៅឃ្វាលក្របីនៅក្រៅ ហើយបាយមិនគ្រប់សម្រាប់ចម្អែតក្រពះទេ ៗ

បច្ចុប្បន្នប្រជាពលរដ្ឋនៅតំបន់នេះភាគច្រើនធ្វើស្រែចម្ការ និងនេសាទសម្រាប់ហូបៗ ជាទូទៅប្រជាជននេសាទតាមបែបបុរាណ ដូចខ្ញុំនេសាទតាំងពីឆ្នាំ១៩៧៩ មកតែនេសាទសម្រាប់ហូបមិនបានលក់ដូរអ្វីទេៗ ការនេសាទរបស់ខ្ញុំមិនសូវជាមានផលលំបាកអ្វីទេបើលំបាកគឺលំបាកតែពេលយប់ដោយសារខ្ញុំមានវ័យចំណាស់ ភ្នែកមើលមិនសូវច្បាស់ៗ ឥឡូវខ្ញុំឈប់ហើយ ទុកឱ្យកូនរកម្តងៗ សព្វថ្ងៃនេះយើងរស់នៅក្រោមទំនប់វារីអគ្គិសនីភ័យខ្លាចតែទំនប់បាក់មកទេ ៗ



រដ្ឋបាលខេត្តស្ទឹងត្រែងរៀបចំពិធីគោរពព្រះវិញ្ញាណក្ខន្ធ ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជបិតា ឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិ ខ្មែរគម្រប់ខួប ១២ព្រះវស្សានៃការយាងសោយព្រះទិវង្គត នៅស្រុកបុរីអូរស្វាយសែនជ័យ នៅថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២៤ៗ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# មុត សុភា ៖ ខ្មែរក្រហមចាប់បងថ្លៃខ្ញុំយកទៅសម្លាប់

អ៊ី រក្សា



មុត សុភា អាយុ៦៧ឆ្នាំ សព្វថ្ងៃរស់នៅឃុំអូរស្វាយ ស្រុកបុរីអូរស្វាយ-សែនជ័យ ខេត្តស្ទឹងត្រែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ មុត សុភា ភេទស្រី អាយុ៦៧ឆ្នាំ មានបងប្អូនចំនួន៥នាក់គឺស្រីចំនួន៤ និងប្រុសម្នាក់។ ចំណែកកូនខ្ញុំមានចំនួន៥នាក់។ ខ្ញុំមានស្រុកកំណើតនៅ ខេត្តតាកែវ ហើយខ្ញុំបានមករស់នៅក្នុងតំបន់អូរស្វាយនៅឆ្នាំ១៩៦៤។

កាលពីមុនតំបន់អូរស្វាយមាន សាលារៀនរោងតម្បាញ រោងដំដែក សាលាស្រុក កន្លែងកសិកម្ម មានច្រើនកន្លែង ហើយមកដល់សព្វថ្ងៃនេះនៅសល់ស្តូបសម្តេចព្រះ នរោត្តម សីហនុ។ ក្រៅពីនេះសម្តេចព្រះនរោត្តម សីហនុ ទ្រង់បានយាងចុះមកសម្ពោធនៅសាលាឆទាននៅកន្លែងកំពង់ទឹក។ កាលនោះខ្ញុំមានអាយុ១៨ឆ្នាំហើយ ខ្ញុំក៏បានចាប់ព្រះហស្តទ្រង់ផងដែរ។ សម្តេចព្រះ នរោត្តម សីហនុ បានចែកអំណោយដោយឱ្យក្រណាត់ម្នាក់មួយដុំដល់អ្នកចូលរួមនៅពេលនោះ។

ពេលមានសង្គ្រាមស្តូបអនុស្សាវរីយ៍សម្តេចព្រះនរោត្តម សីហនុ មិនមានការខូចខាតទេ ការទម្លាក់គ្រាប់បែក ប៉ះពាល់ដល់សាលារៀន និងបន្ទាយទាហានក្នុងទឹកដីអូរស្វាយ។ មូលហេតុដែលសម្តេចព្រះនរោត្តម សីហនុ បង្កើតភូមិអូរស្វាយ

នេះឡើងព្រោះដើម្បីការពារកុំឱ្យប្រទេសឡាវយកទឹកដីនៅទីនេះ។ ការបង្កើតភូមិអូរស្វាយ សម្ដេចព្រះនរោត្ដម សីហនុ បានយកប្រជាជននិងទាហានឱ្យមករស់នៅតំបន់អូរស្វាយដោយផ្ដល់ឱ្យនូវដីសម្រាប់សាងសង់ផ្ទះ រួមទាំងឱ្យប្រាក់ខែក្នុងមួយខែចំនួន៣៥០រៀល។ ចំណែកអង្ករ ប្រហុកអំបិលមានលក់ក្នុងតម្លៃថោកឱ្យប្រជាជន ហើយទ្រង់បានចែកគោឱ្យចិញ្ចឹម ដើមចេក និង ដើមដូងឱ្យប្រជាជនដាំ។ ដីភូមិនេះមានទំហំទទឹង៤០ម៉ែត្រ និងបណ្ដោយ៥០០ម៉ែត្រក្នុងមួយគ្រួសារនិងដីស្រែចម្ការថែមទៀត។ មុនពេលខ្មែរក្រហមចូលមកដល់ភូមិអូរស្វាយគឺមានភាពសប្បាយរីករាយ សាលារៀននៅស្អាតទាំងអស់រួមទាំងមានប្រព័ន្ធទឹកត្រឹមត្រូវ។ ប៉ុន្តែនៅពេលនោះសម្បូរទៅដោយជំងឺគ្រុនចាញ់បណ្ដាលឱ្យអ្នកភូមិឈឺស្លាប់។ ប្រជាជននាំគ្នាផ្សំថ្នាំដោយខ្លួនឯង ថ្នាំឫសឈើ ថ្នាំវីតាមីនសេ និងថ្នាំប៉ារ៉ា។

ពេលខ្មែរក្រហមចូលមកកាន់កាប់ទឹកដីតំបន់អូរស្វាយនៅឆ្នាំ១៩៧០ឬឆ្នាំ១៩៧១ ហើយបង្កើតជាសហករណ៍ដោយផ្លាស់ប្ដូរភូមិថ្មី ដីថ្មី នៅតំបន់អូរស្វាយត្រូវបានទុកចោល។ មុនឆ្នាំ១៩៧២ ខ្ញុំធ្វើពេទ្យ និងគ្រូបង្រៀនកុមាររួមទាំងបង្កើតឱ្យមានក្រុមសិល្បៈទៀតផង។ ខ្មែរក្រហមបង្ខំខ្ញុំឱ្យយកគ្រួសារ តែខ្ញុំមិនព្រម។

នៅតំបន់អូរស្វាយគ្មានកន្លែងសម្លាប់មនុស្សឬធ្វើទារុណកម្មអ្វីនោះទេ ខ្មែរក្រហមចាប់យកប្រជាជនទៅកន្លែងផ្សេង សម្លាប់ចោលជាបន្តបន្ទាប់ប៉ុន្តែខ្មែរក្រហមមិនដែលឱ្យប្រជាជនណាឃើញនោះទេ ហើយខ្មែរក្រហមចាប់បងថ្លៃខ្ញុំដោយដាក់ប្រវាក់ប៉ុនកដៃអូសទៅ។

ការប្រកបមុខរបរអ្នកភូមិភាគច្រើនប្រកបមុខរបរនេសាទត្រីដោយការដាក់មង សំណាញ់ សន្ទូច ទ្រូ និង លប តាំងពីជំនាន់សម្ដេចព្រះនរោត្ដម សីហនុមកម្ល៉េះហើយត្រីកាលនោះសម្បូរណាស់ត្រីបាសាដាយមួយទម្ងន់១៥គីឡូក្រាមមកដល់សព្វថ្ងៃបាត់បង់អស់ហើយ។ ខ្ញុំមានការបារម្ភចំពោះទំនប់វារីអគ្គិសនីនៅពេលមានភ្លៀងធ្លាក់ខ្លាំងគឺមានការបើកទំនប់ធ្វើឱ្យទឹកធ្លាក់មកក្នុងភូមិជន់លិច។



ទន្លេមេគង្គ នៅស្រុកបុរីអូរស្វាយសែនជ័យ ខេត្តស្ទឹងត្រែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ព្រះរាជបណ្ណាល័យហ្លួងម៉ែ ចូលរួមតាំងពិព័រណ៍ផលិតផលសូត្រចាម ក្រោមប្រធានបទ «ការលើកស្ទួយសហគ្រិនស្ត្រី ទៅកាន់ទីផ្សារអន្តរជាតិ»

ជាវ៉ាវដ្ឋ មេត្តា



ឯកអគ្គរដ្ឋទូតតួកគី ប្រចាំប្រទេសកម្ពុជា លោកជំទាវ UIKU Kocaefe (រូបទី៤រាប់ពីស្តាំ) ទស្សនាស្តង់ពិព័រណ៍សូត្រចាម ព្រះរាជបណ្ណាល័យ ហ្លួងម៉ែនៃមជ្ឈមណ្ឌលឯកសារកម្ពុជា។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ពីថ្ងៃទី១៨ ដល់ ថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០២៤ ព្រះរាជបណ្ណាល័យ ហ្លួងម៉ែ បានចូលរួមតាំងបង្ហាញផលិតផល«សូត្រចាម» នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៍កោះពេជ្រ ដែលរៀបចំដោយពិព័រណ៍ពាណិជ្ជកម្មអន្តរជាតិកម្ពុជា។ ផលិតផល «សូត្រចាម» រួមមាន សំពត់ហូល ក្រមា ដែលបានដាក់តាំងបង្ហាញទាំងនេះ ត្រូវបានត្បាញដោយស្ត្រីសហគមន៍ជនជាតិចាម ក្នុងស្រុកកោះសូទិន ខេត្តកំពង់ចាម។

ឯកអគ្គរដ្ឋទូតតួកគីប្រចាំប្រទេសកម្ពុជា លោកជំទាវ UIKU Kocaefe និងឯកអគ្គរដ្ឋទូត



អ្នកស្រី សូ ហ្វារីណា នាយករងមជ្ឈមណ្ឌលឯកសារកម្ពុជា ពាក់ហិចាប់ត្បាញដោយស្ត្រីជនជាតិចាមនៅសហគមន៍តម្បាញស្រុកកោះសូទិន ខេត្តកំពង់ចាម។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ហ្វីលីពីន លោកជំទាវ Flerida Ann Camille P. Mayo បានអញ្ជើញមកទស្សនាការដាក់បង្ហាញផលិតផល «សូត្រចាម» ទាំងនេះ។ លោកស្រីឯកអគ្គរដ្ឋទូតទាំងពីររូប បានសម្តែងការចាប់អារម្មណ៍ និងគាំទ្រដល់ស្នាដៃផលិតផល«សូត្រចាម»។

លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា បានលើកឡើងថា៖ នេះគ្រាន់តែជាជំហានដំបូងឆ្ពោះទៅមុខក្នុងការផ្សព្វផ្សាយផលិតផលសូត្រចាម ធ្វើដោយដៃដ៏វិសេសទាំងនេះ ដែលមិនត្រឹមតែជាក្រណាត់ដ៏ស្រស់ស្អាតប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងឆ្លុះបញ្ចាំងពីការរចនាដែលបានបន្សល់ទុកជាច្រើនជំនាន់ (ត្រឡប់ទៅដើមសតវត្សរ៍ទី២០ និងទំនងជាយូរលង់ជាងនេះ)។ ផលិតផលសំពត់ហូល និងក្រមានេះគឺជាមធ្យោបាយដ៏អស្ចារ្យបំផុត ដើម្បីជួយលើកស្ទួយក្រុមគ្រួសារ និងសហគមន៍របស់គាត់ និងធានាបាននូវវិធីសាស្ត្រនៃការតម្បាញសូត្រចាមដ៏ប្រណិតនេះឱ្យមាននិរន្តរភាពសម្រាប់មនុស្សជំនាន់ក្រោយៗ។ គម្រោងសូត្រចាមគឺជាឧទាហរណ៍មួយនៃការអភិរក្សបេតិកភណ្ឌវប្បធម៌ ក៏ដូចជាគម្រោងសហគ្រាសសង្គម។

នៅក្រោមរបបខ្មែរក្រហម ប្រទេសកម្ពុជាបានទទួលរងនូវអំពើឧក្រិដ្ឋកម្មសង្គ្រាម ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងអំពើប្រល័យពូជសាសន៍ ប៉ុន្តែមិនត្រឹមតែការប្រល័យពូជសាសន៍មនុស្សប៉ុណ្ណោះទេ ក៏មានការប្រល័យពូជសាសន៍វប្បធម៌ថែមទៀតផង ដែលរបៀបរស់នៅរបស់ប្រជាជនកម្ពុជា បានឆ្លុះបញ្ចាំងនៅក្នុងបេតិកភណ្ឌវប្បធម៌មួយចំនួនត្រូវបានកំណត់គោលដៅ និង ស្ទើរតែត្រូវបានបំផ្លាញ។ សិល្បៈនៃការត្បាញសូត្រចាម គឺជាឧទាហរណ៍មួយនៃអត្តសញ្ញាណជនជាតិចាម ដើម្បីជួយអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមមួយផ្នែក ហើយគម្រោងនេះ បានឆ្លុះបញ្ចាំងនៅក្នុងក្រណាត់សូត្រទាំងនេះ ធានាថាសិល្បៈជំនាញបច្ចេកទេស និងប្រវត្តិសាស្ត្រនៅពីក្រោយខស្សាហកម្មនេះមិនត្រូវបានបាត់បង់ ប៉ុន្តែត្រូវបានបង្កើតឡើងឡើងវិញ សម្រាប់មនុស្សជំនាន់ក្រោយ។



ភ្ញៀវ(រូបខាងស្តាំ) ទស្សនាសូត្រចាម ព្រះរាជបណ្ណាល័យ ហ្វូងម៉ៃនៃមជ្ឈមណ្ឌលឯកសារកម្ពុជា។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



ឯកអគ្គរដ្ឋទូតតួកគី ប្រចាំប្រទេសកម្ពុជា លោកជំទាវ UIKU Kocaefe (រូបទី៤រាប់ពីស្ដាំ) ទស្សនាស្ដង់ពិព័រណ៍សូត្រចាម ព្រះរាជបណ្ណាល័យ ហ្វូងម៉ៃនៃមជ្ឈមណ្ឌលឯកសារកម្ពុជា។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



ភ្ញៀវទស្សនាស្ដង់ពិព័រណ៍សូត្រចាម ព្រះរាជបណ្ណាល័យ ហ្វូងម៉ៃនៃមជ្ឈមណ្ឌលឯកសារកម្ពុជា។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

គួររំឭកផងដែរគម្រោង «សូត្រចាម» ឬ «ពណ៌នៃការចងចាំ» ត្រូវបានបង្កើតឡើងដោយមជ្ឈមណ្ឌលឯកសារកម្ពុជា នៅក្នុងឆ្នាំ២០២១ ដែលគាំទ្រផ្នែកហិរញ្ញវត្ថុដោយ ទីភ្នាក់ងារសហប្រតិបត្តិការ និងសម្របសម្រួលរបស់ប្រទេសតួកគី(TIKA) តាមរយៈស្ថានទូតតួកគីប្រចាំកម្ពុជា។ គោលបំណងនៃគម្រោងនេះគឺដើម្បីថែរក្សាស្នាដៃត្បាញសូត្រ ការប្រើប្រាស់ពណ៌ និងគោម តាមរយៈការចងចាំរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងអាចបង្កើតប្រាក់ចំណូលសម្រាប់សហគមន៍។ គោលដៅគម្រោងសូត្រចាមនេះ គឺធ្វើយ៉ាងណាឱ្យមានការរំឭកឡើងវិញ និងទទួលស្គាល់អំពីស្នាដៃតម្បាញនេះ ទាំងក្នុង និងក្រៅប្រទេស។ បន្ទាប់ពីប្រទេសកម្ពុជាត្រូវបានបំផ្លិចបំផ្លាញដោយរបបខ្មែរក្រហម សហគមន៍ចាមបានចាប់ផ្ដើមស្ដារឡើងវិញនៅឆ្នាំ១៩៧៩។ ជនជាតិចាមបានរំឭកឡើងវិញនូវការចងចាំក្នុងរបបខ្មែរក្រហម ក៏ដូចជា សិល្បៈ និងសិប្បកម្មតម្បាញសូត្ររបស់ខ្លួនមុនរបបខ្មែរក្រហមដែរ។ ប៉ុន្តែគួរឱ្យសោកស្ដាយដែលអ្នកត្បាញសូត្រជនជាតិចាមតិចតួចប៉ុណ្ណោះដែលនៅរស់រានមានជីវិតពីរបបខ្មែរក្រហម ហើយសូត្រចាមទៀតសោតក៏នៅសេសសល់តិចតួចបំផុតដែរ។

# អតីតនារីពេទ្យប្រចាំតំបន់ក្រចេះ (៥០៥)

**ឡាំ ស្រីនីត**

នៅក្នុងរបបខ្មែរក្រហម (១៩៧៥-១៩៧៩) គីម ឡៃ គឺជានារីពេទ្យប្រចាំតំបន់ក្រចេះ (៥០៥)។ គីម ឡៃ មានតួនាទីជាអ្នកពិនិត្យជំងឺផ្នែកទូទៅ និងជាឆ្មបសម្រាលកូនជូនប្រជាជននាសម័យខ្មែរក្រហម។ គីម ឡៃ បានរៀបរាប់អំពីរឿងរ៉ាវដែលខ្លួនធ្លាប់បានឆ្លងកាត់ នឹងបទពិសោធន៍ជានារីពេទ្យដូចតទៅ។

គីម ឡៃ ភេទស្រី អាយុ៦៦ឆ្នាំ ប្រកបរបរធ្វើចម្ការ មានស្រុកកំណើតស្ថិតនៅក្នុងភូមិថ្មក្រែ ឃុំថ្មក្រែ ស្រុកក្រចេះ ខេត្តក្រចេះ បច្ចុប្បន្ននេះ ឡៃ រស់នៅភូមិប្រម៉ោយ ឃុំប្រម៉ោយ ស្រុកវាលវែង ខេត្តពោធិ៍សាត់។ មានឪពុកឈ្មោះ គង់ គីម ចំណែកម្ដាយឈ្មោះ ប៉ាន់ សាមីន មានបងប្អូនចំនួន២នាក់ នៅក្នុងនោះមានស្រីម្នាក់។ ប្ដីរបស់ ឡៃ ឈ្មោះ ជ័យ សារី អាយុ៦៩ឆ្នាំ មានកូនចំនួន៥នាក់ នៅក្នុងនោះមានស្រីចំនួន២នាក់។

វ័យកុមារ ឡៃ រស់នៅជាមួយឪពុកម្ដាយនៅក្នុងខេត្តក្រចេះ គ្រួសារប្រកបរបរធ្វើស្រែចម្ការដើម្បីចិញ្ចឹមជីវិត។ ឡៃ បានរៀនសូត្រត្រឹមថ្នាក់ទី១០ ប៉ុណ្ណោះកាលពីសង្គមចាស់ ស្មើនឹងថ្នាក់ទី៣នាពេលបច្ចុប្បន្ននេះនៅសាលាភូមិថ្មក្រែ។ នៅឆ្នាំ១៩៦៩ ឡៃ ឈប់រៀន និងត្រឡប់មកជួយកិច្ចការងារផ្ទះជាមួយឪពុកម្ដាយវិញ។

នៅក្នុងឆ្នាំ១៩៧០ សេនាប្រមុខ លន់ នល់ បានធ្វើរដ្ឋប្រហារទម្លាក់សម្ដេចព្រះ នរោត្តម សីហនុ ស្របពេលនោះ ឡៃ មានអាយុ១២ឆ្នាំ ត្រូវបានកងទ័ពខ្មែរក្រហមជ្រើសរើសចូលក្រុមសហគមន៍នារី។ ឡៃ ត្រូវបានឃ្លាតឆ្ងាយពីគ្រួសារ ទៅរស់នៅតាមសមាគមន៍នារីក្មេងៗ។ នៅក្នុងឆ្នាំ១៩៧៣



គីម ឡៃ អាយុ៦៦ឆ្នាំ សព្វថ្ងៃរស់នៅភូមិប្រម៉ោយ ឃុំប្រម៉ោយ ស្រុកវាលវែង ខេត្តពោធិ៍សាត់។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ឡៃ មានអាយុ១៥ឆ្នាំ ខ្មែរក្រហមបានផ្លាស់ឱ្យ ឡៃ ចូលក្នុងក្រុមអង្គភាពស្រុកនៅក្នុងខេត្តក្រចេះ។ នៅក្នុងអង្គភាពស្រុកខ្មែរក្រហមបានប្រើ ឡៃ ធ្វើស្រែប្រាំងនៅភូមិអូរឫស្សី ខេត្តក្រចេះ។ ក្រោយមកក៏មានការជ្រើសរើសចូលជាសមាជិកពេទ្យតំបន់ ឡៃ បានផ្លាស់ចូលជាសមាជិកអង្គភាពពេទ្យតំបន់៥០៥ (ខេត្តក្រចេះ)។ ចូលដំបូងខ្មែរក្រហមបានឱ្យ ឡៃ ទៅសិក្សារៀនសូត្រវិជ្ជាជីវៈផ្នែកពេទ្យបន្ថែមនៅរាជធានីភ្នំពេញ បានរៀនត្រឹមពេទ្យមធ្យមទី១ប៉ុណ្ណោះដែលមានរយៈពេល២ខែ សិក្សាអំពី

ការពិនិត្យមើលចង្វាក់បេះដូង ពិនិត្យមើលសួត សិក្សាអំពីរបៀបសម្រាលកូន រៀនអំពីទ្រឹស្តីបណ្តើរ និងអនុវត្តន៍បណ្តើរ។

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានវាយបែកទីក្រុងភ្នំពេញ ប្រជាជនបានអបអរសាទរនឹងជ័យរបស់ ប៉ុល ពត យ៉ាងខ្លាំងដែលបានរំដោះប្រជាជនចេញពីភ្លើងសង្គ្រាម ប្រជាជនទាំងអស់មានអារម្មណ៍សប្បាយរីករាយ ព្រោះគិតថាខ្លួនរួចផុតពីរសង្គ្រាមហើយ ប៉ុន្តែការសប្បាយរបស់ប្រជាជនមិនបានប៉ុន្មាន ក៏ត្រូវបានកងទ័ពខ្មែរក្រហមជម្លៀសប្រជាជនដែលរស់នៅទីក្រុងទាំងអស់ ឱ្យទៅរស់នៅតាមជនបទ ហើយកងទ័ពរបស់ខ្មែរក្រហមបានប្រាប់ហេតុផលនៃការជម្លៀសចេញដល់ប្រជាជនថា ខ្លាចទាហានរបស់សហរដ្ឋអាមេរិកមកទម្លាក់គ្រាប់បែកទៀត និងខ្លាចប្រជាជនរស់នៅគ្មានអាហារហូបចុកគ្រប់គ្រាន់។ តែការពិតខ្មែរក្រហមជម្លៀសប្រជាជនឱ្យទៅរស់នៅតាមជនបទនិងធ្វើការងាររួមគ្នា ហូបរួបគ្នា ស្នាក់នៅកន្លែងរួមគ្នា មិនមានអ្វីមួយដែលជារបស់របរផ្ទាល់ខ្លួនទៀតឡើយ។ ចំណែក ឡៃ ខ្មែរក្រហមបានចាត់តាំងឱ្យធ្វើជាពេទ្យប្រចាំនៅតំបន់៥០៥ដដែល សម្រាប់អាហារហូបចុកដំបូងមិនសូវជាខ្វះខាត ប៉ុន្មានទេមានហូបគ្រប់គ្រាន់ ក្នុងមួយថ្ងៃទទួលបានរបបអាហារ៣ពេល។ បន្ទាប់មក ឡៃ បាន ប្តូរពីពេទ្យព្យាបាលជំងឺទូទៅ មកជាពេទ្យឆ្មបវិញ រៀងរាល់ព្រឹក ឡៃ និងគ្រូពេទ្យផ្សេងទៀតបានបែងចែកការងារជាពីរក្រុម មានក្រុមអ្នកសម្អាតនៅខាងក្នុងមន្ទីរពេទ្យ និងមានអ្នកស្រោចទឹកបន្លែ។ នៅប្រហែលម៉ោង៧ព្រឹក ឡៃ ត្រូវចាប់ផ្តើមស្ងោរសារាំង ដើម្បីកុំឱ្យឆ្លងមេរោគដល់អ្នកជំងឺ ពីព្រោះពេទ្យសម័យខ្មែរក្រហមគ្មានសម្ភារប្រើប្រាស់គ្រប់គ្រាន់ទេ។ ករណីមានអ្នកជំងឺធ្ងន់ធ្ងរត្រូវបញ្ជូនទៅព្យាបាលនៅរាជធានីភ្នំពេញ បញ្ជូនទៅតាមរយៈកាណូត កប៉ាល់ មិនអាចធ្វើដំណើរតាមផ្លូវគោកបានទេ ពីព្រោះនៅក្នុងសម័យសាធារណរដ្ឋខ្មែរ សង្គ្រាមបានធ្វើឱ្យខូចខាតផ្លូវថ្នល់ ស្ពាន យ៉ាងច្រើន ទើបមិនអាចបញ្ជូនអ្នកជំងឺតាមផ្លូវគោកបាន។ សម្រាប់សម្លៀកបំពាក់វិញត្រូវពាក់អាវពណ៌ស ខោពណ៌ខ្មៅ បើមិនស្លៀកពាក់តាមហ្នឹង គឺខុសនឹងក្បួនវិន័យរបស់ពេទ្យ។ ក្រុមគ្រូពេទ្យដែលមានចំណេះដឹងជ្រៅជ្រះ គឺត្រូវបានខ្មែរក្រហមប្រមូលយកទៅធ្វើពលកម្មអស់ហើយ ទុកតែអ្នកដែលមិនមានវិជ្ជាជីវៈច្បាស់ឱ្យព្យាបាលជំងឺដល់ប្រជាជន។ ចំណែកប្រធានពេទ្យគឺត្រូវខ្មែរក្រហមយកទៅដាក់នៅគុក ឬក៏យកទៅកសាង( សម្លាប់) ជាដើម។

នៅក្នុងឆ្នាំ១៩៧៦-១៩៧៨ ខ្មែរក្រហមបានឱ្យពេទ្យមួយចំនួនចុះទៅតាមសហករណ៍ ដើម្បីរកបន្លែយកមកផ្គត់ផ្គង់នៅក្នុងអគ្គភាពមន្ទីរពេទ្យ និងអ្នកជំងឺដែលសម្រាកនៅក្នុងមន្ទីរពេទ្យ រាល់ពេលចុះទៅម្តងៗ ឡៃ មានអារម្មណ៍អាណិតដល់ប្រជាជនជាខ្លាំង មានសភាពស្លេកខ្លាំង គ្មានកម្លាំងនៅក្នុងខ្លួនស្គមស្គាំង។ ប្រជជនខិតខំធ្វើការងារខ្លាំងណាស់មិនហ៊ានឈប់សម្រាកទេ ហើយក្នុងមួយឆ្នាំៗប្រមូលផលស្រូវទទួលបានរាប់តោន តែមិនឱ្យប្រជាជនហូបគ្រប់គ្រាន់ឡើយ។ ចំណែកម្តាយឪពុក ឡៃ ត្រូវបានខ្មែរក្រហមចាត់ឱ្យដាំបាយធ្វើម្ហូបនៅក្នុងមន្ទីកុមារ រីឯជីដូនចាស់របស់ ឡៃ ត្រូវនៅផ្ទះម្នាក់ឯងគ្មាននរណាមើលថែ គាត់ចាស់ជរាហើយថែមទាំងវង្វេងទៀត ខ្មែរក្រហមមិនប្រើឱ្យគាត់ធ្វើការងារអ្វីទេ ពីព្រោះគាត់ចាស់ ចំណែករបបអាហារជីដូនរបស់ ឡៃ មិនដែលទទួលបានទាល់តែសោះ ពីព្រោះខ្មែរក្រហមបានប្រាប់ថាអ្នកដែលធ្វើការងារមិនកើតគឺមិនទទួលបានរបបអាហារឡើយ ម្តាយរបស់ ឡៃ តែងតែលួចយកបាយឱ្យហូបជាប្រចាំ។

នៅក្នុងឆ្នាំ១៩៧៩ នៅពេលកងទ័ពរបស់វៀតណាមចូលមករំដោះខេត្តក្រចេះ ឡៃ បានរត់ទៅរស់នៅលើភ្នំជីជាមួយប្រជាជនជាច្រើននាក់។ នៅពេលដែលកងទ័ពរបស់វៀតណាមវាយចូលស៊ើរគ្រប់ជ្រុង ខ្មែរក្រហមបានត្រូវការកម្លាំងពេទ្យជាច្រើននាក់ សម្រាប់ជួយព្យាបាលកងទ័ពដែល



កសិករកំពុងដាំដំណាំនៅចម្ការ ក្នុងស្រុកវាលវែង ខេត្តពោធិ៍សាត់។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ត្រូវរបួស។ ស្របពេលកងទ័ពវៀតចូលមកកាន់តែខ្លាំង ពេទ្យមួយចំនួនបាននាំគ្នាទៅកាន់ស្រុកភូមិកំណើត ព្រមទាំងបបួល ឡៃ រត់ទៅជាមួយគ្នាផងដែរ។ ប៉ុន្តែ ឡៃ មិនហ៊ានពីព្រោះខ្លាចកងទ័ពវៀតណាមចាប់បានយកទៅអាកសម្លាប់ចោល។ មុនពេលកងទ័ពវៀតណាមចូលមកដល់ខេត្តក្រចេះ ខ្មែរក្រហមបានប្រកាសប្រាប់ប្រជាជនថា កងទ័ពវៀតណាមចូលមកនឹងចាប់ប្រជាជនយកទៅអាកសម្លាប់ចោល ឡៃ បានឮដូច្នេះមិនហ៊ានត្រឡប់ចូលស្រុកវិញឡើយ។ នៅចុងឆ្នាំ១៩៧៩ កងកម្លាំងរបស់ខ្មែរក្រហមបានវាយប្រយុទ្ធជាមួយកងទ័ពវៀតណាមនៅលើភ្នំដងរែក។ ឡៃ និងសមាជិកពេទ្យចំនួន៤០០នាក់បានឡើងទៅជាមួយ ដើម្បីព្យាបាលកងទ័ពដែលរងរបួសក្នុងសមរភូមិកងពល៦១២ គ្រប់គ្រងដោយ តាឈាន និង តាហឿន។ ឡៃ រស់នៅលើភ្នំដងរែកគ្មានអាហារហូបចុកទេ មានតែដកមើមក្ដួច មើមដំឡូងព្រៃយកមកហូបជំនួសបាយតែប៉ុណ្ណោះ។ ក្រុមពេទ្យនារីៗចំនួន៦នាក់បានស្លាប់ដោយសារហូបបបរត្រាវជូរ ។ នៅក្នុងឆ្នាំ១៩៨០ កងពល៦១២ វាយជាមួយកងទ័ពវៀតណាមតាមព្រំដែននៅម្ដុំភ្នំខ្មោចស្រុកវាលវែង ចំនួនក្រុមគ្រូពេទ្យដែលមកជាមួយកងទ័ពកាន់តែខ្សត់ខ្សោយទៅៗ គ្មានអាហារហូបចុក ស្លាប់អស់ជាច្រើននាក់។ នៅក្នុងឆ្នាំ១៩៨២ ក្រុមពេទ្យនារីបានធ្វើដំណើរទៅកាន់តំបន់អន្លង់វែង ខេត្តបន្ទាយមានជ័យ ក្រោយពេលទៅដល់ទីនោះទើបមានបាយហូបគ្រប់គ្រាន់។

នៅក្នុងឆ្នាំ១៩៨៣ ឡៃ ត្រូវបានខ្មែរក្រហមជម្រុញឱ្យមានគ្រួសារ ប៉ុន្តែមិនមានការបង្ខិតបង្ខំអ្វីទេស្ម័គ្រចិត្តរៀបការដោយខ្លួនឯង រៀបការមានចំនួន៥គូ ចាស់ៗគាត់រៀបចំសែនព្រេន ដើម្បីឱ្យជីដូនជីតាបានដឹងឮ ។ ក្រោយពេលរៀបការរួច ប្ដីរបស់ ឡៃ ត្រូវបានចាត់តាំងឱ្យវាយជាមួយកងទ័ពវៀតណាមបន្តទៀតទុកឱ្យ ឡៃ រស់នៅមានផ្ទៃពោះម្នាក់ឯង ក្រោយពេលសម្រាលកូនបានរយៈពេល៣ខែទើបជួបជាមួយប្ដីមកលេងផ្ទះបានរយៈពេលមួយសប្ដាហ៍ក៏ត្រឡប់ចូលសមរភូមិវិញ។ រយៈពេលជាង២ឆ្នាំក្រោយមក ទើបប្ដី ឡៃ ត្រឡប់មកលេងប្រពន្ធកូនម្ដងទៀត។ ពេលកងទ័ពរបស់វៀតណាមវាយកាន់តែខ្លាំង ឡៃ បាននាំកូនទៅរស់នៅព្រំដែនថៃនៅក្នុងជំរំសាយខេ លុះដល់ប្រទេសកម្ពុជាមានសមាហរណកម្មទើប ឡៃ ត្រឡប់ចូលមករស់នៅក្នុងប្រទេសកម្ពុជាវិញ។ នៅឆ្នាំ១៩៩៨ ឡៃ បានផ្លាស់មករស់នៅក្នុងភូមិប្រម៉ោយ ស្រុកវាលវែង។ រស់នៅក្នុងភូមិប្រម៉ោយដំបូងពោរពេញទៅដោយព្រៃ និងមិនគ្មានប្រជាជនរស់នៅច្រើនទេ។ ឡៃ និងក្រុមគ្រួសារប្រកបរបរធ្វើចម្ការហូតមកដល់បច្ចុប្បន្ននេះ។

រឿងរ៉ាវទាំងអស់នេះហើយដែលធ្វើឱ្យ ឡៃ ចងចាំមិនភ្លេច ហើយថែមទាំងចែករំលែកប្រាប់ដល់កូនចៅជំនាន់ក្រោយឱ្យខិតខំរៀនសូត្រនិងជួយទប់ស្កាត់កុំឱ្យរបបមួយនេះវិលមកវិញម្ដងទៀត។

# មជ្ឈមណ្ឌលឯកសារកម្ពុជាចូលរួមដាក់តាំងរុក្ខជាតិលម្អ និងអាចប្រើប្រាស់ជាឱសថ នៅក្នុងកម្មវិធីពិព័រណ៍ស្អាត

***មីន សាណាស់***




មជ្ឈមណ្ឌលឯកសារកម្ពុជាចូលរួមដាក់តាំងរុក្ខជាតិលម្អ និងអាចប្រើប្រាស់ជាឱសថនៅក្នុងកម្មវិធីពិព័រណ៍ស្អាត នៅថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២៤។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ចាប់ពីថ្ងៃទី២៩ ខែវិច្ឆិកា ដល់ថ្ងៃទី១ ខែធ្នូ ឆ្នាំ២០២៤ មជ្ឈមណ្ឌលឯកសារកម្ពុជាបានយករុក្ខជាតិលម្អ និងបន្សុទ្ធខ្យល់ក្នុងបរិយាកាស ហើយអាចប្រើប្រាស់ជាឱសថ ទៅដាក់តាំងបង្ហាញក្នុងកម្មវិធីពិព័រណ៍ដែលមានឈ្មោះថា «ពិព័រណ៍ស្អាត» រៀបចំឡើងដោយ ស្អាត និង សហគមន៍ផ្ទះចាស់ នៅឯមជ្ឈមណ្ឌលបៃតង Connecxion (កោះពេជ្រ)។

កម្មវិធី «ពិព័រណ៍ស្អាត» នេះបង្ហាញអំពីអាជីវកម្មប្រកបដោយនិរន្តរភាព គំនិតផ្តួចផ្តើមបៃតង រុក្ខជាតិលម្អ ស្ថាបត្យកម្ម ផលិតផលច្នៃប្រឌិត និងអាជីវកម្មក្នុងស្រុកដែលគិតគូរពីបរិស្ថានៗ ក្រៅពីនេះ កម្មវិធីបានប្រមូលផ្តុំសហគ្រិនដែលជាអ្នកដឹកនាំ អ្នកជំនាញដែលដើរតួនាទីយ៉ាងសំខាន់ក្នុងការចែករំលែកចំណេះដឹងអំពីអាជីវកម្ម និងរុក្ខជាតិ។

មជ្ឈមណ្ឌលឯកសារកម្ពុជា បានធ្វើការសិក្សាស្រាវជ្រាវអំពីរុក្ខជាតិជាច្រើនឆ្នាំមកហើយ ដែលសង្ឃឹមថារុក្ខជាតិមួយចំនួនអាចប្រើប្រាស់ជាឱសថសម្រាប់ជួយដល់សុខភាពបែបលក្ខណៈគ្រួសារ



ចំពោះអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។ មជ្ឈមណ្ឌលឯកសារកម្ពុជា បានបង្កើតបន្ទប់ពិសោធន៍រុក្ខជាតិមួយ ដែលសិក្សាលើរុក្ខជាតិកម្រនៅក្នុងប្រទេសកម្ពុជា និងរុក្ខជាតិជាច្រើនប្រភេទទៀតមកពីបណ្តាប្រទេសដទៃ ដើម្បីបន្តុំពូជ និងអាចប្រើប្រាស់ជាឱសថ។ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមអាចប្រើប្រាស់រុក្ខជាតិទាំងនេះដើម្បីឱ្យមានសុខភាពល្អប្រសើរ។ រុក្ខជាតិទាំងនេះទៀតសោត អាចជួយបន្សុទ្ធបរិយាយកាស បង្កើតជាសោភ័ណភាព និងជួយធ្វើឱ្យបរិយាកាសស្រស់ស្រាយ ដែលបច្ចុប្បន្នមានការប្រែប្រួលអាកាសធាតុរហូតដល់ការបាត់បង់ជីវៈចម្រុះ ការបំពុលបរិស្ថាន ហើយដែលមនុស្សប្រមាណ៤០ភាគរយនៅលើពិភពលោកកំពុងទទួលរងផលប៉ះពាល់។

ការសិក្សាស្រាវជ្រាវអំពីរុក្ខជាតិលម្អ និងអាចប្រើប្រាស់ជាឱសថនេះ ស្រាវជ្រាវដោយនិស្សិតស្ម័គ្រចិត្តកម្ពុជា (CamboCorps) ចំនួនពីររូបគឺ ជ័យ វីរៈ និង អាង សុខហេង។ រុក្ខជាតិដែលមជ្ឈមណ្ឌលឯកសារកម្ពុជាបានបន្តុំពូជ និងដាំដុះទាំងនេះ ក៏ធ្លាប់បានដាក់តាំងបង្ហាញនៅក្នុងពិព័រណ៍រុក្ខជាតិលម្អ និង កម្រ នៅប្រទេសវៀតណាម ប្រទេសថៃ និងប្រទេសសិង្ហបុរី រួចមកហើយដែរ។

ជ័យ វីរៈ និង អាង សុខហេង គឺជានិស្សិតមកពីសាកលវិទ្យាល័យអាមេរិកាំងភ្នំពេញ ដែលគ្រប់គ្រងលើការស្រាវជ្រាវរុក្ខជាតិ និងបន្ទប់ពិសោធន៍ នៅមជ្ឈមណ្ឌលឯកសារកម្ពុជាបានឱ្យដឹងថា៖ រុក្ខជាតិដែលកម្រ នឹងប្រឈមមុខក្នុងការបាត់បង់នៅថ្ងៃអនាគត គឺត្រូវការដង្វាំ និងបន្តុំពូជជាថ្មីឱ្យបានច្រើនដើម្បីចូលរួមចំណែកក្នុងការថែរក្សាពូជកម្រ។ បន្ទាប់ពីដង្វាំរុក្ខជាតិថ្មីៗ និងកម្ររួចរាល់ មជ្ឈមណ្ឌលឯកសារកម្ពុជាគ្រោងយករុក្ខជាតិទាំងនេះទៅដាំនៅតាមសាខាមជ្ឈមណ្ឌលឯកសារកម្ពុជារបស់ខ្លួននៅតាមបណ្តាខេត្តមួយចំនួនទៀត។






មជ្ឈមណ្ឌលឯកសារកម្ពុជាចូលរួមដាក់តាំងរុក្ខជាតិលម្អ និងអាចប្រើប្រាស់ជាឱសថនៅក្នុងកម្មវិធីពិព័រណ៍ស្អាត នៅថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២៤។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)








មជ្ឈមណ្ឌលឯកសារកម្ពុជាចូលរួមដាក់តាំងរុក្ខជាតិលម្អ និងអាចប្រើប្រាស់ជាឱសថនៅក្នុងកម្មវិធីពិព័រណ៍ស្អាត នៅថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២៤។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)





# ស្នង នឿន ៖ ខ្មែរសុរិនជម្លៀសទៅខេត្តស្ទឹងត្រែង

ស្រេង លីដា

ខ្ញុំឈ្មោះ ស្នង នឿន ភេទស្រី អាយុ៨០ឆ្នាំ មានបងប្អូនចំនួន២នាក់ ហើយខ្ញុំគឺជាកូនទី២។ ខ្ញុំរៀបការនៅឆ្នាំ១៩៦២ ជាមួយប្តីខ្ញុំឈ្មោះ ភួយ អូន ហើយមានកូនចំនួន២នាក់ ប្រុសម្នាក់និងស្រីម្នាក់ គឺឈ្មោះ ភួយ មិត និងឈ្មោះ ភួយ ឆេន។ ចំណែកម្តាយខ្ញុំឈ្មោះ ឈុំ សំណើន និងឪពុកឈ្មោះ ម៉ែស្នង ចន្ទ្រយ។



ស្នង នឿន អាយុ៨០ឆ្នាំ សព្វថ្ងៃរស់នៅឃុំអូរស្វាយ ស្រុកបុរីអូរស្វាយ-សែនជ័យ ខេត្តស្ទឹងត្រែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

## បុណ្យបំពាក់ស័ក្តិ

កាលពីមុនស្រុកកំណើតខ្ញុំនៅសុរិន្ទ ប៉ុន្តែខ្ញុំមកប្រកបមុខរបរស៊ីឈ្នួលកាប់ខសដុតធ្វើធ្យូងនៅអារញ្ញក៏មានការជ្រើសរើសធ្វើទាហានខ្មែរសេរីនៅអូរជ្រៅ ខាងទឹកដីខ្មែរ។ ប្តីខ្ញុំក៏ស្ម័គ្រចិត្តចូលធ្វើទាហាន ខ្មែរសេរីហើយបានទទួលប្រាក់ខែសម្រាប់ផ្គត់ផ្គង់ក្រុមគ្រួសារ។ ចំណែកខ្ញុំប្រកបរបររកស៊ីឈ្នួលកាប់ខសដុតធ្វើធ្យូងលក់ឱ្យគេ និងវិចនំអន្សមលក់។ នៅពេលនោះគេមានចែកដីឱ្យក្រុមគ្រួសារខ្ញុំសម្រាប់ធ្វើកសិកម្មដាំ ស្រូវនិងពោត។ យើងរស់នៅសមរម្យ។ ថ្ងៃមួយមានអ្នកភូមិហៅទៅលេងបុណ្យបំពាក់ស័ក្តិនៅភ្នំវិល័យ មានគោយន្តមកដឹកពួកខ្ញុំចំនួន១០០គ្រឿង។ ខ្ញុំចាំបានថាពេលនោះខែពិសាខមេឃកំពុងតែមានភ្លៀងរលឹម ទាំងក្មេងចាស់ជិះលើគោយន្តចង្អៀតក្នុងនោះសុទ្ធសឹងតែជាជនជាតិថៃ។ អ្នកមកយកពួកយើងប្រាប់ថាទៅមើលពិធីបំពាក់ស័ក្តិ តែតាមការពិតយកពួកខ្ញុំមកខ្មែរសោះ។ ពេលមកដល់ស្វាយស៊ីសុផុន មិនទាន់ដឹងថាអ្នកណាយកពួកខ្ញុំមកទីនេះទេ។ ពេលមកដល់អ្នកនៅទីនោះរៀបចំដាំបាយទឹកទទួលពួកខ្ញុំ។ មានយន្តហោះ ហោះខ្វាត់ខ្វែងពីលើអាកាសដឹកត្រីកញ្ចុះ ត្រីងៀត មកឱ្យពួកយើងហូប។ ខ្ញុំក៏ចាប់ផ្តើមយំតែម្តងព្រោះមកមានទាំងម្តាយខ្ញុំ ឪពុក និងកូនខ្ញុំ។ ខ្ញុំចេះតែភ័យខ្លាចក្នុងចិត្តមិនដឹងថាយកពួកយើងទៅសម្លាប់ចោលនៅឯណាទេ។ ពេលមកដល់ស្វាយស៊ីសុផុនមានមនុស្សយ៉ាងច្រើនកោះករគេឱ្យនៅបន្ទាយ ទាំងអស់គ្នា ខុះតែបីនាក់គ្រប់ចំនួន១០០០នាក់រួម ទាំងក្មេងនិងមនុស្សចាស់។ គេឱ្យរស់នៅស្វាយស៊ីសុផុន រយៈពេលមួយខែក៏ខ្ញុំនៅតែ

មិនទាន់ដឹងថាអ្នកណាឱ្យពួកយើងមកនៅទីនេះដែរ។ ក្រោយមកប្តីខ្ញុំក៏មកតាមខ្ញុំហើយយើងជុំគ្នានៅស្វាយស៊ីសុផុន។ ខ្ញុំយំអត់បាយអត់ទឹកមុនពេលប្តីខ្ញុំមកដល់ដោយសារតែខ្លាចគេយកទៅសម្លាប់ផងនិងពិបាកក្នុងការរស់នៅ មិនចេះនិយាយភាសាខ្មែរទៀត។

នៅស្វាយស៊ីសុផុនបានមួយខែមានអ្នកតូចអ្នកធំ យន្តហោះហោះចុះ ហោះឡើងគេមកមើលពួកខ្ញុំហើយក៏ប្រាប់ពួកខ្ញុំឱ្យផ្លាស់ទៅពោធិ៍ចិនតុងភ្នំពេញ។ ពេលមកដល់ពោធិ៍ចិនតុង គេក៏បានសួរប្តីខ្ញុំថាតើអ្នកឯងចង់ធ្វើអ្វី? ប្តីខ្ញុំឆ្លើយថា «ខ្ញុំធ្វើទាហាន»។ អ្នកណាដែលធ្វើទាហានគេតម្រូវឱ្យទៅរៀននៅខេត្តពោធិ៍សាត់ រយៈពេល៣ខែថែមទៀតមានទាំងប្តីខ្ញុំដែរ។ ក្រោយមកបានរយៈពេល៣ខែគេក៏បានឱ្យស្រីៗដែលជាប្រពន្ធទៅជួបប្តីនៅឯពោធិ៍ចិនតុងភ្នំពេញ។ ពេលនោះទើបខ្ញុំបានឃើញ សម្តេចព្រះនរោត្តម សីហនុ។ សម្តេចព្រះនរោត្តម សីហនុ បានចែកអំណោយសព្វគ្រប់ មានទាំងក្រណាត់សង្គមរាស្ត្រនិយមរបស់របរប្រើប្រាស់ហូបចុកច្រើនណាស់ ព្រមទាំងថវិកាមួយចំនួនធំផងដែលសម្រាប់គ្រួសារនីមួយៗ។

នៅវិមានឯករាជ្យសម្តេចព្រះនរោត្តម សីហនុ ទ្រង់មានព្រះបន្ទូលអរគុណដល់កូនចៅទ្រង់។ ពួកខ្ញុំក៏ស្រែកឡើងថាជយោសម្តេចឪ! ជយោសម្តេចឪ!។ គេនាំខ្ញុំស្រែកបែបហ្នឹង ខ្ញុំចេះតែស្រែកតាមគេទៅព្រោះកាលនោះខ្ញុំមិនទាន់ចេះភាសាខ្មែរទេ។ ដល់ពេលចេញពីទីនោះខ្ញុំក៏បានជិះកប៉ាល់ទាហានអាមេរិន ប្រហែលជាបីជាន់ដោយសារតែវាធ្ងន់ទើបចំណាយពេលយូររហូតដល់ពីរយប់ពីរថ្ងៃពីភ្នំពេញដល់ក្រចេះ។ ខ្ញុំបានឃើញសត្វផ្សោតចេញពីទឹក អ្នកធ្វើដំណើរនាំគ្នាទៅមើល ឡើងផ្អៀងកប៉ាល់អាមេរិនមួយចំហៀង។ ខ្ញុំភ័យណាស់តែមិនមានបញ្ហាអ្វីទេ។ គេហៅក្រុមពួកខ្ញុំថាខ្មែរសេរី។

## ប្តីខ្ញុំត្រូវចាត់តាំងយាមនៅតំបន់អូរស្វាយ

ពេលឈប់នៅក្រចេះគេក៏បែងចែកកម្លាំងទៅប្រចាំការតាមព្រំដែន។ គេហៅប្តីខ្ញុំថា ភួយ អូន ទៅប្រចាំការព្រំដែន ឡាវ ហើយអ្នកផ្សេងទៀតទៅរតនគិរី មណ្ឌលគិរី ក្រចេះ និង ស្ទឹងត្រែង។ អ្នកដែលមកស្ទឹងត្រែងជាមួយប្តីខ្ញុំ អ្នកខ្លះទៅសៀមប៉ាង ខ្លះទៅព្រះរំកិល ហើយខ្ញុំមកប្រចាំនៅអូរស្វាយជាមួយប្តីខ្ញុំ។

ខ្ញុំមកដល់អូរស្វាយក្នុងឆ្នាំ១៩៦៨ ពេលមកដល់អូរស្វាយដំបូងខ្ញុំបានឃើញមាន ទីស្នាក់ការ កន្លែងរាំវង់ ព្រលានយន្តហោះ បន្ទាយទាហាន វត្ត ផ្សារ ស្តូបអនុស្សាវរីយ៍កន្លែងដើមពោធិ៍ មានសួនច្បារផ្ការីកស្គុសស្គាយមើលទៅស្រស់ស្អាតខ្លាំងណាស់។ តែសព្វថ្ងៃកន្លែងមួយចំនួនធំត្រូវបាក់ចូលទន្លេខ្លះ ហើយ នៅសេសសល់តិចតួចប៉ុណ្ណោះ ដូចជា ស្តូបនៅកន្លែងដើមពោធិ៍ និងវត្ត។ ពេលខ្ញុំមកដល់អូរស្វាយនៅក្នុងឆ្នាំដដែល ខ្ញុំមិនបានរស់នៅផ្ទះកាឡូងដែលសម្តេចព្រះនរោត្តម សីហនុ កសាងឱ្យប្រជាជនដូចអ្នកដទៃទេព្រោះគេបានគ្រប់ៗគ្នាទៅហើយ។ ខ្ញុំរស់នៅជាមួយប្តីខ្ញុំនៅបន្ទាយទាហាន។ ការរស់នៅក្នុងបន្ទាយមិនពិបាកប៉ុន្មានទេនៅពេលដែលខ្ញុំអត់អង្ករអត់អំបិល ទៅបើកនៅ (ផូយេ) អស់របស់ប្រើប្រាស់ខ្ញុំទៅយកនៅទីហ្នឹងគេកាត់ប្រាក់ខែប្តីខ្ញុំតាមហ្នឹង។ ខ្ញុំរស់នៅអូរស្វាយបានរយៈពេលពីរឆ្នាំក៏ពួកទាហានវៀតណាមខាងជើងចូលមកពេញភូមិ ពេញស្រុក។ ក្រោយមកក៏មានយន្តហោះទម្លាក់គ្រាប់បែកដែលគិតថាជាទីតាំងដែលទាហានវៀតណាមខាងជើងលាក់ខ្លួន។ ការទម្លាក់នោះធ្វើឱ្យខូចហេដ្ឋារចនាសម្ព័ន្ធផ្សេងៗដែលមាននៅអូរស្វាយគ្មានសេសសល់ទេ មានតែរណ្តៅធំៗបន្សល់ទុកគ្រប់ទីកន្លែងនៅអូរស្វាយ។

ខ្ញុំក៏នៅក្នុងទិដ្ឋភាពនោះដែលនៅពេលយន្តហោះអាមេរិកទម្លាក់គ្រាប់បែក ខ្ញុំនិងក្រុមគ្រួសារនាំគ្នាចូលក្នុងរណ្តៅលេណដ្ឋានមិនហ៊ានចេញមកក្រៅទេ។ ខ្ញុំឮសូរតែសំឡេងផ្ទុះហើយនៅពេលខ្ញុំដាំបាយធ្វើម្ហូបមិនហ៊ានបង្កាត់ភ្លើងឱ្យហុយចេញផ្សែងខ្លាំងទេព្រោះយន្តហោះអាមេរិកកាំងឱ្យតែឃើញផ្សែងនៅ

ទីណា ទម្លាក់គ្រាប់នៅទីនោះៗ ដូច្នេះហើយនៅពេលដាំបាយបរិភោគមួយពេលៗចំណាយពេលរាប់ម៉ោង ទើបឆ្អិនបានហូប។

## ខ្មែរក្រហមចូលមកអូរស្វាយនៅក្នុងឆ្នាំ១៩៧០

បន្ទាប់មកខ្មែរក្រហមបានចូលមកអូរស្វាយក្នុងឆ្នាំ១៩៧០។ នៅពេលខ្មែរក្រហមចូលមកមុនដំបូងបានធ្វើនយោបាយឱ្យយើងជឿជាក់ទាំងអស់។ ខ្មែរក្រហមឱ្យយើងសាមគ្គីគ្នា ហូបបាយល្ងាចរួចនាំគ្នាទៅរាំ គឺគេធ្វើយ៉ាងណាឱ្យយើងជឿទៅលើពួកគេ។ ខ្មែរក្រហមចាប់ផ្ដើមប្រើខ្ញុំនិងអ្នកភូមិផ្សេងទៀតឱ្យបិតចម្រូងសម្រាប់យកទៅដាក់តាមព្រំដែន នៅពេលដែលសត្រូវដើរទាក់ធ្វើឱ្យមុតជើង។ ស្រីៗជាអ្នកបិត ធ្វើរួចហើយខ្មែរក្រហមឱ្យមនុស្សប្រុសជាអ្នកយកទៅដាក់។ បន្ទាប់មកខ្មែរក្រហមចាប់ផ្ដើមឱ្យធ្វើស្រែប្រវាស់ដៃក្រោយមកក៏ចាប់ផ្ដើមរឹតបន្តឹងបន្តិចម្ដងៗ។ ខ្មែរក្រហមចាប់ផ្ដើមឱ្យធ្វើស្រែរួម ហូបចុករួមអ្វីៗគឺរួមទាំងអស់។ ចំណែក កូន និង ប្ដី របស់ខ្ញុំខ្មែរក្រហមមិនឱ្យនៅជុំគ្នាទេ គឺបំបែកចេញពីខ្ញុំទាំងអស់។ កូនខ្ញុំអាយុ៧ឆ្នាំ ៨ឆ្នាំ ខ្មែរក្រហមឱ្យទៅមន្ទីរកុមារ ដើម្បីកាប់ដើមទន្ទ្រានខេត្តធ្វើជី មើលគោ ក្របី រកខុស ដកសំណាបម្នាក់២០កណ្ដាប់។ ដកស្រូវរួចហើយទើបខ្មែរក្រហមឱ្យកូនខ្ញុំទៅមន្ទីរកុមារវិញ។ នៅក្នុងរបបខ្មែរក្រហមប្រហែល២ឆ្នាំ ខ្មែរក្រហមក៏ចាប់ផ្ដើមយកឆ្នាំង ចាន មិនដឹងយកទៅណាអស់ទេ ទុកតែខោអាវពីរសម្រាប់ផ្លាស់ប្ដូរដែលជាកម្មសិទ្ធិសមរម្យ។ ខ្មែរក្រហមក៏បានឱ្យស្បោងមួយតូចក្នុងនោះមានស្លាបព្រាមួយគ្រប់ៗគ្នា។ ចំណែកខ្ញុំខ្មែរក្រហមប្រើឱ្យទៅកាស់គល់ឈើកាប់ឫស្សីព្រៃម្នាក់ឯងមួយថ្ងៃត្រូវកាស់ឱ្យបានមួយគុម្ព ទាំងខ្ញុំមានផ្ទៃពោះ។ ឯការហូបចុកវិញខ្មែរក្រហមផ្ដល់របបអាហារមួយថ្ងៃពីរពេលព្រឹក និង ពេលល្ងាច ដោយហូបម្ដងមួយចានចង្កឹះ។ ខ្ញុំហូបមិនឆ្អែតទេ ពេលដែលខ្ញុំដើរទៅស្រែបេះស្លឹកឈើហូបតាមផ្លូវ។ យូរៗទើបបានត្រីម្ដងយូរៗទៅទើបបានសាច់ម្ដង។ ខ្ញុំបានរស់ដោយសារតែមើមក្ដួច មើមដំឡូង ខ្ញុំឆ្លៀតពេលដែលគេសម្រាកប្រហែលមួយម៉ោងខ្ញុំទៅជីកយកយប់ឡើងចិតត្រាំទឹក ទុកគ្រាន់ហូប ទើបបានឆ្អែត។ ក្រោយមកក៏ជម្លៀសចេញពីអូរស្វាយទៅនៅគុជចំបក់ បានប្រហែលមួយឆ្នាំ ក៏ជម្លៀសខ្ញុំឱ្យទៅនៅញើន។

ប្ដីរបស់ខ្ញុំត្រូវខ្មែរក្រហមរកសម្លាប់តែមិនស្លាប់។ ខ្មែរក្រហមថាឱ្យប្ដីខ្ញុំចាំចម្លងមនុស្សដែលមកពីអូរស្វាយ កាលពេលនោះខ្ញុំនៅកោះញ៉ៅ។ ខ្ញុំគិតក្នុងចិត្តយកប្ដីខ្ញុំទៅសម្លាប់ចោលមិនដឹងមានមនុស្សឯណាឱ្យប្ដីខ្ញុំចាំចម្លងព្រោះកាលនោះអូរស្វាយជម្លៀសប្រជាជនចេញអស់ហើយ។ ដល់ពេលយប់ជ្រៅ ខ្ញុំឮសំឡេងឆ្កែព្រុសឈ្លបមកម្ដងនេះមានគ្នាពីរនាក់មានកាំភ្លើងគ្រប់ដៃហៅប្ដីខ្ញុំថា«អូនៗងើបក្រោកមកនេះបន្តិច» ប្ដីខ្ញុំក៏ស្រវាកាំបិតដែលមាននៅក្បាលដំណេកយកទៅជាមួយដែរ។ ចំណែកខ្ញុំក៏ងើបបីកូនដើរទៅតាមប្ដី ខ្ញុំបាននិយាយជាមួយប្ដីខ្ញុំរួចហើយថាមានរឿងអ្វីក៏មានជាមួយគ្នាដែរ។ ប្ដីខ្ញុំកាន់កាំបិតជាប់នឹងដៃដើរកៀកនិងអ្នកស្ពាយកាំភ្លើង ដល់ពេលដើរទៅឆ្ងាយហើយខ្មែរក្រហមឱ្យប្ដីខ្ញុំនឹងខ្ញុំត្រឡប់មកផ្ទះវិញ។ ដល់ក្រោយមកខ្មែរក្រហមឱ្យប្ដីខ្ញុំចាំចម្លងមនុស្សទៀត។ តែពេលនេះពីអូរស្វាយទៅកោះញ៉ៅម្ដងដោយគេឱ្យកូនទាហានម្នាក់មកហៅប្ដីខ្ញុំទៅអង្គុយចាំគេនៅកន្លែងទីស្នាក់ការអូរស្វាយ ប្ដីខ្ញុំនិយាយថាបើចង់ឱ្យខ្ញុំទៅចម្លងត្រូវឱ្យកាំភ្លើងខ្ញុំមួយដើមមកបានខ្ញុំទៅរួច ហើយគេក៏យល់ព្រមឱ្យកាំភ្លើងប្ដីខ្ញុំមួយដើម ប្ដីខ្ញុំមកត្រើយម្ខាងខាងអូរស្វាយ អង្គុយចាំគេឡើងយប់តែមិនឃើញមានអ្នកណាមក ប្ដីខ្ញុំក៏ត្រឡប់មកផ្ទះវិញទៅ។ ហើយម្ដងទៀតមុនពេលក្រុមគ្រួសារខ្ញុំទៅរស់នៅគុជចំបក់ ខ្មែរក្រហមបានហៅសួរនាំត្រូវនិយាយប្រាប់គេឱ្យត្រង់កុំកុហក ប្ដីខ្ញុំនិយាយតាមត្រង់កាលពីមុនឡើយពួកខ្ញុំនេះជាជនជាតិថៃទេតែមកធ្វើទាហានខ្មែរសេរីនៅតាមព្រំដែន ដល់ពេលមកនៅទីនេះក៏ធ្វើទាហានខ្មែរសេរី។ បន្ទាប់មកខ្មែរក្រហមក៏ជម្លៀសគ្រួសាររបស់ខ្ញុំឱ្យទៅនៅគុជចំបក់ និយាយថា«ផ្ញើគ្រួសារនេះ

ផងពួកគេនេះជាជនជាតិថៃមិនមែនជនជាតិខ្មែរទេ ធ្លាប់ធ្វើជាទាហានខ្មែរសេរី»។ តែជាភ័ព្វសំណាងស្រុកទេសបានរំដោះ។

## ព្រៃដកពរ

ពេលមួយនោះខ្ញុំទៅជីកទំពាំងសម្រាប់សហករណ៍ ដូចមានអ្វីនាំខ្ញុំឱ្យដើរទៅកន្លែងមួយនោះអញ្ចឹង។ ខ្ញុំចេះតែដើរទៅៗស្រាប់តែខ្ញុំបានទៅជួបកន្លែងមួយ ឃើញមានគល់ឫស្សីប្អូនដប់កំណាត់នៅលើខ្ទម។ ខ្ញុំច្បាស់ក្នុងចិត្តណាស់ថាជាគល់ឫស្សីសម្រាប់សម្លាប់មនុស្ស។ រួចហើយខ្ញុំបានឃើញស្រះមានព្រៃដុះពីលើជិតឈើង ខ្ញុំក៏បានមើលទៅក្នុងស្រះទឹកនោះពណ៌ឡើងខៀវ មានឃើញក្បាលមនុស្សទាំងតូចទាំងធំនៅពាសពេញស្រះ។ ពេលនោះហើយទើបខ្ញុំភ្ញាក់ខ្លួនថាមកធ្វើអីកន្លែងនេះ មើលឆ្វេងមើលស្តាំ ខ្ញុំរត់គ្មានឈប់រហូតដល់មន្ទីរវិញ។ មកដល់បច្ចុប្បន្ន ទើបខ្ញុំហ៊ាននិយាយប្រាប់រឿងនេះទៅអ្នកផ្សេង។ នៅកន្លែងខ្ញុំទៅនោះគេហៅថាព្រៃដកពរ ខ្ញុំចាំបានថាដើរទៅភាគឦសាន ប្រហែលជា៥គីឡូពីមន្ទីរដែលខ្ញុំរស់នៅ។

នៅឆ្នាំ១៩៧៩ កងទ័ពវៀតណាមចូលមករំដោះពេលនោះខ្ញុំកំពុងតែនៅលាបលាន។ ខ្ញុំឮស្នូរសំឡេងកាំភ្លើងចាស់ៗថាវៀតណាមចូលមកហើយកំពុងវាយជាមួយខ្មែរក្រហម។ ពីមួយថ្ងៃទៅមួយថ្ងៃកាន់តែឮសំឡេងជិតទៅៗ។ ថ្ងៃមួយនោះមកពីលាបលានវិញ ខ្ញុំឃ្លានបាយណាស់ម៉ោង១១ មនុស្សនៅក្នុងភូមិគេរត់ទៅអស់នៅសល់តែពួកខ្ញុំដែលទៅលាបលាន មានសភាពស្ងាត់ឈឹងជួបតាម្នាក់គាត់ប្រាប់ថាយកអីយកទៅ។ ខ្ញុំក៏កើបអង្ករមួយស្បោងរួចឆ្លងទូកពីញើនមកខាងគុជចំបក់។ ល្ងាចបាត់ទៅហើយខ្ញុំចេះតែនាំគ្នារត់ កូនក៏យំ ណាមួយស្តាយអីវ៉ាន់ណាមួយបីកូនយ៉ាងពិបាកវេទនាចេះតែរត់គ្មានគោលដៅ។ ប្តីក៏ទៅផ្សេងខ្លួនខ្ញុំកាន់តែពិបាក។ ខ្ញុំបានដេកតាមផ្លូវ ព្រឹកឡើងក៏ធ្វើដំណើរទៀតចេះតែទៅតាមគេតាមឯង។ ប្តីខ្ញុំជាអ្នកដឹកជញ្ជូនគាត់ដឹងស្ថានភាពមិនសូវស្រួលគាត់ក៏វិលត្រឡប់មករកខ្ញុំវិញចេះសំណាងល្អជួបនៅសែបឹ។ រួចក៏ធ្វើដំណើរមកអូរស្វាយ ជិះទូកឆ្លងទៅព្រះរំកិលទៅដល់កំពង់សាមី។ គេថាមិនឱ្យធ្វើដំណើរទៅទៀតទេតែឡើងទៅជួប ប៉ុល ពត ហើយគេភ្ជង់កាំភ្លើងឱ្យត្រឡប់មកវិញ។ ទៅកន្លែងណាក៏គេមិនឱ្យទៅដែរ ត្រឡប់ទៅត្រឡប់មក ខ្ញុំឃើញមនុស្សចាស់គេទុកចោល។ ខ្ញុំបានទៅដល់ភូមិប្រា ភូមិណារ៉ុង ខ្ញុំក៏ដួលសន្លប់ដោយសារតែធ្វើដំណើរច្រើនថ្ងៃ។ ខ្ញុំឮប្តីខ្ញុំនិយាយជាមួយកូនថាម្តាយឯងស្លាប់មានតែកាយដីខ្សាច់កប់នៅទីនេះហើយ។ ខ្ញុំសំងំដេកសម្ងឹងទៅឃើញផ្លែផ្តៅក៏ប្រាប់ឱ្យប្តី ខ្ញុំ ទៅបេះឱ្យជញ្ជក់ក្រែងមានកម្លាំងប្តីខ្ញុំក៏បេះឱ្យខ្ញុំ។ ជញ្ជក់មួយសន្ទុះក៏មានកម្លាំងធ្វើដំណើរបន្តទៅមុខទៀត។ ធ្វើដំណើរទៅដល់ភូមិដងផ្ចិតក៏ទៅជួបកងទ័ពវៀតណាមគេយកកូនខ្ញុំមកស្រុកថា ឡាបរិវ៉ាត់មុន។ ខ្ញុំក៏ភ័យម្តងទៀតចេះសំណាងល្អបានជួបកូនវិញ។ ប្តីខ្ញុំទៅប្រយុទ្ធជាមួយកងទ័ពខ្មែរក្រហមជារៀងរាល់ថ្ងៃពេលនោះកងទ័ពខ្មែរក្រហមនៅអុកឡុកនៅឡើយ។

ក្រោយមកខ្ញុំនៅអូរស្វាយក្នុងឆ្នាំ១៩៨០ ខ្ញុំបានជញ្ជូនស្រូវអង្ករដែលធ្វើបានពីញើន ចាប់ក្របីមកធ្វើស្រែចម្ការ រស់នៅលើកោះញ៉ោជួបជុំក្រុមគ្រួសារ។ អ្វីដែលខ្ញុំចងចាំមិនភ្លេចរហូតមកដល់សព្វថ្ងៃនេះគឺខ្មែរក្រហមធ្វើបាបមិនឱ្យហូបឆ្អែត បែកបង បែកប្អូនប្តីទៅដោយប្តីកូនទៅដោយកូនឈឺគ្រុនក៏មិនបានមើល។

កាលពីមុនមុខរបរនេសាទជួយដល់ក្រុមគ្រួសារខ្ញុំទាំងមូល។ គ្រួសារខ្ញុំទៅនេសាទមិនដែលជួបការលំបាកអ្វីទេពីមុនមកស្រួលណាស់ឱ្យតែចេញដំណើរទៅពេលណាដឹងតែបានត្រីត្រឡប់មកផ្ទះវិញហើយ។ ប៉ុន្តែបច្ចុប្បន្នតាំងពីប្តីខ្ញុំស្លាប់ទៅមិនមានអ្នកណាទៅនេសាទត្រីដូចពីមុនទៀតទេហើយត្រីក៏ពិបាករកដែរ។ ខ្ញុំព្រួយបារម្ភដល់កូនចៅជំនាន់ក្រោយដោយសារតែត្រីកាន់តែថយចុះម្តងបន្តិចៗ មិនបានសប្បាយក្នុងការនេសាទដូចសម័យខ្ញុំនេសាទទេ។

# លោកជំទាវ ហ្វ្ល័រីដា អាន កាមីឡេ ភីម៉ៃយ៉ូ ឯកអគ្គរដ្ឋទូត ហ្វីលីពីន ប្រចាំនៅកម្ពុជា អមដំណើរដោយគណៈប្រតិភូនៃស្ថានទូត៤រូប ធ្វើទស្សនកិច្ចនៅ «ព្រះរាជបណ្ណាល័យហ្វ្លូងម៉ៃ»

*រស់ សំពៅ*



ឯកអគ្គរដ្ឋទូតហ្វីលីពីន ប្រចាំប្រទេសកម្ពុជា លោកជំទាវ Flerida Ann Camille P.Mayo និងលោក ឆាំង យុ ស្ថាបនិកព្រះរាជបណ្ណាល័យ ហ្វ្លូងម៉ៃ និងជានាយកមជ្ឈមណ្ឌលឯកសារកម្ពុជា។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅរសៀល ថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២៤ លោកជំទាវ ហ្វ្ល័ររីដា អាន កាមីឡេ ភីម៉ៃយ៉ូ (H.E. Flerida Ann Camille P. Mayo) ឯកអគ្គរដ្ឋទូតហ្វីលីពីនប្រចាំនៅកម្ពុជា អមដោយគណៈប្រតិភូនៃស្ថានទូត៤រូបទៀតរួមមាន៖ លោកស្រី ឡាអានីស៊ូរ៉ៃដា ហ្គាន់ដារ៉ូសា (Ms. Laarni Zorayda Gandarosa) អគ្គកុងស៊ុល, លោកស្រី ជេនីណា ម៉ារីយ៉ុន ធី រ៉ាហ្វ័ល (Ms. Genina Marion T. Rafal) លេខាទី៣ ឯកអគ្គរដ្ឋទូត និងអនុប្រធានកុងស៊ុល, លោកស្រី ហ័រមែនីហ្គីលដា ប៊ី ខារីណូ (Ms. Hermenigilda B. Cariño) មន្ត្រីអនុព័ន្ធវប្បធម៌, និងលោកស្រី ក្លារ៉ា ម៉ារីណែល ស៊ីគ្រុស (Ms. Clara Marinel C. Cruz) មន្ត្រីអនុព័ន្ធបានអញ្ជើញមក

ធ្វើទស្សនកិច្ចនៅ «ព្រះរាជបណ្ណាល័យ ហ្វូងម៉ែ» និង មជ្ឈមណ្ឌលឯកសារកម្ពុជា។

សូមរំឭកផងដែរថា កាលពីថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២៤ កន្លងទៅនេះ សម្រាប់អាណត្តិថ្មី លោកជំទាវ ហ្វ័ររីដា អាន កាមី ឡេ ភីម៉ៃយ៉ូ (H.E. Flerida Ann Camille P. Mayo ) ឯកអគ្គរដ្ឋទូតហ្វីលីពីន ប្រចាំនៅកម្ពុជា បានចូលជួបសម្តែងការគួរសម ជាមួយ សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា នៅវិមានសន្តិភាព ក្នុងរាជធានីភ្នំពេញ។

សម្រាប់កិត្តិយសដ៏ខ្ពង់ខ្ពស់នៃការអញ្ជើញធ្វើទស្សនកិច្ចនៅ ព្រះរាជបណ្ណាល័យ ហ្វូងម៉ែ និង មជ្ឈមណ្ឌលឯកសារកម្ពុជា គឺមានគោលបំណងពីរ៖ គោលបំណងទីមួយ លោកជំទាវឯកអគ្គរដ្ឋទូតហ្វីលីពីន និងគណៈប្រតិភូនៃស្ថានទូត បានជួបសំណេះសំណាលដោយភាពស្និតស្នាល និងភាតរភាពជាមួយ លោក ឆាំង យុ នាយកប្រតិបត្តិនៃមជ្ឈមណ្ឌលឯកសារកម្ពុជា (DC-Cam) និងស្ថាបនិកនៃព្រះរាជបណ្ណាល័យ ហ្វូងម៉ែ (QML) ហើយគោលបំណងទីពីរ បន្តពង្រឹងទំនាក់ទំនងប្រកបដោយភាតរភាពរវាងមន្ត្រីនិងបុគ្គលិកស្ថានទូតនៃសាធារណរដ្ឋហ្វីលីពីន ប្រចាំនៅកម្ពុជា ជាមួយបុគ្គលិកនៃព្រះរាជបណ្ណាល័យ ហ្វូងម៉ែ និង មជ្ឈមណ្ឌលឯកសារកម្ពុជា សម្រាប់អាណត្តិថ្មីនេះ។ គួររំឭកផងដែរថា នៅក្នុងឆ្នាំ២០១៨ មជ្ឈមណ្ឌលឯកសារកម្ពុជា បានទទួលពានរង្វាន់ Ramon Magsaysay Awards ( ពានរង្វាន់ដ៏មានកិត្យានុភាពនៃសាធារណរដ្ឋហ្វីលីពីន) ដែលត្រូវបានចាត់ទុកជា "ពានរង្វាន់ណូបែលអាស៊ី សម្រាប់ការថែរក្សាការចងចាំប្រវត្តិសាស្ត្រ ការអប់រំប្រវត្តិសាស្ត្រ ការផ្សះផ្សាផ្លូវចិត្ត និងការស្វែងរកយុត្តិធម៌សម្រាប់ជនរងគ្រោះនៃអំពើប្រល័យពូជសាសន៍នៅកម្ពុជា"។

សម្រាប់ទស្សនកិច្ចនេះ ជាបឋម លោកនាយក ឆាំង យុ បានផ្តល់ជូននូវព័ត៌មានលម្អិត តាមរយៈផ្ទាំងពិព័រណ៍ព្រះឆាយាល័ក្ខណ៍នៃសម្តេចព្រះបរមរតន



ឯកអគ្គរដ្ឋទូតហ្វីលីពីន ប្រចាំប្រទេសកម្ពុជា លោកជំទាវ Flerida Ann Camille P.Mayo ទស្សនកិច្ចព្រះរាជបណ្ណាល័យ ហ្វូងម៉ែ។ ( បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា )

កោដ្ឋ ព្រះវររាជបិតាជាតិខ្មែរ និងសម្តេចព្រះវររាជមាតាជាតិខ្មែរ ព្រមទាំងរាជវង្សានុវង្ស ដែលជាអំណោយរបស់ លោកបណ្ឌិត ហ្វូលីយ៉ូ អេ. ដែលជ្រេស អតីតអ្នកនិពន្ធព្រះរាជជីវប្រវត្តិនៃសម្តេចព្រះបរមរតនកោដ្ឋ និងសម្តេចព្រះវររាជមាតាជាតិខ្មែរ ព្រមទាំងអមបទភ្លេងជាព្រះរាជនិពន្ធរបស់សម្តេចព្រះបរមរតនកោដ្ឋ។ ជាងនេះទៀត ផ្ទាំងពិព័រណ៍ព្រះឆាយាល័ក្ខណ៍ដែលបានដាក់បង្ហាញ និងអមដោយបទភ្លេង គឺបានរំឭកដល់ព្រះរាជប្រវត្តិស្នេហារនៃសម្តេចឪនិងសម្តេចម៉ែ ដែលទ្រង់បានកត់ត្រាទុក ចំណងជើងថា៖ «ស្នេហាមួយមិនមែនជារឿងព្រេងនិទាន» ក្នុងសៀវភៅ «សម្តេចព្រះមហាក្សត្រីនរោត្តម មុនិនាថ សីហនុ ព្រះបវរាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល សម្រាប់ព្រះរាជដំណើរនៃជីវិតពោរពេញដោយព្រឹត្តិការណ៍»។ ពិសេសជាងនេះទៀត មានព្រះរាជចម្រៀងពីរបទបន្ថែមទៀតគឺ «រាត្រីដែលបានជួបភ័ត្រ» និង «ម៉ូនីកា» ក្រោយបានរៀបអភិសេក សម្តេចឪបានប្រទានព្រះរាជចម្រៀងថ្វាយសម្តេចម៉ែ ដើម្បីសម្តែងនូវព្រះរាជហឫទ័យស្វាមីភក្តិសម្រាប់ទ្រង់ ដែលទ្រង់តែងតែនៅក្បែរព្រះកាយរបស់ព្រះស្វាមីគ្រប់ពេល នឹងបានពុះពារឆ្លងកាត់នូវអនុស្សាវរីយ៍ដ៏ផ្អែមល្ហែមនិងជូរចត់រួមគ្នានៅគ្រប់កាលៈទេសៈ។

បន្ទាប់មក លោកនាយក ឆាំង យុ បានរៀបរាប់បង្ហាញ លោកជំទាវ ឯកអគ្គរដ្ឋទូតនិងគណៈប្រតិភូនូវបណ្ណាល័យ និងបណ្ណសារ រួមទាំងបរិក្ខាឯកសារដូចជា៖ ទូម៉ាស៊ីនផ្ទុកឯកសារឌីជីថល (Dedicated/Cloud Sever) បន្ទប់ផ្ទុកឯកសារសំឡេងបទសម្ភាស (Audio Room) ម៉ាស៊ីនម៉ាក្រូហ្វីល ក្នុងនោះរួមមានទាំងឯកសារក្រដាសដើម ឯកសារភស្តុតាង ឯកសាររូបថត ឯកសារសំឡេង និងឯកសារវីដេអូដ៏ច្រើនសន្ធឹកសន្ធាប់មួយចំនួនទៀត។

បន្ថែមលើសពីនេះទៀត លោកនាយក ឆាំង យុ បានរៀបរាប់យ៉ាងលម្អិតអំពីសកម្មភាពនៃគម្រោងការងារយូរអង្វែង និងជាអទិភាពរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា រួមមានការពង្រឹងនិងលើកកម្ពស់ «សិទ្ធិមនុស្ស លទ្ធិប្រជាធិបតេយ្យ និងនីតិរដ្ឋ» ដែលក្នុងនោះផ្តោតសំខាន់សម្រាប់ យុត្តិធម៌ ការចងចាំ និងការផ្សះផ្សាជាតិ តាមរយៈការប្រមូលចងក្រងឯកសារភស្តុតាងជាប្រវត្តិសាស្ត្រទាក់ទងនឹងអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការរំលោភបំពានធ្ងន់ធ្ងរ ដែលក្រុមការងារនៃមជ្ឈមណ្ឌលឯកសារកម្ពុជាបាននឹងកំពុងបន្តអនុវត្តជាបន្តបន្ទាប់។ ក្នុងពេលជាមួយគ្នានេះដែរ លោកនាយក ឆាំង យុ បានរៀបរាប់បង្ហាញបន្ថែមជូនដល់ លោកជំទាវ ឯកអគ្គរដ្ឋទូត និងគណៈប្រតិភូ ស្តីពីផែនទីនៃទីតាំងសិក្សាស្រាវជ្រាវរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា និងបណ្ណាល័យប្រវត្តិសាស្ត្រនៃរបបកម្ពុជាប្រជាធិបតេយ្យនៅតាមបណ្តាខេត្តទាំង១៩ ក្នុងប្រទេសកម្ពុជា។

ជាចុងបញ្ចប់ លោកជំទាវ ឯកអគ្គរដ្ឋទូត បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ លោកនាយក ដែលបានទទួលស្វាគមន៍ការអញ្ជើញទស្សនកិច្ចរបស់ លោកជំទាវនិងគណៈប្រតិភូនៃស្ថានទូតហ្វីលីពីននៅព្រះរាជបណ្ណាល័យ ហ្វូងម៉ែដ៏ស្រស់ស្អាតក្នុងថ្ងៃនេះ។ លោកជំទាវឯកអគ្គរដ្ឋទូតក៏បានកោតសរសើរយ៉ាងក្រៃលែងចំពោះសកម្មភាពការងារ ស្តីពីការអភិរក្សឯកសារប្រវត្តិសាស្ត្រកម្ពុជាដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយជាពិសេសសម្រាប់ព្រះរាជបណ្ណាល័យ ហ្វូងម៉ែ គឺជាទីតាំងតម្កល់រតនសម្បត្តិនៃប្រវត្តិសាស្ត្រកម្ពុជា ដែលបានចូលរួមចំណែកក្នុងការអប់រំនិងផ្តល់ចំណេះដឹងដ៏វិសេសវិសាល សម្រាប់អនាគតមនុស្សជំនាន់ក្រោយ និងទូទាំងពិភពលោក។



ឯកអគ្គរដ្ឋទូតហ្វីលីពីន ប្រចាំប្រទេសកម្ពុជា លោកជំទាវ Flerida Ann Camille P.Mayo និងគណៈប្រតិភូ ទស្សនកិច្ចព្រះរាជបណ្ណាល័យ ហ្វូងម៉ែ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# «អតីតអ្នកបើកឡានតាម៉ុកត្រូវបញ្ជូនទៅរៀនបច្ចេកទេសនៅប្រទេសចិន »

ចាន់ ណារិទ្ធ

សែប រ៉ែត ជាអតីតអ្នកបើកឡានតាម៉ុកត្រូវបានខ្មែរក្រហមជ្រើសរើសទៅរៀនផ្នែកយោធានៅប្រទេសចិន និងបានវិញត្រឡប់មកប្រទេសកម្ពុជាវិញនៅអំឡុងពេលកងទ័ពខ្មែរក្រហមធ្វើសង្គ្រាមជាមួយកងទ័ពវៀតណាមនៅតាមបណ្ដោយព្រំដែនកម្ពុជា-ថៃនៅឆ្នាំ១៩៧៩។ សែប រ៉ែតបានរៀបរាប់ពីបទពិសោធន៍ដែលនៅអ្នកបើកឡានឱ្យតាម៉ុក និងរៀនសូត្រផ្នែកបច្ចេកទេសគីមី និងផ្នែកយោធានៅប្រទេសចិនដូចខាងក្រោម៖។



សែប រ៉ែត អាយុ៦៨ឆ្នាំ សព្វថ្ងៃរស់នៅភូមិឈើទាលជ្រុំ ឃុំប្រម៉ោយ ស្រុកវាលវែង ខេត្តពោធិ៍សាត់។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

សែប រ៉ែត ភេទប្រុស អាយុ៦៥ឆ្នាំ សព្វថ្ងៃប្រកបមុខរបរធ្វើស្រែចម្ការ។ រ៉ែតមានស្រុកកំណើតនៅភូមិធ្លកយុល ឃុំស្រែក្នុង ស្រុកឈូក ខេត្តកំពត។ សព្វថ្ងៃរស់នៅភូមិឈើទាលជ្រុំ ឃុំប្រម៉ោយ ស្រុកវាលវែង ខេត្តពោធិ៍សាត់។ រ៉ែតមានប្រពន្ធឈ្មោះ នាង គូ អាយុ៥៨ឆ្នាំ សព្វថ្ងៃមានមុខរបរធ្វើស្រែចម្ការ។ រ៉ែត មានកូន៦នាក់( ប្រុស៣នាក់ ស្រី៣នាក់)។ រ៉ែត មានឪពុកឈ្មោះ ប៉ុក សែត(ស្លាប់ឆ្នាំ១៩៧៩) និងម្ដាយឈ្មោះ សុខ គួន។ រ៉ែត មានបងប្អូន៨នាក់(ប្រុស៥នាក់ ស្រី៣នាក់)។ បងប្អូនរ៉ែតបានស្លាប់២នាក់ជំនាន់សង្គ្រាមវាយជាមួយលន់ នល់។ រ៉ែត ជាកូនទី៤នៅក្នុងគ្រួសារ។

កាលពីក្មេង រ៉ែត បានរៀនត្រឹមថ្នាក់ទី៩ សង្គមចាស់ នៅសាលាវត្តស្រែ-ក្នុង។ រ៉ែត ឈប់រៀននៅឆ្នាំ១៩៧៣ ដោយសារតែប្រទេសមានសង្គ្រាម ជីវភាពគ្រួសារខ្វះខាតមិនអាចបន្តការសិក្សាបាន។ បន្ទាប់ពីឈប់រៀន រ៉ែត ត្រូវបានខ្មែរក្រហមប្រមូលឱ្យចូលក្នុងកងកុមារ។ រ៉ែត និងកុមារនៅក្នុងភូមិប្រហែល៦០ទៅ៧០នាក់ត្រូវបានខ្មែរក្រហមប្រមូលដាក់ផ្ដុំឱ្យនៅក្នុងសហករណ៍ហូបបាយរួមនិងធ្វើការងាររួមគ្នា។ ការងារដែល រ៉ែត ត្រូវធ្វើនៅក្នុងកងកុមារដំបូងមានដូចជា៖ ដើរកាប់ទន្ទ្រានខែត្រ រែកដីដំបូកដាក់ស្រែនិងដើររើសអាចម៍គោ ទុកសម្រាប់ធ្វើជី។ បន្ទាប់មកទៀតខ្មែរក្រហមចាប់ផ្ដើមជ្រើសរើសកុមារដែលធំៗឱ្យចូលខាងកងយុទ្ធជនព្រោះកុមារធំៗអាចហ្វឹកហាត់យុទ្ធសាស្ត្រកងទ័ព និងចូលសមរភូមិប្រយុទ្ធបាន។

នៅក្នុងឆ្នាំ១៩៧៤ វ៉ែត ត្រូវបានខ្មែរក្រហមជ្រើសរើសឱ្យធ្វើប្រធានក្រុមគ្រប់គ្រងយុទ្ធជននៅស្រុកឈូកដែលមានគ្នាប្រហែល៣០ទៅ៤០នាក់។ វ៉ែតរស់នៅស្រុកឈូកបានរយៈពេលប្រហែល៧ខែ ក៏ផ្លាស់ពីស្រុកឈូកឡើងមកភូមិភាគនិរតីវិញ ដោយសារតែពេលនោះកងទ័ពកងពលទី២ ប្រចាំភូមិភាគនិរតី ត្រូវការកងទ័ពជាចាំបាច់ ដើម្បីវាយជាមួយទាហាន លន់ នល់នៅក្នុងខេត្តតាកែវ ចាប់ពីត្រពាំងធំខាងត្បូង ត្រពាំងធំខាងជើង រហូតមកដល់ព្រំប្រទល់កំពង់ស្ពឺ។ ភូមិភាគនិរតីមាន៣កងពល៖ កងពលទី១ កងពលទី២ កងពលទី៣។ ពេលដែលចល័តមកប្រចាំការនៅម្តុំត្រពាំងអណ្តើក វ៉ែត បានមករស់នៅជាមួយ ទូច ប៊ុន ដែលជាប្រធានមន្ទីរកងពលទី២និងប្រធានកងពលឈ្មោះ វ៉ែន (កូនប្រសារតាម៉ុក ដែលមានស្រុកកំណើតនៅភូមិព្រៃខ្លា)។ ពេលនៅក្នុងមន្ទីរកងពលទី២ វ៉ែតជានីរសាររបស់ ទូច។ ពេលនោះ វ៉ែត ជួបការលំបាកជាច្រើន ព្រោះត្រូវយកសំបុត្រទៅកាន់កងវរសេនាតូចនៅតាមសមរភូមិនីមួយៗដោយឆ្លងកាត់ឧបសគ្គជាច្រើន មានពេលខ្លះមានខ្មាំងចាំស្ទាក់ក៏មាន។ បន្ទាប់មក ទូច បានជ្រើសរើសឱ្យ វ៉ែត ធ្វើជាប្រធានកងនីរសារ ដោយសារ វ៉ែត ជាមនុស្សដែល ទូច បានស្គាល់ជីវប្រវត្តិច្បាស់លាស់ និងជាបងប្អូននៅស្រុកភូមិជាមួយគ្នាផង។

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ កងទ័ពខ្មែរក្រហមបានវាយរំដោះបានទីក្រុងភ្នំពេញ ហើយខ្មែរក្រហមចាប់ផ្តើមជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញឱ្យទៅតាមបណ្តាខេត្តនានា ដោយបន្សល់ទុកសម្ភាររាយប៉ាយជាច្រើនពាសពេញទីក្រុងភ្នំពេញ។ នៅក្នុងកំឡុងពេលនោះ វ៉ែត ត្រូវបានផ្លាស់ចេញពីប្រធាននីរសារមកអង្គភាពបោសសម្អាតដែលមានគ្នាប្រហែល៥០នាក់បោសសម្អាតក្នុងក្រុងភ្នំពេញមកពោធិ៍ចិនតុង និងចោមចៅ។ ប្រធានអង្គភាពបោសសំអាតមានឈ្មោះ ធី។ ការងារប្រចាំថ្ងៃ គឺដើរបោសសំអាតសំរាមតាមផ្លូវលំនិងថ្នល់ជាតិ និងដើរប្រមូល ម៉ូតូ ឡានដែលរាយប៉ាយពេញថ្នល់រុញមកដាក់ក្នុងឃ្លាំង។ នៅពេលកំពុងប្រមូលសំរាមតាមផ្លូវ វ៉ែត ត្រូវបានទាហាន លន់ នល់ លួចបាញ់ ប៉ុន្តែមិនរងរបួស។ ទាហាន លន់ នល់ មួយចំនួនតូចបានលាក់ខ្លួនសម្ងំនៅក្នុងផ្ទះថ្មមិនព្រមចេញទៅណា លុះយប់ឡើងបានចេញមករកស្បៀង រកឆ្នាំងបាយដើម្បីលាក់ទុកសម្រាប់ដាំបាយហូប។

នៅក្នុងឆ្នាំ១៩៧៦ វ៉ែត បានផ្លាស់ចេញពីអង្គភាពបោសសម្អាតមកធ្វើជាកងការពារ តា ម៉ុក និង ទូច នៅភូមិភាគនិរតី (ខេត្តតាកែវ)។ ពេលដែលមករស់នៅមន្ទីរភូមិភាគនិរតី វ៉ែត បានក្លាយជាអ្នកបើក ឡានជូន តា ម៉ុក ទៅកន្លែង ប៉ុល ពត ទៅជួប ខៀវ សំផន និងជូនទៅប្រជុំគណៈរដ្ឋមន្ត្រីនៅភ្នំពេញមួយសប្តាហ៍ចំនួនពីរដង។ វ៉ែតបានបន្តថា ពេល តា ម៉ុក ជិះ ឡានចេញពីក្រុងតាកែវប្រហែលកន្លះគីឡូ តា ម៉ុក តែងតែចុះត្រួតពិនិត្យមើលប្រជាជននៅតាមសហករណ៍ កន្លែងធ្វើស្រែ និងចុះទៅមើលប្រជាជននៅតាមជនបទរួចក៏បើក ឡានត្រឡប់ទៅវិញ។ វ៉ែតបានបន្តទៀតថា តា ម៉ុក ខស្សាហ៍ក្លែងបន្លំខ្លួនពាក់អាវចាស់ៗរហែកទៅកន្លែងធ្វើស្រែណាស់ ដើម្បីដើរពិនិត្យមើលការងារ។ មានថ្ងៃមួយគាត់បានបន្លំខ្លួនដើរពិនិត្យការងារដូចសព្វដង ប៉ុន្តែត្រូវបានខាងឃុំនិងភូមិចាប់បានដោយចោទប្រកាន់ថាជាអ្នកស៊ើបការណ៍រួចយកគាត់ទៅសួរចម្លើយ ប៉ុន្តែមិនបានធ្វើទារុណកម្មទេ។ លុះសួរនាំប្រហែលកន្លះម៉ោងទើបដឹងថា តា ម៉ុក ក៏ដោះលែងមកវិញ។ នៅពាក់កណ្តាលឆ្នាំ១៩៧៦ តា ម៉ុក បានបញ្ជូនមនុស្សសំខាន់ៗខាងផ្នែកយោធាទៅ គ្រប់គ្រងនៅតាមព្រំដែនវៀតណាមនៅខាងភ្នំដិន។ នៅពេល តា ម៉ុក ជាប់រវល់ចុះទៅមូលដ្ឋានម្តងៗ មិនបានចូលរួមប្រជុំគណៈរដ្ឋមន្ត្រីនៅភ្នំពេញ តា ម៉ុក តែងតែប្រើ វ៉ែត និងកងការពារ២នាក់ទៀតឈ្មោះ សយ និង ញ៉ុញ ប្អូនប្រុសរបស់ ទូច ដែលចេះបើក ឡានបញ្ជូនឯកសារទៅខាងមជ្ឈិម ដែលហៅថាមន្ទីរ៨៧០ ដែលជាកន្លែងប៉ុល ពត, ខៀវ សំផន, អៀង សារី, វ៉ន វេត,

ចេង អន, នួន ជា, សុន សេន ប្រជុំនៅម្តុំស្ពាតអូរ ឡាំពិក។ បន្ទាប់ពីប្រជុំចប់ប្រធានមន្ទីរនៅមជ្ឈិមឈ្មោះ ញ៉ាន់ នៅជាប់ជាមួយប៉ុល ពត ខៀវ សំផនបានផ្ញើឯកសារត្រឡប់មកវិញ។ ឯកសារដែលប៉ុល ពតផ្ញើមកមានដូចជា៖ ឯកសារនិយាយពីរឿងផ្ទៃក្នុងបក្សសៀវភៅទង់បដិវត្តន៍ជាដើម។ វ៉ែត បាននិយាយបន្តថា តាម៉ុក ឧស្សាហ៍ចុះទៅតាមសហករណ៍ព្រោះចង់ដឹងប្រជាពលរដ្ឋរស់នៅរបៀបម៉េច ហើយការហូបចុកគ្រប់គ្រាន់ដែរឬអត់។ កន្លែងខ្លះក៏ឆ្លើយថាហូបគ្រប់គ្រាន់ និងកន្លែងខ្លះទៀតក៏ឆ្លើយ ហូបមិនបានគ្រប់គ្រាន់ដោយសារតែ មេភូមិ មេឃុំត្រៀមស្បៀងផ្តល់ទៅឱ្យរដ្ឋច្រើនពេក ដល់ចឹងសហករណ៍ខ្លះ ហូបមិនបានគ្រប់គ្រាន់។ បន្ទាប់ពីដឹងថាសហករណ៍ខ្លះហូបមិនបានគ្រប់គ្រាន់ តាម៉ុក ក៏មានវិធានការណ៍ណែនាំទៅខាងភូមិ និងឃុំមិនឱ្យបញ្ជូនស្រូវទៅរដ្ឋហួសកំណត់ដែលរដ្ឋដាក់ផែនការ ដើម្បីឱ្យប្រជាជនហូបបានគ្រប់គ្រាន់ឡើងវិញ។ តា ម៉ុក បានណែនាំបន្ថែមទៀតថា ពេលដែលហូបបានគ្រប់គ្រាន់ យើងត្រូវហូបឱ្យចេះសន្សំសំចៃ ហូបកុំឱ្យសល់ច្រើន ហូបឱ្យបានត្រឹមត្រូវដែលយើងអាចមានកម្លាំងធ្វើការងារបាន ហើយគាត់បាននិយាយបន្ថែមប្រាប់ទៅកាន់ប្រជាពលរដ្ឋដែលនៅកងភ្ជួរមិនឱ្យបររទេះគោកាត់តាមផ្លូវថ្នល់ពេលថ្ងៃ ព្រោះវាអាចបណ្តាលខូចផ្លូវ និងហួសម៉ោងគោស៊ីស្មៅ។ នៅចុងឆ្នាំ១៩៧៦-៧៧ វ៉ែត បានបើកឡានជូន តាម៉ុក ចុះទៅតាមមូលដ្ឋានស្រុកឈូក ខេត្តកំពត ដែលមាន តា ផែន. តា ផុន និងប៉ុន ផុន គ្រប់គ្រងនៅទីនោះ។ ពេលទៅដល់ វ៉ែត បានឃើញប្រជាជន១៧ មេសា ដែលជម្លៀសមកពីភ្នំពេញជាច្រើនត្រូវខ្មែរក្រហមយកទៅសម្លាប់នៅក្នុងទីធ្លាវត្តស្រែក្នុង ដែលស្ថិតនៅក្នុងភូមិធ្លកយុល ដែលមានទំហំប្រហែលមួយគីឡូកន្លះ៤ជ្រុង ដោយសារតែប្រជាជនទាំងអស់នោះអត់ប្រសព្វធ្វើស្រែ និងធ្វើការងារពលកម្ម។ នៅពេលកងឈ្លបឃុំដើរពិនិត្យឃើញក៏ចោទថា ខ្ជិលស៊ីរូងផ្ទៃក្នុង ហើយបានយកពួកគាត់ទៅសម្លាប់នៅក្នុងវត្តស្រែក្នុង ដែលមានរណ្តៅធំៗនៅក្បែរដើមស្វាយ និងដើមដូង ។ ពេលនោះ វ៉ែត ព្រួយបារម្ភខ្លាំងណាស់ ព្រោះខ្លាចមានឪពុកម្តាយបងប្អូនជាប់និន្នាការជាមួយអ្នក១៧ មេសាដែលអាចចាប់ដាក់គុក ឬយកទៅសម្លាប់។ វ៉ែត បាននិយាយប្រាប់ តា ម៉ុក ថាទីធ្លាដែលសម្លាប់ប្រជាជនច្រើនគឺជាកន្លែងដែលគាត់ធ្លាប់អង្គុយរៀនពីមុន។ តាម៉ុក ដឹងតែគាត់ក៏អត់មានវិធានការណ៍ដែរ។ នៅក្នុងខែមីនា ឆ្នាំ១៩៧៧ តាម៉ុក បានជ្រើសរើសកម្លាំងខាងផ្នែកទ័ព និងខាងគ្រប់ក្រសួងមន្ទីរប្រហែល៣០០នាក់ មកបំពេញបែបបទនៅភ្នំពេញដើម្បីទៅរៀនបន្តនៅប្រទេសចិន។ ពេលមកដល់ភ្នំពេញ វ៉ែត បានមករៀននៅសាលាទួលគោក សាលាមិត្តភាពកម្ពុជាសូវៀត ដែលមានគ្រូចិនបង្រៀន និងរៀនផ្នែកអក្សរសាស្ត្របន្ថែមបានរយៈពេល៦ខែក៏រៀបចំឡើងទៅរៀនបន្តនៅប្រទេសចិន។

នៅក្នុងខែមិថុនា ឆ្នាំ១៩៧៨ វ៉ែត ត្រូវបានបញ្ជូនទៅរៀននៅប្រទេសចិន ដែលស្ថិតនៅក្នុងខេត្តគ័ង ទុង។ នៅពេលទៅដល់ប្រទេសចិន វ៉ែត បានរៀនបច្ចេកទេសផ្នែកគីមី ក្នុងគោលបំណងពេលដែលត្រឡប់មកប្រទេសខ្មែរវិញ ធ្វើគ្រូខាងផ្នែករោងចក្រប្រេងនៅកំពង់សោម។ វ៉ែត រៀនបច្ចេកទេសខាងផ្នែកគីមី បានរយៈពេល៣ខែ ក៏ផ្លាស់មករៀនផ្នែកយោធាវិញ ដោយសារតែទាហានវៀតណាមបានវាយចូលព្រំដែនខ្មែរជាខ្លាំង។ បន្ទាប់មកទូតខ្មែរប្រចាំនៅស្រុកចិនបានប្រាប់ទៅកាន់កងទ័ពដែលមករៀនទាំងអស់ឱ្យរៀបចំខ្លួនវិលត្រឡប់មកប្រទេសខ្មែរវិញ ព្រោះប្រទេសកំពុងតែមានសង្គ្រាមព្រំដែន។ ពេលនោះ វ៉ែត ឈប់រៀនខាងផ្នែកគីមី មករៀនខាងផ្នែកយោធាវិញ។ ផ្នែកយោធាដែល វ៉ែត ត្រូវរៀនមាន២គឺ ផ្នែកកងរថក្រោះ និងផ្នែកកាំភ្លើងធំៗ។ នៅពេលនោះ វ៉ែត រៀនខាងផ្នែកកងរថក្រោះបានរយៈពេលមួយខែ ក៏ចាប់ផ្តើមបញ្ជូនតាមកប៉ាល់មកកាន់ព្រំដែនថៃទាំងអស់។ ពេលចេញពីព្រំដែនថៃ វ៉ែត និងកងទ័ពជាច្រើនបានធ្វើដំណើរមកចូលរួម

ជាមួយកងពលទី២ ដែលដឹកនាំដោយ តា វ៉ែន។ វ៉ែត រស់នៅក្នុងកងពលទី២បានរយៈពេល៤-៥ខែ ដោយសារមានបញ្ហាផ្ទៃក្នុងកងពលដោះស្រាយមិនបាន ក្រុមវ៉ែត ក៏ផ្លាស់ទៅកងពលទី៣នៅថ្មដាវិញ ដែលគ្រប់គ្រងដោយ តា សេង។

ក្នុងឆ្នាំ១៩៨៥ តា សេង ប្រធានកងពលទី៣ បានចាត់តាំងឱ្យអង្គភាពនីមួយៗប្រមូលសម្ភារដូចជា រថក្រោះ ឡានដឹកជញ្ជូនគ្រាប់ ឡានអូសកាំភ្លើងយកដាក់នៅក្នុងស្រុកថៃ។ បន្ទាប់ពីប្រមូលសម្ភារដាក់ក្នុងទឹកដីថៃអស់ កងពលទី៣ បានផ្លាស់ចេញពីថ្មដាចុះមកសមរភូមិខាងក្នុង ដើម្បីទៅវាយ ខាងផ្នែកកោះកុង ត្រពាំងរូង និងអណ្តូងទឹក។ បន្ទាប់ពីវាយហើយ វ៉ែត បានបន្តរស់នៅជាមួយកងពលតូចដែលគ្រប់គ្រងដោយតា អ៊ឹម បានរយៈពេល៣ឆ្នាំ។ នៅឆ្នាំ១៩៨៩ វ៉ែត រៀបចំមានគ្រួសារ។

នៅក្នុងឆ្នាំ១៩៩២ វ៉ែត បានមកបើក ឡានឱ្យ មាស មុត និង តា ម៉ុក ម្តងទៀត។ នៅពេលរស់នៅជាមួយ មាស មុត និង តា ម៉ុក វ៉ែត មានរបួសដោយធ្លាក់ពីលើដើមស្វាយកម្ពស់៤ម៉ែត្រ ខណៈពេលដែលដំឡើងគេអូបញ្ជរទៅតាមសមរភូមិ អុកបះសរសៃប្រសាទ បណ្តាលខូចចង្កេះ និងស្ពិតជើងទាំងសងខាង វ៉ែត ត្រូវបានបញ្ជូនឡើងទៅដេកពេទ្យថៃរយៈពេល១ខែបានអាចដើររួច។

នៅក្នុងឆ្នាំ១៩៩៣ បន្ទាប់ពីមានកិច្ចព្រមព្រៀងនៅទីក្រុងប៉ារីស ប្រជាជនបាននាំគ្នាសប្បាយព្រោះគិតថាសង្គ្រាមត្រូវបានបញ្ចប់ ពេលនោះប្រជាជនអាចប្រកបរបររកស៊ីធម្មតាបាន មិនយូរប៉ុន្មានក៏កើតមានសង្គ្រាមផ្ទៃក្នុងនៅតាមព្រំដែនអស់រយៈពេល១០ខែម្តងទៀត។ បន្ទាប់ពីសមាហរណកម្ម វ៉ែត និងគ្រួសារកងទ័ពជាច្រើនបាននាំគ្នាមករស់នៅភូមិឈើទាលជ្រុំប្រកបរបរធ្វើស្រែចម្ការដើម្បីចិញ្ចឹមជីវិត ។ វ៉ែត រស់នៅភូមិឈើទាលជ្រុំបានកន្លះឆ្នាំ ត្រូវបានបោះឆ្នោតជ្រើសរើសឱ្យធ្វើប្រធានកងពលអន្តរាគមន៍ដើម្បីត្រួតពិនិត្យមើលឈ្មោះទាហានរដ្ឋាភិបាលបានរយៈពេល៣ឆ្នាំក៏ចូលនិវត្តន៍ ហើយក៏បន្តធ្វើស្រែចម្ការរហូតមកដល់សព្វថ្ងៃ។

ជាចុងក្រោយរឿងរ៉ាវដែល វ៉ែត ចងចាំមិនអាចបំភ្លេចបាន គឺប្រជាជន១៧មេសាជាច្រើនត្រូវបានយកសម្លាប់នៅក្នុងទីធ្លាវត្តស្រែក្នុង ស្ថិតភូមិធ្លុកយុលដែលជាកន្លែងដែល វ៉ែត ធ្លាប់អង្គុយរៀនកាលពីមុនសង្គ្រាម។ វ៉ែត បានផ្តាំផ្ញើទៅកាន់ក្មេងជំនាន់ក្រោយថា សង្គ្រាមបានធ្វើឱ្យមនុស្សបាត់ជីវិតច្រើនណាស់ យើងត្រូវតែខំរៀន បើយើងចេះដឹងសង្គ្រាមក៏លែងមានដែរ។



ចម្ការដំឡូងមី នៅស្រុកវាលវែង ខេត្តពោធិ៍សាត់។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ខ្ញុំត្រូវខ្មែរក្រហមបង្ខំឱ្យហូបសាច់មនុស្ស

**ម៉ាប់ ស៊ីណា**



ជូន យឿន អាយុ៥៧ឆ្នាំ សព្វថ្ងៃរស់នៅភូមិគ្គុលលើ ឃុំទន្ទង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅក្នុងឆ្នាំ១៩៧៨ នៅខណៈពេលខ្ញុំបានដើរទៅរកបាយហូប ខ្ញុំប្រទះឃើញខ្មែរក្រហមកំពុងតែលីងសាច់មនុស្ស។ ពេលខ្មែរក្រហមឃើញខ្ញុំក៏ចាប់ និងបង្ខំឱ្យហូបសាច់មនុស្ស បើខ្ញុំមិនហូប ខ្ញុំត្រូវខ្មែរក្រហមយកទៅសម្លាប់ចោល។ ដោយសារខ្លាចខ្មែរក្រហមសម្លាប់ ខ្ញុំបានបិតភ្នែក និងហូបសាច់មនុស្ស។

ខ្ញុំឈ្មោះ ជូន យឿន ភេទប្រុស អាយុ៥៧ឆ្នាំ កើតនៅភូមិគ្គុលលើ ឃុំទន្ទង ស្រុកមេមត់ ខេត្តកំពង់ចាម។ បច្ចុប្បន្នខ្ញុំរស់នៅភូមិគ្គុលលើ ឃុំទន្ទង ស្រុកមេមត់ ខេត្តត្បូងឃ្មុំដដែល។ ឪពុកខ្ញុំឈ្មោះ ជូន ស្លាប់ក្នុងរបបខ្មែរក្រហមដោយសារអត់បាយហូប ពេលដែលខ្មែរក្រហមជម្លៀសដោយបង្ខំទៅរស់នៅភូមិម្ចិប ស្រុកស្នួល ខេត្តក្រចេះ គ្មានបាយហូប និងប្រើឱ្យធ្វើការច្រើន។ ឪពុកខ្ញុំបានធ្លាក់ខ្លួនឈឺ គ្មានពេទ្យ និងថ្នាំព្យាបាលរហូតដល់ស្លាប់។ ម្តាយខ្ញុំឈ្មោះ ស៊ុម ស្លាប់ ពេលខ្មែរក្រហមចាត់តាំងឱ្យធ្វើការក្នុងក្រុមប្រវាស់ដៃក្នុងឆ្នាំ១៩៧៤។ ម្តាយខ្ញុំ ត្រូវខ្មែរក្រហមប្រើឱ្យបុកស្រូវ នៅខណៈនោះគាត់បានហើមពោះ ឈឺក្នុងពោះ គ្មានថ្នាំ និងពេទ្យព្យាបាល។ ម្តាយខ្ញុំឈឺរហូតដល់ស្លាប់។ ខ្ញុំមានបងប្អូន៥នាក់ (ប្រុស៣នាក់ស្រី២នាក់) នៅរស់ទាំងអស់។ ខ្ញុំមានប្រពន្ធឈ្មោះម៉ឺន ជឿន អាយុ៣៣ឆ្នាំ ប្រពន្ធខ្ញុំបានស្លាប់បាត់ហើយដោយសារឈឺក្នុងពោះ និងបន្សល់ទុកកូន៣ប្រុសទាំងបី។ កាលពីកុមារភាពខ្ញុំមិនបានរៀនសូត្រទេ ព្រោះគ្រួសារខ្ញុំក្រីក្រ មានជីវភាពខ្វះខាត ខ្ញុំធ្វើតែការងារមិនបានរៀនសូត្រទេ សព្វថ្ងៃខ្ញុំមិនចេះអាន និងសរសេរអក្សរឡើយ ។

នៅឆ្នាំ១៩៧៥ ខ្ញុំមានអាយុ៧-៨ឆ្នាំ ខ្មែរក្រហមចូលមកនៅក្នុងភូមិគ្គុលលើភ្លាមមិនទាន់ឱ្យប្រជាជនហូបរួមទេ ខ្មែរក្រហមបានចាត់តាំងប្រជាជនឱ្យធ្វើស្រែចម្ការប្រវាស់ដៃឱ្យគ្នាម្នាក់ម្តងៗ ហើយបែងចែករបបឱ្យហូប តែហូបមិនឆ្អែតទេ។ មិនយូរប៉ុន្មានខ្មែរក្រហមបានប្រមូលរបស់របរ ដូចជា គោ ក្របី ដីស្រែ ចម្ការ ដាក់ជារបស់រួម និងចាប់ផ្តើមឱ្យប្រជាជនហូបរួម ធ្វើការរួម លែងឱ្យមានដាកម្មសិទ្ធឯកជនទៀតហើយ។ ខ្មែរក្រហមហាមដាច់ខាតមិនឱ្យផ្ទះអ្នកណាម្នាក់ចិញ្ចឹមសត្វឆ្កែទេ។ បើផ្ទះណាមានឆ្កែ ខ្មែរក្រហម

វាយចោល ទាំងផ្លែ ទាំងម្ចាស់។ ខ្មែរក្រហមអនុញ្ញាតឱ្យចិញ្ចឹមសត្វផ្សេងៗទៀត លើកលែងតែឆ្កែ ព្រោះខ្មែរក្រហមគិតថាបើមានឆ្កែពេលដែលមានឈ្លបដើរពេលយប់ច្បាស់ណាស់ឆ្កែនិងព្រុស ធ្វើឱ្យប្រជាជនទាំងអស់មានការប្រុងប្រយ័ត្នក្នុងការនិយាយស្តីគ្នានៅពេលយប់និងពិបាកក្នុងការស៊ីបការណ៍ ពេលណាដែលដើរតាមផ្ទះ ផ្ទះណាមានឆ្កែវានិងព្រុស ជាហេតុដែលខ្មែរក្រហមមិនឱ្យចិញ្ចឹមឆ្កែ។ នៅក្នុងឆ្នាំ១៩៧៦ ខ្មែរក្រហមបានជម្លៀសប្រជាជនក្នុងភូមិក្តុលលើ ទាំងអស់ឱ្យទៅរស់នៅតាមភូមិផ្សេងៗ ដំបូងនៅភូមិស្រែតាពេជ្រ ឃុំជាំតាម៉ៅ ស្រុកមេមត់ខេត្តកំពង់ចាម (បច្ចុប្បន្នខេត្តត្បូងឃ្មុំ)។ នៅពេលជម្លៀសនោះបងប្អូនខ្ញុំ៥នាក់ត្រូវបានបែកគ្នា បងប្រុសខ្ញុំមានប្រពន្ធ ទៅតាមប្រពន្ធ។ បងស្រីទីពីរខ្ញុំទៅធ្វើកងចល័ត បងស្រីទីបីខ្ញុំ និងប្អូនពៅនៅកងកុមារ។ មេក្រុមខ្មែរក្រហមឈ្មោះ ម៉ាំ សារី អនុប្រធានឈ្មោះ ប៉ក កញ្ចៀង និងសមាជិកម្នាក់ទៀតឈ្មោះ ចង ប៊ិន ជាអ្នកដើរប្រាប់ប្រជាជនក្នុងភូមិក្តុលលើឱ្យទៅរស់នៅភូមិផ្សេង ដោយហេតុផល ថាខ្មាំងវៀតណាមចូលមកសម្លាប់។ ពេលរស់នៅស្រែតាពេជ្រ ខ្ញុំជាកងកុមារ ខ្មែរក្រហមឱ្យខ្ញុំមើលគោ រើសអាចម៍គោ សម្រាប់ធ្វើជី ការហូបចុកនៅស្រែតាពេជ្រមិនឆ្អែតទេ។ មានពេលខ្លះខ្ញុំអាចលួចដាំបាយហូបនៅពេលយប់ ប៉ុន្តែបើខ្មែរក្រហមដឹងខ្ញុំប្រាកដជាខ្មែរក្រហមយកទៅសម្លាប់ជាមិនខានខ្ញុំមានសំណាងក៏ថាបានព្រោះរាល់ពេលខ្ញុំលួចដាំបាយខ្មែរក្រហមមិនដែលដឹងទេ។ ខ្ញុំរស់នៅភូមិស្រែតាពេជ្យអស់រយៈពេលមួយឆ្នាំ។ ចំណែកអ្នកភូមិស្រែតាពេជ្រទៅរស់នៅភូមិផ្សេងៗ។ បន្ទាប់មកខ្មែរក្រហមចាប់ផ្តើមជម្លៀសចេញពីភូមិស្រែតាពេជ្រទៅរស់នៅភូមិម្ទិច (ខេត្តក្រចេះ) ខ្ញុំរស់នៅម្ទិចរយៈពេលមួយឆ្នាំ រស់នៅទីនោះដូចជាប់គុកអត់ជញ្ជាំងអញ្ចឹង ខ្មែរក្រហមមិនអនុញ្ញាតឱ្យដើរទៅណាផ្តេសផ្តាស់ឡើយ ព្រោះខ្លាចយើងលួចចាប់ក្តាមខ្យងយកមកហូប ខ្មែរក្រហមឱ្យយើងហូបតែបបរមួយវែកៗគ្មានគ្រាប់អង្ករទេមានតែទឹកៗមានមនុស្សជាច្រើនបានស្លាប់ដោយសារដាច់ពោះគ្មានអ្វីហូប គ្មានកម្លាំង មួយថ្ងៃៗមានមនុស្សប្រហែល១០នាក់បានស្លាប់ នៅម្ទិចនេះប្រជាជនស្លាប់ច្រើនណាស់ដោយសារគ្មានអ្វីហូប ឈឺគ្រុនគ្មានពេទ្យគ្មានថ្នាំព្យាបាលទេ មានតែដាំបុសឈើ ស្លឹកឈើផឹក រង់ចាំតែសេចក្តីស្លាប់ប៉ុណ្ណោះ។ ពេលខ្ញុំនៅម្ទិច ខ្ញុំបានឃើញខ្មែរក្រហមធ្វើបាបប្រជាជន ធ្វើទារុណកម្មមនុស្សដោយមូលហេតុលួចរបស់ហូបអ្នកខ្លះធ្វើខុសសីលធម៌។ ខ្ញុំត្រូវបានខ្មែរក្រហមធ្វើទារុណកម្ម ដោយសារឃ្លានខ្លាំងពេក ទ្រាំមិនបានក៏ទៅលួចបាយនៅរោងបាយយកមកហូបតែជាអកុសល ខ្ញុំត្រូវបានក្រុមខ្មែរក្រហមចាប់បាននៅខណៈពេលខ្ញុំកំពុងរត់ផងហូបផង។ ខ្ញុំបានគិតថាបើខ្ញុំស្លាប់ក៏ស្លាប់ទៅ ចុះឱ្យតែខ្ញុំបានហូបឆ្អែត ព្រោះខ្ញុំឃ្លានខ្លាំងណាស់ទ្រាំមិនបានទេ ។ ខ្ញុំត្រូវបានខ្មែរក្រហមចាប់ចង និងវាយខ្ញុំយ៉ាងខ្លាំង ខ្មែរក្រហមបានឱ្យប្រជាជនជាច្រើនមកមើលខ្ញុំដើម្បីកុំឱ្យធ្វើតម្រាប់តាមខ្ញុំ ប៉ុន្តែនៅតែមានអ្នកលួចរបស់ហូបដដែល ព្រោះគ្មានអ្នកណាម្នាក់ទ្រាំនឹងភាពអត់ឃ្លានបានទេ នៅតែមានអ្នកលួច ៗ ខ្មែរក្រហមប្រើឱ្យធ្វើការងារគ្មានពេលសម្រាកៗ ចំណែកការហូបចុកវិញ ស៊ីអត់ស៊ីឃ្លាន ធ្វើឱ្យប្រជាជនខ្មែរជាច្រើនត្រូវបានស្លាប់ដោយសារដាច់ពោះ។ ទិន្នផលស្រូវដែលទទួលបានយកទៅដោះដូរជាមួយគ្រឿងសព្វាវុធជាមួយប្រទេសចិន សុខចិត្តឱ្យប្រជាជនគ្មានអ្វីហូប។ នៅឆ្នាំ១៩៧៨ ខ្ញុំត្រូវបានខ្មែរក្រហមជម្លៀសទៅនៅភូមិរំពុក ឃុំឃ្សឹម ស្រុកស្នួល ខេត្តក្រចេះ នៅទីនោះធ្វើការងារដូចតែនៅម្ទិចគ្មានអ្វីខុសគ្នាទេ មើលគោ រើសអាចម៍គោ ការហូបចុកមិនគ្រប់គ្រាន់ដដែល និងផ្លាស់ពីកន្លែងមួយទៅកន្លែងមួយដូចគ្នា។ នៅខណៈពេលខ្ញុំដើរទៅរកបាយហូប ស្រាប់តែខ្ញុំប្រទះឃើញពួកខ្មែរក្រហមកំពុងតែលីងសាច់មនុស្ស ហើយខ្ញុំត្រូវខ្មែរក្រហមចាប់ និងបង្ខំឱ្យហូបសាច់មនុស្សបើខ្ញុំមិនហូបទេ ខ្ញុំត្រូវខ្មែរក្រហមយកទៅសម្លាប់ចោល ខ្ញុំហូបទាំងបិតភ្នែក វាពិតជាយោរយៅណាស់ មនុស្សស៊ីមនុស្ស ខ្ញុំហូបបានតែពីរបីម៉ាត់ទេ។ សាច់មនុស្សមានរសជាតិប្រៃៗហើយផុយៗ ពេលដែលខ្មែរក្រហមលីងវាផ្ទុះខ្លាំងណាស់ព្រោះនៅក្នុងខ្លួនមនុស្សមានជាតិទឹកច្រើន។ បន្ទាប់មក

ខ្មែរក្រហមជម្លៀសខ្ញុំទៅនៅយ្រឹមបានពីរទៅបីខែ ក៏មានឡានខ្មែរក្រហមមកដឹកប្រជាជនយកទៅសម្លាប់ចោល។ ចំណែកខ្ញុំត្រូវចាំឡើងឡានដើរក្រោយទៀត តែសំណាងល្អកងទ័ពវៀតណាមក៏ចូលមករំដោះ មានទាំងយន្តហោះបានស្រែកថាប្រជាជនដែលមកពីភូមិណាសូមត្រឡប់ទៅភូមិនោះវិញចុះ ពេលវៀតណាមចូលមកពួកខ្មែរក្រហមបាននាំគ្នារត់ទៅអស់។ ខ្ញុំបាននៅភូមិដើងឃ្លូ ឃុំពីរធ្នូ មួយរយៈសិន នៅទីនោះមានទាហានវៀតណាម នៅចាំការពារច្រើន ខ្ញុំបានសុំបាយយោធាហូប ដើម្បីមានកម្លាំង ទើបខ្ញុំត្រឡប់មកស្រុកកំណើតខ្ញុំវិញ។ ខ្ញុំបានមករស់នៅជាមួយបងប្រុសខ្ញុំនៅភូមិរំដេង ឃុំទន្លូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ ដោយសារបងខ្ញុំយកប្រពន្ធនៅទីនោះ ខ្ញុំមិនបានត្រឡប់មកនៅភូមិក្តួលលើទេ។ ខ្ញុំនៅភូមិរំដេងជាមួយបងប្រុសខ្ញុំបានធ្វើស្រែចម្ការដើម្បីចិញ្ចឹមជីវិត។

ខ្ញុំនៅតែនឹកឃើញរឿងរ៉ាវនៅក្នុងសម័យខ្មែរក្រហមជានិច្ចដែលធ្វើបាបប្រជាជនបង្ខំឱ្យធ្វើការជាច្រើនម៉ោង គ្មានពេលសម្រាក រស់នៅបែកបាក់គ្រួសារ គ្មានអាហារហូបគ្រប់គ្រាន់។ ខ្ញុំនៅតែខ្លាចរបបខ្មែរក្រហមវិលត្រឡប់មកម្តងទៀតណាស់ ខ្ញុំមិនចង់ឱ្យវាកើតឡើងទេ វាពិតជាឃោរឃៅណាស់ បើត្រឡប់មកម្តងទៀតខ្ញុំអាណិតក្មេងៗជំនាន់ក្រោយ។ ខ្ញុំធ្លាប់បាននិយាយរឿងរ៉ាវដែលខ្ញុំចងចាំមិនអាចបំភ្លេចបានពីរបបខ្មែរក្រហមដល់មនុស្សជុំវិញខ្លួនខ្ញុំ ជាពិសេសក្មេងៗជំនាន់ក្រោយដូចជាកូនរបស់ខ្ញុំឈ្មោះ យឿន ដេត យឿន ដា យឿន ឌី និងក្មួយខ្ញុំឈ្មោះ នើស សំណាង។ ខ្ញុំបាននិយាយពីជីវិតពិតរបស់ខ្ញុំបានជួបការលំបាក ដូចជាការអត់ឃ្លាន ការធ្វើការងារពលកម្មច្រើនម៉ោងក្នុងមួយថ្ងៃៗ រស់នៅបែកបាក់គ្រួសារ គ្មានសិទ្ធិសេរីភាព។ ខ្ញុំធ្លាប់ឆ្លងកាត់ពីរបបប៉ុល ពត នោះ ធ្វើឱ្យខ្ញុំរិតតែចង់និយាយរឿងរ៉ាវដែលខ្ញុំជួបនៅសម័យខ្មែរក្រហមប្រាប់ដល់កូន ចៅ និងក្មួយៗខ្ញុំបន្តទៀត ព្រោះវាមានសារសំខាន់ណាស់ កុំឱ្យក្មេងៗយកគំរូតាម។ ក្មេងៗជំនាន់ក្រោយត្រូវជៀសឱ្យឆ្ងាយពីអំពើហិង្សាទាំងឡាយ និងត្រូវខិតខំប្រឹងប្រែងរៀនសូត្រឱ្យមានចំណេះដឹងមានការចេះគិតបានវែងឆ្ងាយជាពិសេសនោះចេះស្រឡាញ់ប្រទេសជាតិរបស់ខ្លួន។



វាលស្រែនៅភូមិក្តួលលើ ឃុំទន្លូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ឆាយ ធឿន ៖ ធ្វើការនៅរោងចក្រផលិតរំសេវ ក្នុងរបបខ្មែរក្រហម

**សោម ប៊ុនថន**

ខ្ញុំឈ្មោះ ឆាយ ធឿន កើតនៅឆ្នាំ១៩៤៨ នៅភូមិទួលអង្គប់ ឃុំសំបួរ ស្រុកស្វាយទាប ខេត្តស្វាយរៀង។ ខ្ញុំមានឪពុកឈ្មោះ ពេន សឺន ស្លាប់នៅឆ្នាំ១៩៩៧ និងម្តាយឈ្មោះ ថោង ម៉ៅ ស្លាប់ដោយសារជំងឺ។ ខ្ញុំមានបងប្អូន៨នាក់ ហើយខ្ញុំគឺជាកូនទី៣។ បងប្អូនខ្ញុំនៅរស់៧ នាក់ ចំណែកប្អូនម្នាក់បានស្លាប់នៅឆ្នាំ១៩៨៣។

កាលពីក្មេងខ្ញុំរៀនដល់ថ្នាក់ទី៣នៅអនុវិទ្យាល័យប្រសូត្រ និងបានប្រឡងឌីប្លូមជាប់។ ក្រោយមកខ្ញុំបានឈប់រៀនដោយសារមានបាតុកម្មប្រឆាំងនឹងរដ្ឋប្រហាររបស់ លន់ នល់ ទម្លាក់សម្តេចព្រះនរោត្តម សីហនុ នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ហើយសាលាបានបិទ។ ប្រសិនបើសិស្សចង់រៀនបន្តគឺត្រូវឡើងទៅរៀននៅក្រុងស្វាយរៀង។ នៅចុងឆ្នាំ១៩៧០ តាខសា និងប្រពន្ធរបស់គាត់យាយសាអែម ត្រូវជាបងប្អូនរបស់ សោម ភឹម ដែលធ្វើការនៅមន្ទីរស្រុកបានចុះមកឃោសនានៅតាមភូមិ ឃុំ ជាញឹកញាប់ឱ្យប្រជាជនដើរតាមសម្តេចឪ ហើយគាត់ក៏បានជ្រើសរើសខ្ញុំឱ្យចូលធ្វើពេទ្យជាមួយកងទ័ពបដិវត្តន៍ខ្មែរក្រហមដែលប្រឆាំងនឹងរបប លន់ នល់ ដែរ។ ខ្ញុំបានសុំការអនុញ្ញាតពីឪពុកម្តាយខ្ញុំ និងប្រាប់គាត់ថា ខ្ញុំចេញទៅធ្វើពេទ្យ ហើយក្នុងចំណោមអ្នកចូលបដិវត្តន៍ស្របាលខ្ញុំគឺខ្ញុំមានអាយុច្រើនជាងគេ។ ដំបូងខ្ញុំចូលធ្វើការនៅអង្គភាពនារីឃុំសំបួរ ដែលបានផ្លាស់ទីតាំងទៅនៅភូមិឈើទាលវាល ឃុំគគីសោម ស្រុកស្វាយទាប ខេត្តស្វាយរៀង ដែលមាន តាគង់ និង តាម៉ាញ គឺជាគណៈឃុំ ចំណែកឃុំសំបួរចាស់ដែលឪពុកម្តាយខ្ញុំរស់នៅគឺរដ្ឋាភិបាល លន់ នល់ នៅគ្រប់គ្រងដដែល។ ការងាររបស់ខ្ញុំគឺដើរស្រង់ឈ្មោះប្រជាជន និងឃោសនាប្រាប់ប្រជាជនឱ្យចូលធ្វើបដិវត្តន៍ប៉ុន្តែមុនចេញទៅឃោសនា គឺតាខសា និងយាយ សាអែម បានបង្រៀនខ្ញុំរយៈពេល៤ទៅ៥ថ្ងៃ។ ការឃោសនាពេលនោះបានបែងចែកជាពីរក្រុម គឺក្រុមយុវជនមានមេឃុំដឹកនាំ ហើយខាងនារីមាននារីនៅក្នុងឃុំដឹកនាំ។ ខ្ញុំហូបបាយនៅផ្ទះ តាខសា និងយាយ សាអែម តែម្តងដោយមិនត្រឡប់មកផ្ទះវិញទេ នៅពេលខ្ញុំចេញទៅឃោសនា។ ពេលខ្ញុំ



ឆាយ ធឿន រស់នៅភូមិទួលអង្គប់ ឃុំសំបួរ ស្រុកស្វាយទាប ខេត្តស្វាយរៀង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ចេញទៅឃោសនាម្តងៗមានមនុស្សច្រើនណាស់បានស្ម័គ្រចិត្តចូលរួមជាមួយបដិវត្តន៍ខ្មែរក្រហម។ ខ្ញុំធ្វើការនៅអង្គភាពនារីបានរយៈពេល៣ខែ ខាងស្រុកក៏ប្រមូលយុវជនយុវនារីឱ្យទៅនៅភូមិណែង ដើម្បីបញ្ជូនឱ្យឡើងទៅរៀនពេទ្យនៅតំបន់២៣ ដែលមានទីតាំងនៅក្នុងខេត្តព្រៃវែង។ ពេលនោះ មានសិស្សស្រីនិងប្រុសប្រមាណ៤០នាក់ និងមានគ្រូជនជាតិវៀតណាមដែលចេះនិយាយភាសាខ្មែរបង្រៀនពីវិធីព្យាបាលជំងឺទូទៅ និងបង្រៀនពីរបៀបរុំរបួសដល់អ្នកជំងឺ។ ក្រៅពីគ្រូជនជាតិវៀតណាម ក៏មានគ្រូជនជាតិខ្មែរដែរ។ ខ្ញុំចូលរៀននៅម៉ោង៧ព្រឹក ហើយសម្រាកនៅម៉ោង១១ ដើម្បីហូបបាយ។ នៅពេលល្ងាចយើងពិភាក្សាពីមេរៀនពេទ្យ។ ជួនកាលមានមេរៀនច្រើន គឺខ្ញុំត្រូវរៀននៅពេលយប់ទៀត។ ខ្ញុំរៀនរយៈពេល៣ខែ ក៏ចេះចាក់ថ្នាំ និងរុំរបួសដល់អ្នកជំងឺ ទើបត្រឡប់មកធ្វើការនៅមន្ទីរពេទ្យស្រុកប្រសូត្រដែលខ្មែរក្រហមបានរៀបចំថ្មី ព្រោះនៅឆ្នាំ១៩៧២ កងទ័ពបដិវត្តន៍ខ្មែរក្រហមបានរំដោះបានទីប្រជុំជនប្រសូត្រ។

ខ្ញុំព្យាបាលឱ្យកងទ័ពបដិវត្តន៍ខ្មែរក្រហមដែលរងរបួសដោយសារវាយប្រយុទ្ធជាមួយកងទ័ពលន់ នល់ នៅក្រុងស្វាយរៀង និងប្រជាជននៅតាមភូមិមួយចំនួន។ នៅពេលនោះ មានប្រធានពេទ្យឈ្មោះ ហ៊ុល ចំណែកប្រធានក្រុមខ្ញុំឈ្មោះ ឈិត និង ឆាំ។ ពេលធ្វើពេទ្យ ខ្ញុំបានមកលេងម្តាយខ្ញុំនៅព្រៃទទឹង ព្រោះម្តាយខ្ញុំត្រូវខ្មែរក្រហមជម្លៀសចេញពីភូមិកំណើតនៅព្រៃអង្គប់ទៅនៅព្រៃទទឹង។

ខ្ញុំធ្វើពេទ្យនៅស្រុកប្រសូត្រដល់ឆ្នាំ១៩៧៤ ទើបអង្គភាពដកខ្ញុំឱ្យទៅធ្វើពេទ្យនៅអង្គភាពទ័ពនារីភូមិភាគបូព៌ា ក្រោមការដឹកនាំរបស់ឈ្មោះ ទាញ។ ទាញ បានបង្ហាត់យុទ្ធសាស្ត្រទ័ពដល់យុទ្ធនារីដើម្បីត្រៀមវាយនៅសមរភូមិ ដែលមាននារីទាំងអស់៣០០នាក់ ស្មើនឹងមួយវរសេនាតូច ដែលមានទីតាំងនៅផ្តៅ ក្នុងខេត្តកំពង់ចាម។ ខ្ញុំហ្វឹកហាត់ពីរបៀបដោះសោកាំភ្លើង ហើយពេលកំពុងហ្វឹកហាត់ ខ្ញុំទទួលបានព័ត៌មានថាកងទ័ពខ្មែរក្រហមវាយយកបានទីក្រុងភ្នំពេញ។ នៅឆ្នាំ១៩៧៦ ទើបខ្មែរក្រហមបានបញ្ជូនខ្ញុំ និងយុទ្ធនារីទៅក្រុងភ្នំពេញ ហើយបែងចែកកម្លាំងមួយចំនួនឱ្យទៅធ្វើការនៅតាមរោងចក្រ ចំណែកខ្ញុំទៅធ្វើការនៅរោងចក្រក្រឡឹងនៅទួលគោក ម្តុំផ្ទះរបស់ ឌុក រ៉ាស៊ី និងមានប្រធានរោងចក្រឈ្មោះ ហួរ ដែលកូនកាត់ចិននៅខេត្តកំពត។ រោងចក្រនោះក៏មានក្រឡឹងខ្នៅកាំភ្លើងដែរ។ ពេលខ្ញុំធ្វើការហើយ ឈឺ អង្គភាពបញ្ជូនខ្ញុំទៅព្យាបាលនៅពេទ្យព្រះកេតុមាលា។ នៅថ្ងៃទី៣០ ខែសីហា ឆ្នាំ១៩៧៦ អង្គភាពបានរៀបការឱ្យខ្ញុំតាមការស្នើរបស់ប្តីខ្ញុំឈ្មោះ ប៊ុត សីហា គឺជាប្រធានផ្នែកក្រឡឹងនៅរោងចក្រជាមួយគ្នា និងត្រូវជាក្មួយបង្កើតរបស់ចក្រី (ចាន់ ចក្រី)។ ថ្ងៃរៀបការនោះមានទាំងអស់៣គូ រួមទាំងខ្ញុំ។ ចំណែកកម្មវិធីគឺគណៈអធិបតីឡើងរៀបរាប់ពីប្រវត្តិរូបរបស់សាមីខ្លួនប្រុសនិងស្រី បន្ទាប់មកទើបឱ្យសាមីខ្លួនចាប់ដៃគ្នា ហើយឡើងប្តេជ្ញាចំពោះមុខគណៈអធិបតី និងអ្នកចូលរួមទាំងអស់ដែលភាគច្រើនកម្មករនៅរោងចក្រ។

នៅចុងឆ្នាំ១៩៧៦ ខ្មែរក្រហមបានបញ្ជូនខ្ញុំទៅរៀនផលិតរំសេវនៅចម្ការដូង ដែលមានទីតាំងនៅសាលាកសិកម្មចម្ការដូង ដែលមាន តាចាយ គឺជាអ្នកបង្រៀន។ តាចាយ មានវ័យចាស់ ចំណែកប្រពន្ធរបស់គាត់នៅក្មេង ហើយគាត់ក៏ស្រឡាញ់ចូលចិត្តខ្ញុំដែរ។ ខ្ញុំមើលតាចាយផ្សំធ្វើរំសេវដោយផ្ទាល់តែម្តង ដោយមិនមានសៀវភៅកត់ត្រាទេ។ រយៈពេលមួយសប្តាហ៍ឬដប់ថ្ងៃ ទើបខ្ញុំទៅជួបប្តីខ្ញុំម្តង ហើយពេលខ្លះប្តីរបស់ក៏មកដេកនៅកន្លែងខ្ញុំធ្វើការនៅចម្ការដូង។ នៅថ្ងៃមួយប្រធានរោងចក្របានប្រាប់កម្មករថា តាលេខ២ នឹងចុះមកមើលកន្លែងផលិតរំសេវ បន្ទាប់មកខ្ញុំក៏ឃើញតាលេខ២ដែលមានមាឌធំសប្បុរស ជាមួយកងការពាររបស់គាត់ម្នាក់បានមកដល់កន្លែងខ្ញុំធ្វើការ។ តាលេខ២មិនបាននិយាយជាមួយកម្មករនៅកន្លែងផលិតរំសេវទេ គឺគាត់ដើរមើលនៅតាមបន្ទប់ធ្វើរំសេវរយៈពេល១៥នាទី និងងក់ក្បាលដាក់កម្មករ រួចហើយក៏ចេញទៅវិញ។ បន្ទាប់ពីតាលេខ២ចេញផុត ទើប តាចាយ ប្រាប់ខ្ញុំថា តាលេខ២ គឺជា នួន ជា។

នៅពាក់កណ្តាលឆ្នាំ១៩៧៧ រោងចក្របានដកខ្ញុំ

ពីកន្លែងផលិតរំសេវឱ្យមកធ្វើនៅរោងចក្រក្រឡឹង នៅទួលគោក ជាមួយប្ដីរបស់ខ្ញុំវិញ ដោយសារខ្ញុំមានផ្ទៃពោះ៤ខែ។ ពេលមកដល់រោងចក្រក្រឡឹង ប្រធានរោងចក្រមិនឱ្យខ្ញុំធ្វើការទេ គឺឱ្យនៅផ្ទះ ហើយដល់ម៉ោងហូបអាហារ ខ្ញុំទៅហូបបាយជាមួយកម្មករ។ ក្រោយមក ខ្ញុំឮប្ដីខ្ញុំនិយាយថា ពូរបស់គាត់ (ចក្រី) ចង់ទៅវៀតណាមដែរ ប៉ុន្តែទៅមិនរួច ហើយក្រោយមកត្រូវអង្គការចោទប្រកាន់ និងចាប់ខ្លួន។ ខ្ញុំក៏បានទាមទារប្ដីរបស់ខ្ញុំទៅលេងផ្ទះម្ដង ប៉ុន្តែប្ដីខ្ញុំឆ្លើយថា ទៅធ្វើអ្វី បើស្រុកមិនស្រួល។ ប្ដីខ្ញុំបានប្រាប់ខ្ញុំថា «បើខ្ញុំបែកពីឯងទៅ គឺដឹងថាខ្ញុំស្លាប់ហើយ» ស្រាប់តែវេលាយប់ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ១៩៧៧ ខ្មែរក្រហមមកហៅប្ដីខ្ញុំទៅប្រជុំ ហើយបាត់ខ្លួនតែម្ដង។ ខ្ញុំបានសួរឈ្មោះ ខាត់ មកពីខាងភូមិភាគនិរតីដែលស្នាក់នៅក្បែរខ្ញុំអំពីដំណឹងប្ដីរបស់ខ្ញុំ ហើយគាត់ប្រាប់ថា ទៅធ្វើការ។ រំលងបានពីរថ្ងៃ គឺថ្ងៃទី៣០ ខែកក្កដា ឆ្នាំ១៩៧៧ នីសារបានបើករថយន្តមក និងហៅខ្ញុំឱ្យទៅតាមប្ដីរបស់ខ្ញុំ ដោយមិនចាំបាច់យករបស់របរទៅជាមួយទេ។ អ្នកបើករថយន្តបានដឹកខ្ញុំមកដាក់នៅច្បារអំពៅ ដោយប្រាប់ខ្ញុំថាប្ដីខ្ញុំធ្វើការនៅច្បារអំពៅ។ ខ្ញុំដាំដំណាំនៅច្បារអំពៅជាមួយប្រពន្ធកម្មាភិបាលខ្មែរក្រហមជាច្រើននាក់ទៀត ហើយខ្ញុំក៏មិនដែលឃើញប្ដីរបស់ខ្ញុំដែរ។ ថ្ងៃមួយប្រធានអង្គភាពនៅច្បារអំពៅបានហៅប្រពន្ធកម្មាភិបាលខ្មែរក្រហមទៅប្រជុំ លើកលែងតែខ្ញុំដែលមិនបានហៅ។ បន្ទាប់ពីប្រជុំចប់ នារីម្នាក់នៅខេត្តពោធិ៍សាត់ដែលមានឪពុកម្ដាយគឺជាកម្មាភិបាលខ្មែរក្រហមបានមកលួចខ្សឹបប្រាប់ខ្ញុំថា ប្ដីឯងទៅបាត់ហើយ ហើយគាត់ផ្ដាំថា បើកាលណាគេមកប្រាប់ខ្ញុំថា នាំខ្ញុំទៅជួបគាត់ សូមកុំឱ្យខ្ញុំទៅតាមឱ្យសោះ»។

នៅខែតុលា ឆ្នាំ១៩៧៧ មានរថយន្តហ្ស៊ីបមកដឹកប្រពន្ធកម្មាភិបាល និងខ្ញុំចេញពីច្បារអំពៅ ដោយប្រាប់ថាទៅជួបប្ដីដូច្នេះមិនបាច់យកអីវ៉ាន់ទៅទេ ហើយខ្ញុំក៏មិនហ៊ានប្រកែកដែរ។ អ្នកបើករថយន្តបានដឹកគាត់តាខ្មៅ មកឈប់នៅផ្ទះមួយកន្លែងនៅព្រែកហូរ ដែលជាកន្លែងសម្រាប់ឱ្យកូនប្រពន្ធកម្មាភិបាល និងយោធាស្នាក់នៅ។ ខ្ញុំត្រូវចេញទៅដាំដំណាំនៅម៉ោង៧ព្រឹក ហើយសម្រាកនៅម៉ោង១១ ដោយមានប្រធានគ្រប់គ្រងឈ្មោះ សុខ។ នៅកន្លែងខ្ញុំធ្វើការមានប្រពន្ធកម្មាភិបាលមកពីភូមិភាគបូព៌ា និងបស្ចិមចំនួន១៣នាក់។ ខ្ញុំធ្វើការគ្មានពេលឈប់សម្រាកនៅពេលថ្ងៃ ហើយថ្ងៃខ្លះខ្ញុំត្រូវធ្វើការរហូតដល់ម៉ោង១០យប់ទៀត។ រៀងរាល់យប់ អ្នកគ្រប់គ្រងឱ្យខ្ញុំ និងនារី១៣នាក់ទៀតដេកនៅលើផ្ទះថ្មជាន់ខាងលើរួចហើយចាក់សោ មិនឱ្យដើរចេញក្រៅឡើយ។ ខ្ញុំលំបាកវេទនាខ្លាំងណាស់ ហើយរបបអាហារមានតែពីរពេលប៉ុណ្ណោះ។ នៅពេលប្រជុំ ប្រធានគ្រប់គ្រងបានប្រាប់ថា ខាងបូព៌ាក្បត់ដូច្នេះសូមសមមិត្តកុំយកគំរូតាម។ ខ្ញុំធ្វើការទាំងមានផ្ទៃពោះរហូតខ្ញុំឈឺពោះឆ្លងទន្លេដោយមានពេទ្យឆ្មបឈ្មោះ ថាច ជួយបង្កើតកូនឱ្យខ្ញុំ។ បន្ទាប់ពីសម្រាលកូនរួច ប្រធានចម្ការនៅតាខ្មៅឱ្យខ្ញុំសម្រាកចំនួន១៥ថ្ងៃ។ បន្ទាប់មក ទើបខ្ញុំយកកូនខ្ញុំឱ្យយាយៗមើលថែទាំ រួចហើយខ្ញុំចេញទៅធ្វើការ។ ប៉ុន្តែសំណាងល្អប្រធានអង្គភាពចម្ការ ស្រឡាញ់កូនខ្ញុំដូចកូនបង្កើតដែរ។ នៅឆ្នាំ១៩៧៨ កូនខ្ញុំដែលមានអាយុជាងមួយឆ្នាំ បានធ្លាក់ខ្លួនឈឺក្អួត ហើយក៏ស្លាប់ទៅ។

ពេលកងទ័ពវៀតណាមវាយចូលមក នៅឆ្នាំ១៩៧៩ ខ្មែរក្រហមបានកៀរខ្ញុំ និងក្រុមខ្ញុំទាំង១៣នាក់ទៅដល់ខេត្តបាត់ដំបង។ ប្រសិនរណារត់គេចខ្លួនគឺខ្មែរក្រហមបាញ់ចោលតែម្ដង។ ខ្ញុំទៅរែកដីនៅស្រះតាព្រហ្ម ក៏បានជួបមិត្តភក្តិខ្ញុំម្នាក់ដែលធ្វើជាប្រធានកងនៅទីនោះ។ មិត្តភក្តិខ្ញុំតែងយកអាហារនិងដំឡូងដែលដាំបានមកឱ្យខ្ញុំហូប។ ក្រោយមក ប្រធានកងនារីខ្ញុំបានកៀងខ្ញុំបន្តទៅដល់ព្រំដែន ក៏ស្រាប់តែមានអ្នកលបកាប់ប្រធានកងនោះស្លាប់។ ខ្ញុំបន្តដំណើរទៅមុខទៀតក៏ជួបតាចាស់ម្នាក់ ហើយគាត់ក៏ប្រាប់ឱ្យខ្ញុំត្រឡប់មកស្រុកកំណើតវិញ ព្រោះកំពុងតែមានការវាយប្រយុទ្ធគ្នានៅតាមភ្នំ។ ក្រុមខ្ញុំបានស្នាក់នៅជាមួយតានោះ រហូតកងទ័ពវៀតណាមចូលមកដល់ ទើបត្រឡប់មកវិញ ហើយក្រុមរបស់ខ្ញុំ១៣នាក់ គឺនៅតែ៣នាក់ប៉ុណ្ណោះរួមទាំងខ្ញុំ។ នៅខែមិថុនា ឆ្នាំ១៩៧៩ ទើបខ្ញុំមកដល់ភូមិកំណើត និងជួបជុំឪពុកម្ដាយ និងបងប្អូនវិញ។

# អ៊ុក សៀត ៖ រត់ភៀសខ្លួនទៅនៅជំរំក្នុងខេត្ត តាយនីញ ប្រទេសវៀតណាម

សោម ប៊ុនថន

នៅពេលកងទ័ពវៀតណាមវាយចូលមកខេត្តស្វាយរៀងនៅចុងឆ្នាំ១៩៧៧ ខ្ញុំនិងក្រុមគ្រួសារបានរត់ភៀសខ្លួនទៅនៅជំរំនៅក្នុងប្រទេសវៀតណាម ព្រោះខ្លាចខ្មែរក្រហមចាប់ខ្លួន។ ខ្ញុំឈ្មោះ អ៊ុក សៀត កើតនៅឆ្នាំ១៩៥០ នៅភូមិតាប៉ោង ឃុំសង្កែ ស្រុករំដួល ខេត្តស្វាយរៀង។ ខ្ញុំមានប្រពន្ធឈ្មោះ ពីន សារ៉ាន អាយុប្អូនខ្ញុំបួនឆ្នាំ និងមានកូនទាំងអស់១១នាក់។ កូនខ្ញុំស្លាប់អស់៧នាក់នៅក្នុងរបបខ្មែរក្រហម ហើយសព្វថ្ងៃនៅរស់តែ៤នាក់ប៉ុណ្ណោះ។



អ៊ុក សៀត រស់នៅភូមិតាប៉ោង ឃុំសង្កែ ស្រុករំដួល ខេត្តស្វាយរៀង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅពេលខ្ញុំអាយុបាន៨ឆ្នាំ ខ្ញុំបានចូលរៀននៅសាលាពាមអំពិល ដែលមានចម្ងាយ៥គីឡូម៉ែត្រពីផ្ទះរបស់ខ្ញុំ។ ខ្ញុំរៀនរយៈពេល៥ឆ្នាំ គឺដល់ថ្នាក់ទី១០ ពីសង្គមក៏ឈប់រៀន។ ខ្ញុំរៀនបានត្រឹមថ្នាក់ទី១០ ដោយសារខ្ញុំរៀនត្រួតថ្នាក់។ បន្ទាប់ពីឈប់រៀន ខ្ញុំមកជួយធ្វើស្រែឪពុកម្តាយខ្ញុំរហូតដល់ឆ្នាំ១៩៦៦ ទើបខ្ញុំទៅបួសជានេន នៅវត្តពាមអំពិល។ ខ្ញុំបួសបានរយៈពេល២ឆ្នាំក៏សឹកវិញ ដោយសារខ្ញុំឈឺញឹកញាប់។ ខ្ញុំនៅផ្ទះធ្វើស្រែជាមួយឪពុកម្តាយ។ នៅឆ្នាំ១៩៧០ ខ្ញុំបានស្ម័គ្រចិត្តចូលរួមជាមួយរណសិរ្ស ដោយខ្ញុំជិះកង់ពីផ្ទះរបស់ខ្ញុំនៅភូមិតាប៉ោងទៅស្នាក់ការជាប់ក្បាលស្ពានកំពង់ត្រាបក្នុងស្រុករមាសហែក ខេត្តស្វាយរៀង ដោយមានក្រុមរណសិរ្ស (សំដៅលើសមាជិក រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា បង្កើតឡើងដោយសម្តេចព្រះនរោត្តម សីហនុ នៅទីក្រុងប៉េកាំង នៅថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៧០។ សមាជិករបស់បក្សកុម្មុយនិស្តកម្ពុជា គឺជាសមាជិករបស់រដ្ឋាភិបាលនេះ) រង់ចាំទទួល និងកត់ឈ្មោះ។ ខ្ញុំនៅជាមួយរណសិរ្សបានរយៈពេលតែ៣ថ្ងៃប៉ុណ្ណោះក៏ជិះកង់ត្រឡប់មកផ្ទះវិញ ដោយសារការរស់នៅលំបាក។

មួយរយៈក្រោយមក ខ្ញុំរៀបការប្រពន្ធ។ យើងរៀបចំពិធីកាត់សក់នៅលើផ្ទះឈើប្រក់ក្បឿង៣ខ្នង ដែលឪពុកម្តាយខ្ញុំសាងសង់ ដើម្បីឱ្យកុំយន្តហោះដែលហោះមកឆ្វែលលើភូមិរបស់ខ្ញុំជាញឹកញាប់ឃើញ ព្រោះខ្លាចមានការទម្លាក់គ្រាប់បែក។ មិនយូរប៉ុន្មាន កងកម្លាំងបដិវត្តន៍ខ្មែរក្រហមបានចូលមកបោះជំរំតាមគុម្ពោធព្រៃក្នុងភូមិឃុំស្រុករបស់ខ្ញុំ

ហើយបានលបចាប់អ្នកដែលធ្វើគិញឱ្យទាហាន លន់ នល់ និង ទាហាន លន់ នល់ យកមកឃុំឃាំងនៅផ្ទះឪពុកក្មេករបស់ខ្ញុំ ព្រោះឪពុកក្មេកខ្ញុំគឺជាប្រធានភូមិចំណតត្រាច ស្ថិតនៅក្នុងឃុំថ្នាធ្នង់ ស្រុករំដួល ខេត្តស្វាយរៀង។ ឈ្លបខ្មែរក្រហមបានឱ្យឪពុកក្មេកនិងគ្រួសារខ្ញុំចេញពីផ្ទះ ហើយវាយសួរចម្លើយគិញនិងទាហាន លន់ នល់ ទាំងនោះ។ គិញនិងទាហាន លន់ នល់ មួយចំនួនត្រូវឈ្លបខ្មែរក្រហមដោះលែង ហើយមួយចំនួនទៀតយកទៅវាយសម្លាប់ចោលនៅតាមដំបូក។

នៅពេលខ្មែរក្រហមទទួលជ័យជម្នះនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានជម្លៀសប្រជាជនថ្មីមកនៅភូមិតាប៉ោង។ ខ្មែរក្រហមបានតាមដានប្រជាជនថ្មីទាំងនោះជាប្រចាំ និងបានឃោសនាឱ្យប្រជាជនថ្មីទាំងនោះប្រាប់អំពីតួនាទី និងឋានន្តរស័ក្តិពិតរបស់ខ្លួនពីសង្គមចាស់ដើម្បីបញ្ជូនឱ្យទៅធ្វើការកន្លែងដើមវិញ ប៉ុន្តែតាមពិតគឺខ្មែរក្រហមយកអ្នកទាំងនោះទៅសម្លាប់នៅមន្ទីរសន្តិសុខកំពង់ពពិល។ ចំណែកប្រជាជនដែលគ្មានតួនាទីក្នុងសង្គមចាស់ ខ្មែរក្រហមឱ្យរស់នៅក្នុងភូមិតាប៉ោងជាមួយខ្ញុំដដែល។ ប្រធានភូមិតាប៉ោង ឈ្មោះ ពីន ផុន ត្រូវជាឪពុកក្មេករបស់ខ្ញុំ ហើយអនុភូមិឈ្មោះ ណន។ នៅឆ្នាំ១៩៧៦ ខ្មែរក្រហមបានរំសាយឪពុកខ្ញុំពីប្រធានភូមិឱ្យមកជាប្រជាជនធម្មតា ហើយរៀបចំទៅជាសហករណ៍ដោយមានឈ្មោះ ប៉ែន ថន ដឹកនាំ។ ចំណែក តាណន អនុភូមិដែលត្រូវជាឪពុករបស់ ប៉ែន ថុន ផ្លាស់ទៅធ្វើជាប្រធានរោងបាយសហករណ៍។ ប្រធានសហករណ៍ចាត់តាំងឱ្យខ្ញុំនៅកងធ្វើជី។ ខ្ញុំត្រូវដើរប្រមូលលាមកមនុស្សនៅតាមផ្ទះមកលាយធ្វើជីដាក់ស្រែ ចំណែកផលស្រូវដែលទទួលបានគឺប្រមូលយកទៅដាក់នៅក្នុងសហករណ៍។ ទោះបីផលស្រូវប្រជាជនធ្វើបានច្រើនប៉ុន្តែការហូបចុករបស់ប្រជាជននៅក្នុងសហករណ៍មិនគ្រប់គ្រាន់ឡើយ។ ខ្ញុំមិនដឹងថា តាណន ប្រធានរោងបាយសហករណ៍ធ្វើតាមបញ្ជាពីថ្នាក់លើបុយ៉ាងណាទេ។

នៅពាក់កណ្ដាលឆ្នាំ១៩៧៥ ខ្ញុំទៅរកត្រីនៅព្រែកក្នុងភូមិតាប៉ោងជិតបន្ទាយដែលទាហានធីវគីធ្លាប់ចូលមកបោះទីតាំងក៏ឃើញគ្រាប់បែកក្រឡាទាបពណ៌បៃតង ហើយមុនត្រឡប់មកផ្ទះវិញខ្ញុំចាប់គ្រវែងគ្រាប់បែកនោះក៏ផ្ទុះបណ្ដាលឱ្យរងរបួសបងរបស់ខ្ញុំ និងអ្នកភូមិតាប៉ោងម្នាក់ទៀតធ្លាយពោះ។ សន្តិសុខឈ្មោះ សារិន បានជិះកង់មកដឹកខ្ញុំយកទៅអប់រំ។ ទៅដល់មុខមន្ទីរសន្តិសុខស្រុកសំរោង ឬមន្ទីរសន្តិសុខទួលព្រះ ទើបសន្តិសុខគុកចងស្លាបសេក និងយកក្រមារុំមុខខ្ញុំរួចបណ្ដើរចូលគុក។ ចូលដល់បន្ទប់ឃុំឃាំង សន្តិសុខបានឱ្យខ្ញុំដេកលើគ្រែគើយធ្វើយឈើ និងចងជើងព្រោះខ្លាចលួចរត់។ ខ្ញុំដេកនៅមន្ទីរឃុំឃាំងបានរយៈពេលមួយយប់ ទើបសន្តិសុខស្រាយក្រមារុំមុខខ្ញុំចេញ។ ខ្ញុំឃើញអ្នកទោស១០នាក់ជាប់ចំណងដូចខ្ញុំដែរ។ អ្នកទោសទាំងនោះ រួមមានប្រជាជនជម្លៀសមកថ្មី និងប្រជាជននៅក្នុងស្រុកសំរោង។ រយៈពេល៣ថ្ងៃក្រោយមកទៀត ទើបសន្តិសុខគុកហៅខ្ញុំទៅសួរចម្លើយនៅបន្ទប់មួយឆ្ងាយពីកន្លែងឃុំឃាំង។ ឆ្មាំគុកបានសួរខ្ញុំថា មូលហេតុអ្វីបានជាបោកគ្រាប់បែក? ខ្ញុំឆ្លើយថា បានឃើញក្មេង២ទៅ៣នាក់ យកគ្រាប់បែកនោះទៅគប់លេង ប៉ុន្តែមិនផ្ទុះ។ ឃើញដូច្នេះ ខ្ញុំក៏ទៅយកគ្រាប់បែកនោះគ្រវែងចោលក៏ផ្ទុះតែម្ដង។ ខ្ញុំឆ្លើយតាមត្រង់ ហើយសន្តិសុខគុកក៏មិនបានវាយធ្វើទារុណកម្មខ្ញុំដែរ។ បន្ទាប់ពីសួរចម្លើយរួច ឆ្មាំគុកបញ្ជូនខ្ញុំទៅកន្លែងអប់រំដែលនៅទីនោះឃើញអ្នកទោសប្រមាណជាង១០០នាក់ ដែលមានប្រធានមន្ទីរសន្តិសុខឈ្មោះ ឈុំ។ ខ្ញុំជាប់ឃុំឃាំងបានរយៈពេលមួយខែ ប្រធានមន្ទីរសន្តិសុខហៅឪពុកក្មេកខ្ញុំ ទៅយកខ្ញុំត្រឡប់មកផ្ទះវិញ។

នៅឆ្នាំ១៩៧៦ ខ្ញុំមកធ្វើការនៅរោងបាយសហករណ៍។ ថ្ងៃមួយខ្ញុំ និងប្អូនថ្លៃឈ្មោះ ពីន ហេង ទៅបេះផ្លែដូងនៅផ្ទះឪពុកក្មេកខ្ញុំនៅភូមិចំណតត្រាច ឃុំថ្នាធ្នង់ ស្រុករំដួល យកមកសហករណ៍។ ពេលខ្ញុំបេះផ្លែដូងរួច និងរៀបចំត្រឡប់មកវិញស្រាប់តែ

ឈ្លបភូមិឃើញ ហើយចាប់ខ្ញុំនិងប្អូនថ្លៃបញ្ជូនទៅឃុំឃាំងនៅឃុំថ្នាធ្នង់។ នៅថ្ងៃបន្ទាប់ ប្រពន្ធរបស់តាភឹម ដែលធ្វើការនៅឃុំថ្នាធ្នង់មានទីតាំងនៅវត្តញ៉ុកឱ្យនីរសារទៅប្រាប់ តាភឹម គឺជាប្រធានឃុំសង្កែ ថា «ឈ្លបចាប់ប្អូនបងហើយ» ទើប តាភឹម ចាត់តាំងឱ្យឈ្មោះរ៉ន ប្រធានឈ្លបនៅឃុំសង្កែទៅធានាយកខ្ញុំ និងប្អូនថ្លៃខ្ញុំមកវិញ ព្រោះខ្ញុំនឹងប្រពន្ធរបស់ តាភឹម ត្រូវជាបងប្អូនជីដូនមួយ។ ខ្ញុំមកដេកនៅឃុំសង្កែស្ថិតនៅវត្តសង្កែមួយយប់ ទើបត្រឡប់ទៅផ្ទះវិញ។

នៅចុងឆ្នាំ១៩៧៧ ខ្មែរក្រហមបានជម្លៀសប្រជាជនទៅទិសខាងលិច ព្រោះវៀតណាមបានវាយចូលមក។ ខ្ញុំបានរត់គេចខ្លួនទៅដល់ឃុំម៉ឺនជ័យ ស្រាប់តែរថក្រោះ និងកាំភ្លើងធំវៀតណាមផ្លោងគ្រាប់កាត់ពីមុខ ទើបខ្ញុំនាំប្រពន្ធកូននិងឪក្មេកគេចទៅខាងត្បូង ហើយត្រឡប់មកផ្ទះក្នុងភូមិតាប៉ោងវិញ ចំណែកគ្រួសារអ្នកភូមិផ្សេងទៀតត្រូវខ្មែរក្រហមកៀរបន្តទៅទិសខាងលិច។ បន្ទាប់ពីកងទ័ពខ្មែរក្រហមចាកចេញទៅអស់ កងទ័ពវៀតណាមបានមកបោះទីតាំងនៅក្នុងសង្កាត់សង្កែ។ រយៈពេលជាងមួយខែក្រោយមក កងទ័ពវៀតណាមបានដកទ័ពត្រឡប់ទៅប្រទេសខ្លួនវិញ ប៉ុន្តែមុននឹងដកកងទ័ពវៀតណាមបានសួរខ្ញុំជាភាសាខ្មែរថា បងទៅតាមកងទ័ពវៀតណាម ឬនៅក្នុងភូមិនេះដដែល? ខ្ញុំឆ្លើយថា «បើបងទៅ ខ្ញុំក៏ទៅដែរ បើខ្ញុំនៅ អាពត សម្លាប់ខ្ញុំចោលហើយ មិនទុកទេ»។ កងទ័ពវៀតណាមភាគច្រើនគឺជាខ្មែរកម្ពុជាក្រោម និងចេះនិយាយភាសាខ្មែរច្បាស់។ ខ្ញុំបានចាប់គោទឹមជាមួយរទេះឱ្យក្រុមគ្រួសារជិះ។ ខ្ញុំនិងគ្រួសារ ព្រមទាំងប្រជាជនខ្មែរជាច្រើនគ្រួសារទៀតបររទេះលើផ្លូវជាតិលេខ១៣ទៅតាមក្រោយកងទ័ពវៀតណាមសំដៅទៅប្រកព្រំដែនបោះមន។ យើងធ្វើដំណើរចូលដល់ទឹកដីវៀតណាមចម្ងាយប្រមាណ២គីឡូម៉ែត្រក៏ឈប់សម្រាក ចំណែកកងទ័ពវៀតណាមបានបន្តដំណើរទៅបន្ទាយរបស់ខ្លួន។ នៅពេលទៀបភ្លឺ ប្រជាជនវៀតណាម ដែលដេកយាមស្រូវទុំក្បែរនោះ កំពុងតែដេកគ្នាកោកកាក កងទ័ពខ្មែរក្រហមដែលបន្ទំលាក់ខ្លួនក្នុងចំណោមប្រជាជនខ្មែររាប់រយនាក់ដែលរត់ភៀសខ្លួននោះ បាញ់ប្រជាជនវៀតណាមស្លាប់អស់២នាក់។ ភ្លាមនេះកងទ័ពខ្មែរក្រហមឃើញភ្លើងរថយន្តរបស់វៀតណាមបើកមកពីទិសខាងកើតក៏ស្ទុះស្ទារ និងកៀរប្រជាជនខ្មែរមួយចំនួនត្រឡប់មកទិសខាងលិចសំដៅចូលក្នុងប្រទេសកម្ពុជាវិញ ព្រោះស្មានតែរថក្រោះរបស់កងទ័ពវៀតណាម ម្យ៉ាងទៀតកងទ័ពខ្មែរក្រហមមិនស្គាល់ទីតាំងភូមិសាស្ត្រក្នុងទឹកដីវៀតណាម។ ខ្ញុំនិងគ្រួសារបានរត់ទៅលាក់ខ្លួនរហូតកងទ័ពខ្មែរក្រហមចាកចេញអស់ ទើបខ្ញុំទឹមរទេះបរទៅទិសខាងកើតសំដៅទៅខេត្តតាយនីញ ប្រទេសវៀតណាម។ ប្រជាជនខ្មែរដែលត្រឡប់មកប្រទេសកម្ពុជាមួយចំនួនត្រូវខ្មែរក្រហមចាប់យកទៅសម្លាប់ និងមួយចំនួនទៀតបានគេចទៅរស់នៅជាមួយបងប្អូនដោយលាក់ព័ត៌មិនឱ្យខ្មែរក្រហមដឹងថាបានរត់ភៀសខ្លួនទៅប្រទេសវៀតណាមឡើយ។ ប្រសិនបើខ្មែរក្រហមដឹងថាប្រជាជនណាធ្លាប់រត់គេចខ្លួនទៅវៀតណាម នឹងយកទៅសម្លាប់ចោលមិនខាន។

ពេលខ្ញុំបររទេះចូលដល់ទីរួមខេត្តតាយនីញ វៀតណាមបានបើកអង្ករ និងឆ្នាំងឱ្យខ្ញុំនិងសមាជិកគ្រួសារដាំបាយហូប។ មួយសប្តាហ៍ក្រោយមក វៀតណាមបានបញ្ជូនខ្ញុំទៅរស់នៅជំរំនៅក្បាក់ស្ថិតនៅជាប់ជើងភ្នំមួយបាដែងជាភាសាវៀតណាម (ប្រែមកថាភ្នំយាយម៉ៅ) ជាមួយជនភៀសខ្លួនខ្មែររាប់ពាន់ទៀត។ វៀតណាមបានបើកអង្ករ៥គីឡូ ពោត៥គីឡូ ក្នុងមនុស្សម្នាក់ ក្រៅពីនោះបានបើកស្លឹកគ្រៃ ត្រី និងសាច់ឱ្យដែរ។ វៀតណាមបើករបបឱ្យជនភៀសខ្លួនជារៀងរាល់ខែ ហើយអ្នកដែលហូបមិនអស់មួយចំនួនបានយករបបឧបត្ថម្ភទាំងនោះទៅលក់ទៀតផង។ ប្រសិនបើជនភៀសខ្លួនខ្មែរណាចង់ធ្វើស្រែ និងដាំពោត វៀតណាមបានអនុញ្ញាត និងបើកពូជឱ្យដាំ។

ខ្ញុំរស់នៅជំរំក្នុងខេត្តតាយនីញរហូតដល់ថ្ងៃទី៧

ខែមករា ឆ្នាំ១៩៧៩ ពេលកងទ័ពវៀតណាមវាយរំដោះបានប្រទេសកម្ពុជា ខ្ញុំរួមទាំងជនភៀសខ្លួនមួយចំនួននៅក្នុងខេត្តនិញបានធ្វើដំណើរជាមួយកងទ័ពសាធារណរដ្ឋប្រជាមានិតកម្ពុជា មកនៅស្ពានអូរ ឡាំពិក ក្រុងភ្នំពេញ។ ចំណែកប្រពន្ធខ្ញុំនិងកូនម្នាក់រស់នៅក្នុងប្រទេសវៀតណាមដដែល។ ខ្ញុំស្នាក់នៅស្ពានអូរ ឡាំពិករយៈពេល៣ថ្ងៃ ក៏ត្រឡប់ទៅវៀតណាមដើម្បីនាំប្រពន្ធនិងកូនត្រឡប់មកប្រទេសកម្ពុជាវិញ។ ខ្ញុំនិងប្រពន្ធកូនបណ្ដើរកង់ដោយដាក់អង្ករពីលើរយៈពេលមួយថ្ងៃកាត់តាមបាវិតត្រឡប់មកស្រុកកំណើតវិញ។ ពេលខ្ញុំមកភូមិ ផ្ទះរបស់ខ្ញុំត្រូវខ្មែរក្រហមរុះរើអស់ ដូច្នេះខ្ញុំបានទៅស្នាក់ក្រោមដើមឈើនៅតាមវាលស្រែ។ មួយសប្ដាហ៍ក្រោយមក ទើបប្រជាជនដែលរត់ភៀសខ្លួនទៅប្រទេសវៀតណាមបានត្រឡប់មករស់នៅក្នុងភូមិបន្ថែមទៀត ហើយប្រជាជនបានបោះឆ្នោតឱ្យខ្ញុំធ្វើមេឃុំសង្កែ។ នៅឆ្នាំ១៩៨៤ រដ្ឋអំណាចជ្រើសរើសពលករពីភូមិ ដោយក្នុងមួយភូមិមានយុវជន៣នាក់ឱ្យចូលក-៥ ហើយខ្ញុំក៏ត្រូវបានស្រុកចាត់តាំងឱ្យចូលដែរ។ ខ្ញុំទៅកាប់ឆ្ការព្រៃនៅប៉ោយប៉ែតរយៈពេលមួយខែ បន្ទាប់មកទើបទៅនៅតាមជើងភ្នំម៉ាឡៃ និងជាប់អូរព្រំដែនថៃដោយខ្ញុំធ្វើជាប្រធានគ ដែលមានសមាជិក១០០នាក់។ នៅទីនោះខ្មែរក្រហមដាក់មីននៅតាមមាត់អូរក្នុងទំហំដី១ម៉ែត្របួនជ្រុង គឺដាក់២៥គ្រាប់។ ខ្ញុំធ្វើពលករនៅម៉ាឡៃរយៈពេល៣ខែ ក៏ត្រឡប់មកស្រុកកំណើតវិញ។ នៅឆ្នាំ១៩៨៥ ខ្ញុំលាឈប់ពីមេឃុំ និងមកប្រកបរបរធ្វើស្រែដើម្បីចិញ្ចឹមគ្រួសារ។



*ជនភៀសខ្លួនខ្មែរនៅវៀតណាម នៅឆ្នាំ១៩៧៧។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា/ ទីភ្នាក់ងារសារព័ត៌មានវៀតណាម)*

# គ្រូបង្រៀនកុមារនៅក្នុងរបបខ្មែរក្រហម

**ជាវ៉ារដ្ឋ មេត្តា**



គ្រូបង្រៀនកុមារនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)។ (ហ្គុនណា បឺយស្ត្រម/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ក្នុងរបបកម្ពុជាប្រជាធិបតេយ្យមិនមានសាលារៀនផ្លូវការទេ។ កុមារត្រូវបានបញ្ជូនឱ្យទៅរៀននៅក្រោមដើមឈើឬ នៅក្រោមផ្ទះប្រជាជន។ ខ្មែរក្រហមនិយាយថា«អង្គការគ្មានទេសញ្ញាបត្រ មានតែសញ្ញាឃើញ បើចង់បានបាក់អង បាក់ឌុប ត្រូវទៅយកនៅទំនប់ប្រឡាយ» ហើយថា«ការរៀនអក្សររៀនលេខមិនសំខាន់ទេ ការសំខាន់គឺការងារនិងចលនាបដិវត្តន៍» ។ ប្រព័ន្ធអប់រំដ៏ខ្សត់ខ្សោយមួយនេះ អនុញ្ញាតឱ្យសិស្សរៀនបានត្រឹមតែសរសេរ អាន និងគណិតវិទ្យាមូលដ្ឋានតែប៉ុណ្ណោះ ។

**ញាណ សារុំ**



ញាណ សារុំ គឺជាគ្រូបង្រៀនកុមារ។ ញាណ សារុំ រំឭកថា កាលរបបខ្មែរក្រហមមានសិស្សចំនួន១០០នាក់ប៉ុន្តែមានគ្រូបង្រៀនចំនួន២នាក់។ គ្រានោះខ្ញុំបង្រៀននៅស្រុកជីក្រែង ខេត្តសៀមរាប។

ក្នុងមួយថ្ងៃសិស្សតូចៗ រៀនជារៀងរាល់ថ្ងៃប៉ុន្តែប្រសិនបើសិស្សជំទង់វិញរៀនបានតែមួយម៉ោងទេ ក្រៅពីនេះ ទៅវែកដីនិងជីកប្រឡាយ។ ជួនកាលខ្ញុំដែលជាគ្រូបង្រៀនតែងប្តូរគ្នាទៅចល័តលើកទំនប់ម្តងម្នាក់ៗ នៅក្នុងភូមិខ្ញុំគឺជាប្រធានសហករណ៍ដឹកនាំ៧ភូមិដែលមានសិស្សមករៀនចំនួន៧ភូមិដែរ។ ខ្ញុំអ្នកមើលការខុសត្រូវពីលើគ្រូបង្រៀនទាំងអស់នោះ។ ចំណែកការហូបចុកក៏ពិបាកដែរ ខ្ញុំមិនសូវយល់សម័យខ្មែរក្រហម ភូមិគេខ្លះមានហូបចុកគ្រប់គ្រាន់ហើយភូមិខ្ញុំហូបបានតែបបរ។ ទោះបីខ្ញុំជាប្រធានសហករណ៍មើលការខុសត្រូវខាងបង្រៀនរីឯការហូបចុកតាមការរៀបចំរបស់ប្រធានសង្កាត់។

## ប្រាជ្ញ យ៉ន

*អាយុ៧៣ឆ្នាំ មានស្រុកកំណើតនៅ ឃុំព្រែកណ្តៀង ស្រុកពាមរក៍ ខេត្តព្រៃវែង។*



ប្រាជ្ញ យ៉ន ត្រូវបានបងប្រុសឈ្មោះ ប្រាជ្ញ អ៊ួន ចាត់តាំងឱ្យធ្វើការនៅមន្ទីរវប្បធម៌ដែលមានការបង្រៀនសិស្ស និង មើលការខុសត្រូវគ្រូបង្រៀនចំនួន៥នាក់។ ប្រាជ្ញា យ៉ន លើកឡើងថា«ខ្ញុំចាប់ផ្តើមចូលធ្វើការងារគ្រូបង្រៀនកុមារនៅឆ្នាំ១៩៧៥ ដោយរៀងរាល់ថ្ងៃខ្ញុំក្រោកម៉ោង៤ទៀបភ្លឺដើម្បីដឹកនាំកុមារទូលជីដាក់ស្រែ។ បន្ទាប់មកខ្ញុំបង្រៀនសិស្សរយៈពេល១ម៉ោងកន្លះទៅ២ម៉ោង ទើបដឹកនាំសិស្សទៅជម្រះស្មៅ ទៅដាំពោត លាយដីដំបូកធ្វើជីលើកប្រព័ន្ធភ្លឺស្រែ និង កាប់ដើមទន្ទ្រានខែត្រនៅឃុំព្រែកណ្តៀង។ ក្រោយមកឆ្នាំ១៩៧៦ សិស្សគ្រប់គ្នាមានចំនួន២០០នាក់តម្រូវឱ្យកាប់ព្រៃព្រោះកាលនោះក្នុងភូមិសម្បូរទៅដោយព្រៃនិងតម្រង់ប្រព័ន្ធផ្លូវក្នុងភូមិ។ នៅឆ្នាំ១៩៧៧ ខ្ញុំដឹកនាំកុមារទៅជាន់រហាត់ទឹកស្រែប្រាំង នៅខាងលិចភូមិព្រែកណ្តៀង ដែលរហាត់មួយគឺមានកុមារជាន់ចំនួន២នាក់ប៉ុន្តែការជាន់រហាត់ទឹកនេះគឺនឿយហត់ណាស់ព្រោះកុមារត្រូវជាន់ទាំងយប់ទាំងថ្ងៃធ្វើយ៉ាងណាស្រែមួយហិកតាឱ្យមានទឹកគ្រប់គ្រាន់ៗ កាលណាមានអ្នកចុះមកត្រួតពិនិត្យហើយឃើញស្រែមានទឹកគ្រប់គ្រាន់នោះយើងមិនត្រូវបានទិតៀនទេ»។

## សួស សុខុន

*ភេទស្រី មានអាយុ៦៣ឆ្នាំ មានស្រុកកំណើតនៅខេត្តកំពង់ឆ្នាំង។*



ឪពុកឈ្មោះ សួស ឆាយ និង ម្តាយឈ្មោះ ឡុង សារិន ហើយមានបងប្អូនបង្កើតចំនួន១០នាក់។ សព្វថ្ងៃបងប្អូន សួស សុខុន នៅរស់ចំនួន៣នាក់។ សួស សុខុន រៀនបានត្រឹមថ្នាក់ទី១២ ហើយឆ្នាំ១៩៧០ ឈប់រៀននៅពេលកើតមានរដ្ឋប្រហារឆ្នាំ១៩៧០។ ឆ្នាំ១៩៧៣ សម័យសង្គ្រាមជាមួយ លន់ នល់ ដើម្បីតស៊ូរំដោះវណ្ណៈពីរបបសក្តិភូមិ។ ឆ្នាំ១៩៧៥ សួស សុខុន ធ្វើជាគ្រូបង្រៀនកុមារ នៅឃុំកំពង់គគីស្រុកបរិបូណ៌ ដោយកាលនោះ គណៈឃុំឈ្មោះ អឿន និងឈ្មោះ សយ។ សួស សុខុន បង្រៀនកុមារចំនួន៦០នាក់ អំពីអក្សរខ្មែរព្យញ្ជនៈ ក ខ តែប៉ុណ្ណោះ។ រឿងដែល សួស សុខុន ចងចាំជាងគេកាលរស់នៅក្នុងព្រៃផ្អែកដឹកជញ្ជូន មិនមានបាយ ហូបលំបាកវេទនា ហូបមើលក្តួច មើមប្រង់ មើលដីស ត្រពាំងមិននឹកស្មានថាមានជីវិតរស់នៅដល់សព្វថ្ងៃទេ។

## អ៊ឹម វៀត

*ភេទប្រុស អាយុ៦៦ឆ្នាំ មានស្រុកកំណើតនៅស្រុកមេមត់ ខេត្តកំពង់ចាម។*



អឹម វៀត បាននិយាយថា «នៅឆ្នាំ១៩៧៥ ខ្មែរក្រហមចាត់តាំងខ្ញុំឱ្យបង្រៀនក្មេងៗនៅក្នុងភូមិជ្រៃនៅពេលព្រឹកហើយពេលរសៀលក្មេងៗទៅឃ្វាលគោ-ក្របី។ ខ្ញុំបង្រៀនក្មេងៗចាប់ពីម៉ោង៧ព្រឹកដល់ម៉ោង៩ព្រឹក ដោយបង្រៀនព្យញ្ជនៈអក្សរ ក ខ គ និងស្រះ។ ខ្ញុំបង្រៀនបានរយៈពេល២ឆ្នាំខ្មែរក្រហមឈប់ឱ្យខ្ញុំបង្រៀនហើយចាត់តាំងខ្ញុំឱ្យជីកដីធ្វើអាងទឹក ជីកព្រែក និង លើកប្រព័ន្ធភ្លឺស្រែជាមួយកងចល័តផ្សេងទៀត។

តាមការរៀបរាប់ខាងលើរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលធ្លាប់ធ្វើជាគ្រូបង្រៀននៅរបបខ្មែរក្រហម កុមារ មិនបានរៀនសូត្រពេញលេញទេហើយការសិក្សាដែលខ្មែរក្រហមទទួលស្គាល់គឺការអនុវត្តនៅតាមវាលស្រែ ចំណែកការអប់រំនៅក្រោយរបបខ្មែរក្រហមដួលរលំនិងទៅរស់នៅតស៊ូនៅអន្លង់វែង គោលដៅអប់រំត្រូវបានភ្ជាប់យ៉ាងខ្លាំងទៅនឹងការតស៊ូនយោបាយ និងយោធារបស់ខ្មែរក្រហម។ ក្រៅពីការអប់រំកុមារឱ្យមានជំនាញផ្នែកភាសានិងគណិតវិទ្យាជាមូលដ្ឋានការអប់រំក៏ផ្តោតជាចម្បងទៅលើការឃោសនានយោបាយ។ កម្មវិធីសិក្សានៅពេលនោះបណ្តុះគំនិតកុមារស្អប់ខ្ពើមខឹងសម្បារនិងចង់សងសឹកចំពោះអ្វីដែលខ្មែរក្រហមហៅថា«អាខ្មាំងយួនឈ្លានពាន» ។ នៅក្នុងអំឡុងពេលនោះ កុមារត្រូវបានបង្រៀនឱ្យមើលឃើញកុមារផ្សេងទៀតតាមនិន្នាការនយោបាយ កូនយួន (សំដៅកុមារដែលរស់នៅក្នុងតំបន់គ្រប់គ្រងដោយសាធារណរដ្ឋប្រជាមានិតកម្ពុជា) កូនរ៉ា (កុមារដែលរស់នៅក្រោមការគ្រប់គ្រងរបស់រណសិរ្សហ៊្វុនស៊ិនប៉ិច) និង កូនជាតិ (កុមារដែលនៅក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហម) ។



*សិស្សឡើងសរសេរអក្សរលើក្តារខៀននៅសាលារៀនមួយក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)។ (ហ្គុនណាបយស្រ្តម/មជ្ឈមណ្ឌលឯកសារកម្ពុជា)*

# ការពិភាក្សាពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ក្រៅសាលារៀន ជាវិធីសាស្ត្រសិក្សាបន្ថែមពីចំណេះដឹងដែលមានស្រាប់

ផេង ពង្សរ៉ាស៊ី


*សិស្សមកពីវិទ្យាល័យ ជា ស៊ីម គាកែវ មកសិក្សាឈ្វេងយល់ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និងទស្សនាខ្សែភាពយន្តឯកសាររឿង «កុំស្មានបងភ្លេច»។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

ការសិក្សា អាចសំដៅលើការសិក្សានៅក្នុងសាលារៀនពីកម្រិតបឋមសិក្សារហូតដល់សាកលវិទ្យាល័យ ទាំងការសិក្សាក្នុងវិស័យឯកជន និងរដ្ឋ។ ការសិក្សា គឺជាផ្នែកដ៏មានសារសំខាន់បំផុតសម្រាប់សិស្សានុសិស្សក្នុងការអភិវឌ្ឍន៍ចំណេះដឹងជំនាញ សីលធម៌ និងសុជីវធម៌នៅក្នុងសង្គម។ ប៉ុន្តែដើម្បីទទួលបានជោគជ័យក្នុងជីវិតបន្ទាប់ពីការសិក្សា មនុស្សម្នាក់ៗមិនអាចកំណត់ការសិក្សារបស់ខ្លួននៅត្រឹមតែការសិក្សានៅក្នុងសាលារៀនប៉ុណ្ណោះទេ។ អ្នកសិក្សាមានឱកាសច្រើនក្នុងការទទួលបានចំណេះដឹងជាច្រើនទៀត តាមរយៈការសិក្សានៅទីកន្លែងផ្សេងៗក្រៅពីសាលារៀន។ ការឆ្លៀតពេលវេលារបស់សិស្សដើម្បីទទួលបានការសិក្សាបន្ថែម គឺជាវិធីសាស្ត្រមួយមានប្រសិទ្ធភាពខ្ពស់ក្នុងការទទួលបានមកវិញនូវចំណេះដឹងបន្ថែមពីអ្វីដែលខ្លួនចង់ដឹង។ សារប្រយោជន៍ដែលទទួលបានពីការសិក្សាក្រៅសាលារៀន គឺមានច្រើនអនេក និងអាចធ្វើឱ្យអ្នកសិក្សាទទួលបានបទពិសោធន៍ពិតជាមួយនឹងមុខវិជ្ជាដែលអ្នកកំពុងសិក្សា ខណៈដែលសៀវភៅសិក្សា និងការបង្រៀនរបស់គ្រូនៅក្នុង

សាលារៀនគឺជាប្រភពនៃទ្រឹស្ដីដែលអ្នកសិក្សាអាចឈ្វេងយល់ពីទិដ្ឋភាពរួមនៃមេរៀន ប៉ុន្តែការសិក្សាបន្ថែមនៅក្រៅថ្នាក់រៀនគឺអាចអនុញ្ញាតឱ្យអ្នកសិក្សាមើលឃើញពីតថភាពជាក់ស្ដែង ដែលត្រូវបានបកស្រាយចេញពីទ្រឹស្ដីដែលអ្នកសិក្សាបានរៀននៅក្នុងសាលា។ ការសិក្សានៅក្រៅសាលារៀនគឺជាការតភ្ជាប់រវាងទ្រឹស្ដី និងភាពជាក់ស្ដែង។ លើសពីនេះទៀត ការសិក្សានៅក្រៅថ្នាក់រៀនអាចជួយអ្នកសិក្សាឱ្យអភិវឌ្ឍន៍ជំនាញមួយចំនួនដូចជាការដោះស្រាយបញ្ហា ការគិតគូរស៊ីជម្រៅ និងការប្រាស្រ័យទាក់ទងជាមួយអ្នកដែលនៅជុំវិញខ្លួន។ ជំនាញនេះ អាចនាំមកនូវភាពជោគជ័យដល់អ្នកសិក្សា ទាំងនៅក្នុងសាលារៀន កន្លែងធ្វើការ និងសហគមន៍។

ភ្ជាប់ជាមួយការសិក្សាក្រៅសាលារៀន នាព្រឹកថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០២៤ សិស្សានុសិស្សចំនួន១៥នាក់ (ស្រី១២នាក់) កំពុងសិក្សានៅថ្នាក់ទី១២នៃវិទ្យាល័យ ជា ស៊ីម តាកែវ មានទីតាំងស្ថិតនៅប្រមាណ២០០ម៉ែត្រពីការិយាល័យមជ្ឈមណ្ឌលឯកសារខេត្តតាកែវ បានឆ្លៀតពេលទំនេរពីការសិក្សារបស់ខ្លួន មកជួបជុំគ្នានៅការិយាល័យមជ្ឈមណ្ឌលឯកសារខេត្តតាកែវ ដើម្បីសិក្សាឈ្វេងយល់បន្ថែមពីប្រវត្តិសាស្ត្រខ្មែរក្រហម។ សិស្សានុសិស្សទាំងអស់ត្រូវបានទទួលស្វាគមន៍ដោយលោក ផេង ពង្សរ៉ាស៊ី នាយកសាខាមជ្ឈមណ្ឌលឯកសារខេត្តតាកែវ។ ពេលដែលសិស្សមកកាន់ការិយាល័យមជ្ឈមណ្ឌលឯកសារខេត្តតាកែវជាលើកដំបូង លោក ផេង ពង្សរ៉ាស៊ី បានណែនាំសិស្សានុសិស្សឱ្យ ទស្សនា និងឈ្វេងយល់ពីពិព័រណ៍រូបថតសម័យខ្មែរក្រហម សិស្សខ្លះបានឈរទស្សនាពិព័រណ៍រូបថតខ្មែរក្រហម និងអានចំណងជើងរូបថតនៅតាមផ្ទាំងពិព័រណ៍នីមួយៗ។ សិស្សខ្លះទៀតបានថតរូបអនុស្សាវរីយ៍ជាមួយនឹងផ្ទាំងពិព័រណ៍ ខណៈដែលអ្នកខ្លះទៀត កំពុងរង់ចាំគ្នីគ្នាដែលពុំទាន់មកដល់។ នៅពេលដែលសិស្សមកជួបជុំគ្នាហើយ លោក ផេង ពង្សរ៉ាស៊ី បានចាប់ផ្ដើមដោយឱ្យសិស្សអានសំណេរក្នុងផ្ទាំងពិព័រណ៍ ហើយលោករៀបរាប់ពីផ្ទាំងពិព័រណ៍នីមួយៗ ដែលដាក់តាំងបង្ហាញនៅខាងមុខការិយាល័យ ដើម្បីឱ្យសិស្សចេះត្រិះរិះពិចារណាអំពីផ្ទាំងពិព័រណ៍។ ចុងក្រោយ លោក ផេង ពង្សរ៉ាស៊ី ពន្យល់លម្អិតពីផ្ទាំងពិព័រណ៍នីមួយៗ និងពន្យល់ពាក្យខ្លះៗដែលប្រើប្រាស់នៅក្នុងរបបខ្មែរក្រហម ហើយបច្ចុប្បន្នពាក្យទាំងនោះមិនត្រូវបានប្រើប្រាស់ទៀតទេ ដូចជាពាក្យ «សមមិត្ត», «លេខាបក្ស», «ឈ្មោះបដិវត្តន៍», និង «កម្មាភិបាល»។ ពេលសិស្សចូលក្នុងការិយាល័យលោក ផេង ពង្សរ៉ាស៊ី បានបង្ហាញដល់សិស្សនូវរូបថតអ្នកទោសគុកទួលស្លែងមួយចំនួន ព្រមទាំងពន្យល់ពីរឿងរ៉ាវនៃការចាប់ខ្លួនអ្នកទាំងនោះ ក៏ដូចជាបង្ហាញព័ត៌មានខ្លះៗអំពីការបង្កើតមន្ទីរសន្តិសុខខ្មែរក្រហម។ ជាមួយគ្នានេះដែរ លោក ផេង ពង្សរ៉ាស៊ី ក៏បានបង្ហាញរូបថតបីផ្ទាំងទៀត ដែលជាអតីតកម្មាភិបាលខ្មែរក្រហមធ្វើការនៅក្នុងមន្ទីរ ស-២១ និងអ្នករស់រានមានជីវិតពីមន្ទីរ ស-២១ អមជាមួយនឹងការពន្យល់ពីជីវិតរបស់អ្នកទាំងនោះនាពេលបច្ចុប្បន្ន។ សិស្សានុសិស្សបាន



សិស្សមកពីវិទ្យាល័យ ជា ស៊ីម តាកែវ ទស្សនាខ្សែភាពយន្តឯកសាររឿង «ពុកខ្ញុំនៅឋានសួគ៌»។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



សិស្សមកពីវិទ្យាល័យ ជា ស៊ីម តាកែវ មកសិក្សាឈ្វេងយល់ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និងទស្សនាខ្សែភាពយន្តឯកសាររឿង «ពុកខ្ញុំនៅឋានសួគ៌»។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

កត់ត្រា និងសួរសំណួរទាក់ទងនឹងចម្ងល់អំពីរូបភាព។

តមកទៀត សិស្សានុសិស្ស ឈ្វេងយល់ពីឯកសារខ្មែរក្រហមដែលបានតម្កល់នៅក្នុងការិយាល័យ និងត្រូវបានលើកទឹកចិត្តឱ្យធ្វើការសិក្សាស្រាវជ្រាវបន្ថែមពីអ្វីដែលខ្លួនចង់ដឹងពីរបបខ្មែរក្រហម តាមរយៈការអានឯកសារទាំងនេះ។ លោក ដេង ពង្សរ៉ាស៊ី ក៏បានណែនាំសិស្សឱ្យអានសៀវភៅជាសង្ខេបដែលដាក់តម្កល់នៅលើតុ ដែលភាគច្រើនជាស្នាដៃបោះពុម្ពដោយមជ្ឈមណ្ឌលឯកសារកម្ពុជា និងជាសៀវភៅ រៀបរាប់ពីរឿងរ៉ាវដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហម។ សិស្សានុសិស្សភាគច្រើន បានចំណាយពេលវេលាខ្លះៗដើម្បីអានសៀវភៅ ទាំងនោះ ហើយអ្នកខ្លះបានថតចំណងជើងសៀវភៅ និងពិភាក្សាគ្នាពីសៀវភៅទៀតផង។ លោក ដេង ពង្សរ៉ាស៊ី រៀបរាប់ប្រាប់សិស្សថា «សៀវភៅ ទាំងនេះគឺទុកសម្រាប់អាន ហើយសិស្សអាចចូលមកអានសៀវភៅ ទាំងនេះបានគ្រប់ពេលវេលាពីថ្ងៃចន្ទដល់សុក្រ ព្រោះថាកន្លែងនេះគឺជាបន្ទប់អានសៀវភៅ និងជាកន្លែងស្រាវជ្រាវឯកសារប្រវត្តិសាស្ត្រខ្មែរក្រហម។ ប្អូនៗអាចមកកាន់ទីនេះ ដើម្បីអាន សិក្សា និងធ្វើកិច្ចការសាលាបានគ្រប់ពេល។ ប្អូនៗក៏អាចស្នើសុំការទស្សនាខ្សែភាពយន្តឯកសារនានាដែលផលិតដោយមជ្ឈមណ្ឌលឯកសារកម្ពុជា។



ដើម្បីផ្តល់ចំណេះដឹងកាន់តែស៊ីជម្រៅ លោក ដេង ពង្សរ៉ាស៊ី ចាប់ផ្តើមពីការវាស់ស្ទង់



ចំណេះដឹងរបស់សិស្ស អំពីប្រវត្តិសាស្ត្រ មុនធ្វើបទបង្ហាញពីប្រវត្តិសាស្ត្រខ្មែរក្រហមដោយសង្ខេបទៅកាន់សិស្សក្នុងគោលបំណងបន្តការពិភាក្សាពីប្រវត្តិសាស្ត្រខ្មែរក្រហមជាមួយសិស្ស។ ការវាស់ស្ទង់ចំណេះដឹងអាចឱ្យគ្រូដឹងពីចំណុចខ្វះខាតរបស់សិស្ស និងអាចផ្តល់ដល់គ្រូនូវគោលដៅក្នុងពន្យល់ច្រើនពីអ្វីដែលសិស្សពុំទាន់បានដឹង។ ចុងក្រោយនៃការពិភាក្សាគឺសិស្សានុសិស្សបានទស្សនាខ្សែភាពយន្តឯកសារ ដែលផលិតដោយមជ្ឈមណ្ឌលឯកសារកម្ពុជាក្នុងឆ្នាំ២០១៨ មានចំណងជើងថា «ពុកខ្ញុំនៅឯណាទៅ» ដែលមានរយៈពេល៣២នាទី។ នេះគឺជាខ្សែភាពយន្តបង្ហាញពីការជម្លៀសដោយបង្ខំរបស់ខ្មែរក្រហម ដែលឈានទៅការបាត់បង់ឪពុកជាទីស្រឡាញ់របស់អ្នកគ្រូ រស់ ចាន់ថន បង្រៀនមុខវិជ្ជាប្រវត្តិវិទ្យា និងបច្ចុប្បន្នជានាយិការងវិទ្យាល័យ ជា ស៊ីម តាកែវ។ ការចាក់បញ្ចាំងខ្សែវីដេអូនេះ គឺដើម្បីប្រាប់ដល់សិស្សថា គ្រូបង្រៀនមួយចំនួន គឺជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលមានប្រវត្តិបាត់បង់ឪពុកជាទីស្រឡាញ់ក្នុងរបបខ្មែរក្រហម ហើយវាគឺជារឿងដែលមិនអាចបំភ្លេចបាន។ មូលហេតុចម្បងមួយទៀតនៃការចាក់បញ្ចាំងខ្សែវីដេអូនេះ គឺដើម្បីផ្តល់នូវការសន្ទនាអន្តរជំនាន់រវាងគ្រូ និងសិស្សរបស់ខ្លួននៅគ្រប់ពេលវេលា បន្ទាប់ពីការជួបជុំនេះ។

**ខាងក្រោម គឺជាការចំណាប់អារម្មណ៍របស់សិស្សចំនួន៨នាក់ ដែលបានសិក្សាពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)៖**

### ទូច ស្រីនាង

*ភេទស្រី អាយុ១៦ឆ្នាំ គឺជាសិស្សរៀនថ្នាក់ទី១២*



បន្ទាប់ពីបានចូលរួមក្នុងកិច្ចពិភាក្សាពីប្រវត្តិសាស្ត្រខ្មែរក្រហមរយៈពេលមួយព្រឹករួចមក ធ្វើឱ្យខ្ញុំបានយល់ដឹងអំពីរឿងរ៉ាវក្នុងរបបខ្មែរក្រហមច្រើនជាងមុន ដូចជាទុក្ខលំបាករបស់ប្រជាជនដែលត្រូវខ្មែរក្រហមធ្វើបាប បង្អត់អាហារ ហើយបង្ខំឱ្យធ្វើការងារហួសកម្លាំង។ ខ្ញុំស្រមៃឃើញថាប្រសិនជាខ្ញុំកើតទាន់របបខ្មែរក្រហម ខ្ញុំពិតជាមិនបានចូលរៀន ព្រមទាំងត្រូវទៅធ្វើការតាមវាលស្រែរបស់ខ្មែរក្រហម។ ខ្ញុំធ្លាប់ស្តាប់យាយរបស់ខ្ញុំនិយាយពីការធ្វើការគ្មានពេលឈប់សម្រាក និងការងារកាប់ថ្មដែលត្រូវប្រើកម្លាំងខ្លាំង។ យាយរបស់ខ្ញុំបានបន្ថែមទៀតថា គាត់ពិតជាមានសំណាងខ្លាំងណាស់ ដែលបានរួចផុតពីរបបខ្មៅងងឹតនេះ ហើយអាចរស់រានមានជីវិតមកដល់ពេលបច្ចុប្បន្ន។ ការពិភាក្សានៅព្រឹកនេះ ពិតជាបានផ្តល់នូវសារសំខាន់យ៉ាងខ្លាំង

ចំពោះខ្ញុំ អាចឱ្យខ្ញុំយល់ដឹងពីរបបខ្មែរក្រហមថា បានសម្លាប់មនុស្ស ហើយគ្រូពេទ្យខ្មែរក្រហមខ្វះវិជ្ជាជីវៈក្នុងការព្យាបាលប្រជាជនបណ្តាលឱ្យមានមនុស្សស្លាប់ ដូចក្នុងខ្សែភាពយន្តឯកសារ «ពុកខ្ញុំនៅឯណាហានសួរ» ។ របបខ្មែរក្រហមបានកាប់សម្លាប់គ្មានលើកលែង សូម្បីតែក្មេងៗ និងបានសម្លាប់ប្រជាជនខ្លួនឯងៗ ចុងក្រោយ ខ្ញុំសូមសំណូមពរឱ្យមានសកម្មភាពពិភាក្សាពីរបបខ្មែរក្រហមជាបន្តបន្ទាប់ទៀត ព្រោះអាចឱ្យខ្ញុំយល់ដឹងទាក់ទងនឹងរបបខ្មែរក្រហមកាន់តែច្បាស់ជាងមុនៗ

## ផាត ស្រីលាប

ភេទស្រី អាយុ១៧ឆ្នាំ គឺជាសិស្សរៀនថ្នាក់ទី១២ មកពីវិទ្យាល័យ ជា ស៊ីម តាកែវ។



ក្រោយពេលខ្ញុំបានចូលរួមសិក្សាឈ្វេងយល់ពីរបបខ្មែរក្រហមនៅមជ្ឈមណ្ឌលឯកសារខេត្តតាកែវ ធ្វើឱ្យខ្ញុំយល់ដឹងកាន់តែច្បាស់ពីប្រវត្តិសាស្ត្រ។ ពេលឈានចូលដល់ការិយាល័យមជ្ឈមណ្ឌលឯកសារខេត្តតាកែវដំបូង គឺខ្ញុំបានដឹងពីប្រវត្តិរបស់ តាម៉ុក និងការផ្សាររបស់គាត់កាលពីសម័យខ្មែរក្រហម។ ខ្ញុំយល់ថា មេដឹកនាំក្នុងរបបខ្មែរក្រហមពិតជាកាចសាហាវឃោរឃៅ ធ្វើបាប គាបសង្កត់ និងបំបិទសិទ្ធិសេរីភាពរបស់ប្រជាជនៗ បន្ទាប់មក ខ្ញុំបានទស្សនាវីដេអូខ្សែភាពយន្តរបស់អ្នកគ្រូ រស់ ចាន់ថន ដែលផលិតដោយមជ្ឈមណ្ឌលឯកសារកម្ពុជា។ ខ្ញុំអាណិតអ្នកគ្រូ ដែលត្រូវបាត់បង់ឪពុក និងប្អូនទាំងវ័យក្មេងៗ

## ពេជ្រ ពិសិដ្ឋ

ភេទប្រុស អាយុ១៦ឆ្នាំ គឺជាសិស្សរៀនថ្នាក់ទី១២ មកពីវិទ្យាល័យ ជា ស៊ីម តាកែវ។



ក្រោយពីបានចូលរួមសិក្សាបន្ថែមពីរបបខ្មែរក្រហមនៅមជ្ឈមណ្ឌលឯកសារខេត្តតាកែវ ធ្វើឱ្យខ្ញុំបានយល់ដឹងកាន់តែច្រើនអំពីរបបខ្មែរក្រហមដែលធ្វើបាបប្រជាជន ជម្លៀសប្រជាជនដោយបង្ខំឱ្យទៅរស់នៅតាមទីជនបទ លុបបំបាត់ទីផ្សារ លុបបំបាត់រូបិយវត្ថុ និង លុបបំបាត់ស្រទាប់វណ្ណៈសង្គម។ មិនតែប៉ុណ្ណោះ ខ្មែរក្រហមបានលុបបំបាត់សាសនា ទំនៀមទម្លាប់ប្រពៃណី និងបំផ្លាញបោលវត្តអារាមៗ ខ្ញុំគិតថា បើខ្ញុំកើតទាន់របបខ្មែរក្រហមខ្ញុំមិនអាចរៀនសូត្របានទេ ហើយក៏មិនមានសិទ្ធិសេរីភាពដូចសព្វថ្ងៃនេះដែរ ព្រោះខ្មែរក្រហមបានបំបិទសិទ្ធិសេរីភាពគ្រប់បែបយ៉ាងទាំងអស់។ ខ្ញុំធ្លាប់បានឮតាមរយៈយាយរបស់ខ្ញុំដែលរស់រានមានជីវិតពីរបបខ្មែរក្រហមរៀបរាប់ថា ការរស់នៅរបស់គាត់ពិបាកខ្លាំងណាស់ ហើយគាត់ធ្វើការផ្សារមិនមានពេលឈប់សម្រាកឡើយ។ កិច្ចពិភាក្សាដែលរៀបចំឡើងក្នុងថ្ងៃនេះ បានផ្តល់នូវសារសំខាន់ដល់ខ្ញុំ និងមិត្តភក្តិឯទៀត ឱ្យបានយល់ដឹងកាន់តែច្បាស់អំពីប្រវត្តិសាស្ត្រ និងការរស់នៅរបស់ប្រជាជនក្នុងរបបខ្មែរក្រហម ។

## ព្រឹម មន្នីសុជាតា

*ភេទស្រី អាយុ១៦ឆ្នាំ គឺជាសិស្សរៀនថ្នាក់ទី១២ មកពីវិទ្យាល័យ ជា ស៊ីម តាកែវ។*



បន្ទាប់ពីខ្ញុំបានចូលរួមកិច្ចពិភាក្សាពីប្រវត្តិសាស្ត្ររបបខ្មែរក្រហមរួច ធ្វើឱ្យខ្ញុំយល់ដឹងកាន់តែច្រើនដោយលោកគ្រូបានបញ្ជាក់យ៉ាងច្បាស់អំពីចំនួនអ្នកស្លាប់ក្នុងរបបខ្មែរក្រហម។ មួយវិញទៀត ចំណុចដែលខ្ញុំចង់ចាំជាងគេ គឺបានទស្សនាខ្សែភាពយន្តដែលបង្ហាញពីជីវិតអ្នកគ្រូ រស់ ចាន់ថន និងគ្រួសារឆ្លងកាត់របបខ្មែរក្រហម។ ខ្ញុំពិតជាមានសំណាងដែលមិនបានកើតទាន់ក្នុងរបបខ្មែរក្រហម។ ខ្ញុំគិតថាបើខ្ញុំកើតទាន់ក្នុងរបបខ្មែរក្រហម ខ្ញុំមិនអាចសិក្សារៀនសូត្រទេ ព្រោះខ្មែរក្រហមបានបិទសាលារៀន និងវត្តអារាមហើយបើប្រៀបធៀបកាលពីរបបខ្មែរក្រហម និងពេលបច្ចុប្បន្នគឺមានភាពខុសប្លែកគ្នាឆ្ងាយណាស់។ សព្វថ្ងៃ យើងហូបចុកគ្រប់គ្រាន់ បើក្នុងរបបខ្មែរក្រហមប្រជាជនត្រូវរង់ចាំបើករបបអាហារ និងត្រូវហូបរួមគ្នា។ ប្រជាជនហូបចុកមិនបានឆ្អែតទេ គឺមិនស្មើនឹងកម្លាំងដែលធ្វើការងារឱ្យខ្មែរក្រហមឡើយ។ ខ្ញុំអាណិតអាសូរចំពោះអ្នកដែលបានកើតក្នុងរបបខ្មែរក្រហម ។ ខ្ញុំនឹងខិតខំរៀនសូត្រ និងឈ្វេងយល់ឱ្យកាន់តែច្បាស់អំពីប្រវត្តិសាស្ត្រខ្មែរក្រហម ហើយមិនឱ្យប្រវត្តិសាស្ត្រនេះកើតឡើងម្តងទៀតឡើយ។ ខ្ញុំនៅតែចង់ឱ្យមានសកម្មភាពបែបនេះម្តងទៀត ព្រោះជាជំនួយក្នុងប្រឡងបាក់ឌុបរបស់ខ្ញុំនាពេលឆ្នាំក្រោយ ។



*សិស្សមកពីវិទ្យាល័យ ជា ស៊ីម តាកែវ មកសិក្សាឈ្វេងយល់ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និងទស្សនាខ្សែភាពយន្តឯកសាររឿង «ពុកខ្ញុំនៅឋានសួគ៌»។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

# ហ៊ីប សារីម ៖ ប្ដីខ្ញុំត្រូវអង្គការចោទថាក្បត់ និងយកទៅសម្លាប់

សោម ប៊ុនថន



ហ៊ីប សារីម រស់នៅភូមិត្បែង ឃុំគគីសោម ស្រុកស្វាយទាប ខេត្តស្វាយរៀង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

បន្ទាប់ពីអង្គការចាប់ប្ដីខ្ញុំបានរយៈពេលមួយខែ កម្មាភិបាលនៅមន្ទីរមកប្រាប់ខ្ញុំថា «ប្ដីរបស់បងក្បត់ហើយ ដូច្នេះស្នើបងសម្រេចចិត្តថា ទៅតាមប្ដី ឬនៅជាមួយអង្គការ បើចង់ទៅតាមប្ដី អង្គការនឹងជូនទៅជួបប្ដី ហើយបើនៅជាមួយអង្គការ អង្គការចិញ្ចឹម»។ ខ្ញុំរន្ធត់ចិត្តខ្លាំងណាស់ និងគិតតែពីយំពេលឮពាក្យនេះ។ ខ្ញុំបានទប់ស្មារតី និងសម្រេចចិត្តឆ្លើយថា «មិនទៅតាមប្ដីដែលក្បត់ឡើយ គឺខ្ញុំនៅស្លាប់រស់ជាមួយអង្គការ»។ ប្ដីខ្ញុំស្លូតណាស់ ហើយខ្ញុំឆ្លើយដូច្នេះដើម្បីរស់ ព្រោះខ្ញុំត្រូវចិញ្ចឹមកូនតូចដែលនៅជៅនៅឡើយ។ ប្រសិនបើបងប្អូនខាងប្ដីរបស់ខ្ញុំដឹងថាខ្ញុំឆ្លើយដូច្នេះ នឹងខឹងខ្ញុំមិនខាន ហើយខ្ញុំក៏សូមខមាទោសចំពោះប្ដីដែរ។

ខ្ញុំឈ្មោះ ហ៊ីប សារីម កើតនៅឆ្នាំ១៩៤២។ ខ្ញុំមានប្ដីឈ្មោះ សេក យ៉ូវ។ ប្ដីរបស់ខ្ញុំមានអាយុលើសខ្ញុំ៤ឆ្នាំ។ ខ្ញុំនិងប្ដីកើតនិងរស់នៅក្នុងភូមិត្បែង ឃុំគគី

សោម ស្រុកស្វាយទាប ខេត្តស្វាយរៀង ជាមួយគ្នា។ យើងបានស្គាល់គ្នា និងរៀនជាមួយគ្នាតាំងពីក្មេងៗ។ យើងរៀននៅសាលាបឋមសិក្សាក្នុងភូមិត្បែង និងទៅរៀនបន្តនៅសាលាអនុវិទ្យាល័យ ស្ថិតនៅក្នុងឃុំស្វាយរំពារ ស្ថិតនៅឆ្ងាយពីផ្ទះ។ ខ្ញុំនិងប្ដីបានដើរទៅរៀនរាល់ថ្ងៃព្រោះគ្រួសារយើងក្រីក្រណាស់។ ប្ដីរបស់ខ្ញុំរៀនដល់ថ្នាក់ទី៧ (ឬថ្នាក់ស៊ុបប៉េរីយើពីសង្គមចាស់) ក៏ឈប់រៀន។ បន្ទាប់មកគាត់ទៅធ្វើការនៅរោងចក្រនៅស្ទឹងប្រាល ក្នុងខេត្តកំពត (បច្ចុប្បន្នភូមិស្ទឹងប្រាល ឃុំអូរបាក់រទេះ ស្រុកកំពង់សីលា ខេត្តព្រះសីហនុ) ចំណែកខ្ញុំរៀននៅស្រុកកំណើតដដែល។ ពីមួយថ្ងៃទៅមួយថ្ងៃ ម្ដាយខ្ញុំដែលជាស្ត្រីមេម៉ាយមានជីវភាពកាន់តែទទាល់ក្រលំបាក ទើបខ្ញុំឈប់រៀនមកជួយរកស៊ី និងធ្វើការងារចិញ្ចឹមម្ដាយវិញ។

នៅពាក់កណ្ដាលឆ្នាំ១៩៦០ ប្ដីខ្ញុំបានវិលត្រឡប់មកស្រុកកំណើតវិញ ហើយឱ្យឪពុកម្ដាយរបស់គាត់ចូលស្ដីដណ្ដឹងខ្ញុំរៀបការ។ ប្ដីខ្ញុំបានបោះបង់គំនិតដែលធ្លាប់ដើរលេងកាលពីក្មេងចោល ព្រោះយើងត្រូវកសាងគ្រួសារថ្មី។ ខ្ញុំមិនដែលក្រើនរំឭកដាស់តឿនប្ដីខ្ញុំទេ គឺគាត់បានដឹងថាត្រូវធ្វើអ្វីដោយខ្លួនឯងព្រោះគាត់គឺជាមេគ្រួសារ។ ប្ដីខ្ញុំមិនចេះជក់ថ្នាំ មិនចេះផឹកស្រា និងមិនហូបសាច់ឆ្កែឡើយ ទោះបីសាច់ញាតិក្នុងភូមិឱ្យគាត់ក៏ដោយ។ ខ្ញុំនិងប្ដីបានធ្វើស្រែនៅក្នុងភូមិត្បែងដើម្បីចិញ្ចឹមជីវិត។ នៅឆ្នាំ១៩៦៨ ប្ដីរបស់ខ្ញុំបានចូលធ្វើការនៅផ្នែកហិរញ្ញិក នៅក្នុងកម្មវិធីទិញស្រូវអង្ករពីប្រជាជនដែលរដ្ឋាភិបាលសម័យសង្គមរាស្ត្រនិយមបានបង្កើតឡើង ហើយរដ្ឋាភិបាលបានបង្កើត «សហករណ៍» ដើម្បីដាក់តាំងលក់ផលិតផលនៅក្នុងសហគមន៍ មានដូចជា ស៊ីម៉ង់ត៍, ខស, សម្បកបាវ, ប្រេង, ក្រណាត់ ឱ្យប្រជាជនក្នុងតម្លៃថោកវិញ។ ប្រធានសហករណ៍មានឈ្មោះ ម៉ាញ, អនុប្រធានសហករណ៍ឈ្មោះ ដៃ បន្ទាប់មកប្ដីខ្ញុំគ្រប់គ្រងខាងលុយកាក់។ ពេលនោះ មានប្រជាជនជាច្រើនបានមកយកសម្បកបាវពីសហករណ៍យកទៅប្រកស្រូវមកលក់ឱ្យសហករណ៍វិញ។ ប៉ុន្តែមុននឹងយកសម្បកបាវទៅ ប្រជាជនត្រូវកត់ឈ្មោះជាមុនសិន។ មានប្រជាជនខ្លះមិនទាន់មកយកសម្បកបាវ ខ្លះទៀតយកសម្បកបាវទៅហើយ ប៉ុន្តែមិនទាន់ដឹកស្រូវមកឱ្យសហករណ៍ឡើយ ក៏ស្រាប់តែមានរដ្ឋប្រហារទម្លាក់សម្ដេចព្រះ នរោត្តម សីហនុ នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០។ ពេលនោះកងកម្លាំងរំដោះខ្មែរក្រហមបានឡើងមកសំឡុតប្ដីរបស់ខ្ញុំនៅលើផ្ទះ ធ្វើឱ្យប្ដីខ្ញុំភិតភ័យយ៉ាងខ្លាំង ហើយគាត់ក៏ប្រគល់បញ្ជីឈ្មោះអ្នកដែលនៅជំពាក់ប្រាក់ និងស្រូវរដ្ឋទៅឱ្យខ្មែរក្រហមទាំងអស់។ ចាប់តាំងពីពេលនោះ សភាពការណ៍នៅក្នុងភូមិកាន់តែតឹងតែងខ្លាំង ហើយការធ្វើដំណើរទៅមកក៏មានការត្រួតពិនិត្យដែរ។

ប្ដីខ្ញុំបានឈប់ពីការងារ ហើយមកនៅផ្ទះ។ ពេលយប់ប្ដីខ្ញុំចេញទៅរកត្រីនៅវាលឈើទាល ក៏បានជួបខ្មែរក្រហម។ ខ្មែរក្រហមបានបញ្ចុះបញ្ចូលប្ដីខ្ញុំឱ្យចូលធ្វើកងទ័ពខ្មែរក្រហម ប៉ុន្តែប្ដីខ្ញុំមិនបានប្រាប់ខ្ញុំឡើយ។ ខ្ញុំបានសួរប្ដីខ្ញុំថា តើរកបានត្រីទេ? ពេលគាត់ត្រឡប់មកផ្ទះវិញម្ដងៗ ហើយគាត់តែងឆ្លើយថារកមិនបានទេ។ គាត់ចេះតែបង្ហាញអាកប្បកិរិយាប្លែកៗ ដូចជា អង្គុយសញ្ជប់សញ្ជឹងតែម្នាក់ឯង និងដេកយកដៃគងថ្ងាស់។ តាមពិតប្ដីរបស់ខ្ញុំបានសម្រេចចិត្តចូលរួមជាមួយបដិវត្តន៍ខ្មែរក្រហម ហើយព្រួយចិត្តមិនចង់បែកឆ្ងាយពីប្រពន្ធកូន ព្រោះខ្មែរក្រហមមកហៅគាត់ឱ្យទៅធ្វើការនៅចន្ទ្រី ក្នុងស្រុកសំរោង (បច្ចុប្បន្នស្រុករមាសហែក)។ អំឡុងពេលនោះ កងទ័ពធីវគី (កងទ័ពសាធារណរដ្ឋវៀតណាមខាងត្បូងដែលសហការជាមួយកងទ័ព លន់ នល់ តាមកម្ចាត់វៀតណាមខាងជើង និងបដិវត្តន៍ខ្មែរក្រហម) ក៏បានចូលមកភូមិឃុំរបស់ខ្ញុំដែរ ដូច្នេះប្ដីខ្ញុំក៏បានគេចខ្លួនទៅរស់នៅឆ្ងាយៗពីផ្ទះ។ ប្ដីរបស់ខ្ញុំបានចាកចេញពីផ្ទះដោយមិនបានប្រាប់ខ្ញុំឡើយ។ ខ្ញុំជួបការលំបាកយ៉ាងខ្លាំងពេលមានគ្រាប់ផ្លោងធ្លាក់មកម្ដងៗ ព្រោះមិនមានអ្នកដឹកដៃកូនតូចពីរនាក់រត់រកកន្លែងលាក់ខ្លួន និងទុកដាក់ទ្រព្យរបស់។ នៅពេលសភាពការណ៍ស្ងប់ស្ងាត់ ទើបប្ដីខ្ញុំលួចមកជួបខ្ញុំនិងកូន និងដេកនៅផ្ទះរយៈពេលមួយបុពីរយប់ក៏ត្រឡប់ទៅធ្វើការវិញ។ ប្ដីខ្ញុំធ្វើការនៅអង្គភាពពាណិជ្ជកម្មស្រុកសំរោង។

នៅឆ្នាំ១៩៧៥ ខ្ញុំនិងកូនមករស់នៅវត្តលោកយួន (កាលពីជំនាន់មុនមានសង្ឃយួនរស់នៅ

ក្រោយមកប្ដូរឈ្មោះមកវត្តពោធិ៍តាហោ) ជាមួយប្ដីរបស់ខ្ញុំដែលឡើងមកធ្វើការនៅមន្ទីរពាណិជ្ជកម្មតំបន់២៣ ដោះទីតាំងនៅត្រើយតាហោ ខាងកើតក្រុងស្វាយរៀង សព្វថ្ងៃស្ថិតនៅក្នុងភូមិពោធិ៍តាហោ សង្កាត់ពោធិ៍តាហោ ក្រុងស្វាយរៀង ខេត្តស្វាយរៀង។ ប្រធានមន្ទីរពាណិជ្ជកម្មឈ្មោះ គួន មានស្រុកកំណើតនៅភូមិសង្គម (សម័យមុនភូមិគោករនោង) ឃុំគគីសោម ស្រុកស្វាយទាប ខេត្តស្វាយរៀង។ ខ្ញុំធ្វើស្រែ ចិញ្ចឹមគោក្របី ជ្រូក ដាំដំណាំដើម្បីយកទៅផ្គត់ផ្គង់អង្គភាពពាណិជ្ជកម្ម។ ចំណែកប្ដីរបស់ខ្ញុំបានទៅទាក់ទងជាមួយវៀតណាមទិញក្រណាត់ខ្មៅ និងអង្រឹង និងលក់ស្រូវ និងជ្រូកទៅឱ្យវៀតណាមវិញ។ ប្ដីខ្ញុំបានដឹកជញ្ជូនសម្ភារពីស្រុកក្រសាំង (ស្រុករមាសហែក) ទៅមន្ទីរភូមិភាគនៅអរិយក្សត្រ ហើយដឹកថ្នាំពេទ្យត្រឡប់មកមន្ទីរពាណិជ្ជកម្មតំបន់២៣វិញ។ ក្រៅពីនោះប្ដីរបស់ខ្ញុំបានយករថយន្តចំនួន៥គ្រឿងទៅដឹកក្រណាត់ និងថ្នាំពេទ្យពីស្រុកអូររាំងឪដែរ។ ប្ដីរបស់ខ្ញុំក៏ខសង្រាហ៍ធ្វើការជាមួយគណៈតំបន់ឈ្មោះ តាតូ ដែរ។ អ្នកធ្វើការនៅមន្ទីរពាណិជ្ជកម្មជាមួយខ្ញុំពេលនោះភាគច្រើននៅលីវ ចំណែកអ្នករៀបការហើយ ស្នាក់នៅមន្ទីរពាណិជ្ជកម្មតំបន់មានតែពីរគ្រួសារ រួមទាំងខ្ញុំ។

នៅចុងឆ្នាំ១៩៧៧ មានការចាប់ខ្លួនកម្មាភិបាលខ្មែរក្រហមជាបន្តបន្ទាប់ រួមទាំងប្រធានមន្ទីរពាណិជ្ជកម្មតំបន់២៣ ធ្វើឱ្យកម្មាភិបាលនៅមន្ទីរពាណិជ្ជកម្មតំបន់បារម្ភគ្រប់ៗគ្នា ហើយប្ដីខ្ញុំក៏ភ័យព្រួយដែរ ប៉ុន្តែនៅពេលខ្ញុំនិយាយទាក់ទងនឹងហេតុការណ៍ចាប់ខ្លួនជាមួយគាត់ដើម្បីរកផ្លូវរត់គេចខ្លួន គាត់តែងតែយកដៃរបស់គាត់ខ្ទប់មាត់ខ្ញុំមិនឱ្យនិយាយ។ ក្រោយមកប្រធានមន្ទីរពាណិជ្ជកម្មតំបន់២៣មកពីភូមិភាគនិរតី ដែលទើបឡើងថ្មីបានសរសេរសំបុត្រឱ្យនីរសារមកហៅប្ដីរបស់ខ្ញុំដែលកំពុងរៀបចំឃ្លាំងដាក់ស្រូវ និងសម្ភារនៅវត្តក្ដីស្លា បច្ចុប្បន្នស្ថិតនៅក្នុងភូមិក្ដីស្លា ឃុំស្វាយយា ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង ឱ្យឡើងមកប្រជុំនៅមន្ទីរសេដ្ឋកិច្ចតំបន់២៣ នៅពោធិតាហោ ព្រោះពេលនោះកងទ័ពខ្មែរក្រហមកំពុងវាយប្រយុទ្ធជាមួយកងទ័ពវៀតណាម ហើយភ័យខ្លាចកងទ័ពវៀតណាមចូលមកដុតបំផ្លាញស្រូវ និងសម្ភារ ដូច្នេះក៏សម្រេចផ្ទេរឃ្លាំងស្រូវ និងឃ្លាំងសម្ភារពីមន្ទីរពាណិជ្ជកម្មតំបន់២៣ នៅពោធិតាហោមកដាក់នៅវត្តក្ដីស្លាដែលប្ដីរបស់ខ្ញុំកំពុងរៀបចំវិញ។ ចាប់តាំងពីប្ដីខ្ញុំចេញទៅប្រជុំ គឺមិនឃើញត្រឡប់មកវិញទេ។ ក្រោយមក ទើបខ្ញុំទទួលដំណឹងពីអ្នករស់នៅក្នុងមន្ទីរជាមួយគ្នាថា ខ្មែរក្រហមចាប់ខ្លួនប្ដីខ្ញុំហើយ ហើយពីមួយថ្ងៃទៅមួយថ្ងៃខ្ញុំឮតែខ្មែរក្រហមដើរចាប់កម្មាភិបាលនេះ ឬកម្មាភិបាលនោះកាន់តែច្រើនឡើងធ្វើឱ្យខ្ញុំសោកសង្រេងយ៉ាងខ្លាំង ហើយខ្ញុំក៏មិនហ៊ានដើរស៊ើបសួរដំណឹងប្ដីខ្ញុំដែរ។

កន្លងមកបានមួយរយៈ នីរសារខ្មែរក្រហមមកប្រាប់ខ្ញុំថា «គ្រួសារបងឯងក្បត់ហើយ! ឥឡូវបងឯងសម្រេចចិត្តរស់នៅក្នុងសហករណ៍ ឬនៅជាមួយអង្គការ។ ឥឡូវខ្ញុំឱ្យជ្រើសរើសផ្លូវពីរ ព្រោះអង្គការថ្នាក់លើឱ្យខ្ញុំពាំនាំពាក្យមកប្រាប់បងឯងឱ្យបងគិតពិចារណាថា បើបងឯងរស់នៅជាមួយអង្គការ អង្គការចិញ្ចឹមរហូត បើបងរស់នៅសហករណ៍ជាមួយគ្រួសារបងឯងក៏អង្គការមិនថាអីដែរ។ ពេលខ្ញុំឮថាប្ដីខ្ញុំក្បត់ ខ្ញុំភិតភ័យខ្លាំងណាស់ ម្យ៉ាងបងប្អូនខ្ញុំក៏ត្រូវខ្មែរក្រហមបញ្ជូនចេញពីសហរណ៍ដែលខ្ញុំរស់នៅទៅមុនអស់ដែរ។ ខ្ញុំអង្គុយបំបៅដោះកូន និងស្រក់ទឹកភ្នែកព្រោះមិនដឹងឆ្លើយយ៉ាងណា។ មួយសន្ទុះក្រោយមក ខ្ញុំក៏ឆ្លើយប្រាប់នីរសារនោះថា «ឥឡូវប្ដីរបស់ខ្ញុំក្បត់ហើយ ខ្ញុំនិងកូនសុខចិត្តរួមរស់ជាមួយអង្គការជារៀងរហូត ក្នុងមួយជីវិតរបស់ខ្ញុំ»។ នៅពេលស្ដាប់ឮខ្ញុំឆ្លើយដូច្នេះ នីរសារបានប្រាប់ខ្ញុំថា «មិនអីទេ ចាំខ្ញុំពាំនាំសំដីរបស់បងឯងទៅប្រាប់ថ្នាក់លើ»។ បន្ទាប់មកអង្គការឱ្យខ្ញុំមករស់នៅមន្ទីររបស់ប្ដីខ្ញុំធ្លាប់ធ្វើការនៅពោធិតាហោវិញ។ អង្គការបានដាក់ការងារឱ្យខ្ញុំក្រងកន្ទេល ហើយភ្លាមៗនោះខ្ញុំក៏មិនប្រកែកដែរ ទោះបីខ្ញុំមិនចេះក្រងក៏ដោយព្រោះខ្លាចអង្គការយកទៅសម្លាប់ចោល។ ពេលទទួលការងារហើយ ខ្ញុំហួបបាយមិនបាន ហើយដេកក៏មិនលក់ដែរព្រោះខ្ញុំមិនដឹងពីវិធីក្រងកន្ទេល។ សំណាងល្អ មានយុវជនម្នាក់ស្រឡាញ់រាប់អានខ្ញុំដូចជាបងស្រី ហើយខ្ញុំក៏បានលួចខ្សឹបប្រាប់យុវជននោះថា «បងមិនចេះធ្វើកន្ទេលទេ ហើយបើអង្គការដាក់ទិសឱ្យបងធ្វើកន្ទេល



ហ៊ីប សារីម រស់នៅភូមិត្បែង ឃុំគគីសោម ស្រុកស្វាយទាប ខេត្តស្វាយរៀង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

តើបងត្រូវធ្វើរបៀបណា។ យុវជននោះប្រាប់មកខ្ញុំវិញថា «ប្រសិនបើអង្គការដឹងថាបងមិនចេះធ្វើកន្ទេល អង្គការនឹងយកបងទៅវាយចោលមិនខាន ដូច្នេះខ្ញុំទៅកាប់ស្លឹកត្នោត ហើយបងចាំឆូតស្លឹកត្នោតឱ្យខ្ញុំ ខ្ញុំនឹងបង្រៀនបងក្រងកន្ទេល ប៉ុន្តែសូមកុំឱ្យអ្នកជិតខាងឃើញខ្លាចរាយការណ៍ទៅអង្គការ»។ យុវជននោះបានបង្រៀនខ្ញុំក្រងកន្ទេលរហូតចេះ ចំណែកកូនច្បងរបស់ខ្ញុំត្រូវអង្គការចាត់តាំងឱ្យឃ្វាលក្របី។

នៅថ្ងៃមួយ វេលាម៉ោង៨យប់ ក្នុងឆ្នាំ១៩៧៨ ប្រធានអង្គភាពបានមកហៅខ្ញុំទៅប្រជុំនៅមន្ទីរពាណិជ្ជកម្ម តំបន់២៣។ ខ្ញុំខ្សឹបប្រាប់កូនច្បងខ្ញុំថា «បើបាត់ម៉ែយូរ អង្គការយកម៉ែទៅសម្លាប់ចោលហើយ គឺស្ថិតនៅខាងជើងផ្ទះយើងរស់នៅដែលមានដើមអង្គាញ់ច្រើន»។ បន្ទាប់មក ខ្ញុំបានពរកូនតូចទៅជាមួយ ព្រោះកូនខ្ញុំនៅបៅនៅឡើយ។ អ្នកដែលទៅចូលរួមប្រជុំនោះ ក៏មានមិត្តនារីម្នាក់ទៀតដែលមានកូនតូចនៅពរនឹងដៃ ហើយមានប្តីត្រូវអង្គការចោទថាក្បត់ដូចប្តីខ្ញុំដែរ។ នៅពេលបើកប្រជុំដំបូង ប្រធានអង្គប្រជុំមិនបានជានិយាយ ទាក់ទងនឹងប្តីខ្ញុំទេ ស្រាប់តែប្រជុំបានពាក់កណ្តាល ប្រធានអង្គប្រជុំឱ្យមិត្តនារីវ័យក្មេងម្នាក់ឡើងនិយាយថា «ទិសដៅសំខាន់របស់អង្គការហៅមកប្រជុំថ្ងៃនេះ គឺចង់ឱ្យមិត្តដែលមានពាក់ព័ន្ធនឹងគ្រួសារក្បត់ឡើងមានយោបល់»។ ការលើកឡើងនេះ គឺសំដៅមកខ្ញុំនិងមិត្តនារីម្នាក់ទៀត។ យុវនារីវ័យក្មេងម្នាក់នោះបន្តថា «មិនអីទេ ប្រសិនបើបងមានចិត្តស្មោះត្រង់នឹងអង្គការ ប៉ុន្តែបើបងចង់ទៅតាមគ្រួសារ អង្គការនឹងជូនទៅ។ ប្រសិនបើបងមិនចង់ទៅតាមគ្រួសារ ហើយនៅរួមរស់ជាមួយអង្គការ អង្គការនឹងចិញ្ចឹមឱ្យតែបងកុំលាក់លៀមចិត្តក្បត់ដូចប្តីរបស់បង»។ ខ្ញុំស្លេកស្លាំង និងភ័យញ័រទទ្រើកស្ទើរធ្លាក់កូនពីដៃ។ ខ្ញុំតាំងចិត្តនិងពង្រឹងស្មារតីហើយឆ្លើយថា «ខ្ញុំមិនតាមប្តីខ្ញុំដែលក្បត់ទេ ខ្ញុំសុខចិត្តនៅហូបបបរ»។ ភ្លាមៗនោះយុវនារីវ័យក្មេងនោះបានសួរបញ្ជាក់ខ្ញុំម្តងទៀតថា «ប្តីប្រពន្ធនរណាមិនស្រឡាញ់គ្នា ដូច្នេះសូមបងកុំលាក់លៀម ហើយបើបងទៅតាមប្តី អង្គការធានាជូនទៅ»។ ទោះបីសួរបញ្ជាក់ខ្ញុំយ៉ាងណាក៏ខ្ញុំនៅតែឆ្លើយដដែលថា «ខ្ញុំដើរតាមអង្គការ ខ្ញុំអត់ទៅតាមប្តីខ្ញុំទេ»។ ចំណែកមិត្តនារីម្នាក់ទៀតដែលមានប្តីត្រូវអង្គការចាប់ខ្លួនដែរ បានអង្គុយបីកូននៅក្នុងដៃ ហើយយំរហូតទន់ខ្លួន ហើយមួយសន្ទុះក្រោយមកក៏ឆ្លើយដូចខ្ញុំដែរ។ ពេលប្រជុំចប់ខ្ញុំក៏ត្រឡប់មកកន្លែងស្នាក់នៅវិញ។

នៅរដូវវិស្សាឆ្នាំ១៩៧៨ អង្គការបានជម្លៀសខ្ញុំពីមន្ទីរពាណិជ្ជកម្មតំបន់២៣ ក្នុងខេត្តស្វាយរៀង ទៅនៅសហករណ៍ក្នុងឃុំកំពង់ត្របែក ស្រុកកំពង់ត្របែក ខេត្តព្រៃវែង ចំពេលទឹកកំពុងឡើងលិចវាលស្រែ។ រហូតដល់ទឹកស្រក ទើបប្រធានសហករណ៍សរសេរសំបុត្រឱ្យខ្ញុំទៅនៅដកស្ទូងនិងធ្វើស្រែនៅសហករណ៍ក្នុងឃុំព្រៃឈរ ក្នុងស្រុកកំពង់ត្របែកវិញ ដោយឱ្យប្រធានរោងបាយចាំទទួល។ មួយរយៈក្រោយមក ទើបអង្គការបញ្ជូនខ្ញុំបន្តទៅនៅវត្តព្រែកតូច ស្ថិតនៅក្នុងភូមិព្រែករុនក្រោម ឃុំព្រែកគយ ស្រុកស្អាង ខេត្តកណ្តាល ដោយមានបងប្អូនរបស់ខ្ញុំចាំទទួលនៅទីនោះ។ ខ្ញុំរស់នៅឃុំព្រែកតូចរហូតដល់ឆ្នាំ១៩៧៩ ទើបត្រឡប់មករស់នៅភូមិកំណើតវិញ។

# ការិយាល័យព័ត៌មានសាធារណៈ













«ការិយាល័យព័ត៌មានសាធារណៈ» របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានបើកបម្រើជូន សិស្ស និស្សិត អ្នកសិក្សាស្រាវជ្រាវ បុគ្គលិករាជការ និងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍អំពីការវិវឌ្ឍន៍របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬសាលាក្តីខ្មែរក្រហម។

មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងប្រមូលផ្តុំ និងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត។ ឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានប្រាំប្រភេទ។ ប្រភេទឯកសារទីមួយគឺឯកសារជាក្រដាសស្នឹកដែលមានចំនួនជិតមួយលានទំព័រ។ ប្រភេទឯកសារទីពីរ គឺជាបទសម្ភាសន៍ដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាចុះទៅធ្វើសម្ភាសន៍ជាមួយជនរងគ្រោះ និងអតីតកម្មាភិបាលខ្មែរក្រហម។ ប្រភេទឯកសារទីបីគឺជារូបថតទាក់ទងទៅនឹងសម័យខ្មែរក្រហម។ ប្រភេទឯកសារទីបួនគឺជាឯកសារទាក់ទងទៅនឹងការធ្វើផែនទីរណ្តៅសាកសព និងទីតាំងសម្លាប់របស់ខ្មែរក្រហម និងឯកសារទីប្រាំគឺជាខ្សែភាពយន្តឯកសារដែលបានផលិតឡើងក្នុងរបបខ្មែរក្រហម និងសម័យក្រោយមកទៀត។

តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចស្រាវជ្រាវឯកសារទាំងនេះបាន។ ឯកសារខ្លះទៀតរួមមាន៖ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាព កំណត់ហេតុរបស់បក្សទូរលេខឆ្លើយឆ្លងព័ត៌មានដែលបានមកពីការសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្លងនិទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍។

ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ ១១ ផ្លូវលេខ ២៥៦ សង្កាត់បឹងកេងកង...















ចំណងជើងក្របមុខ និងក្របក្រោយ ៖

*លោកស្រី អាលីស វៃរីមូ ឌីរីទូ អគ្គលេខាធិការរងអង្គការសហប្រជាជាតិ និងជាទីប្រឹក្សាពិសេស ទទួលបន្ទុកការទប់ស្កាត់អំពើប្រល័យពូជសាសន៍ និងលោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា ចុះហត្ថលេខាលើអនុស្សរណៈនៃកិច្ចសហការ រំលេចអំពីសារសំខាន់នៃកិច្ចសហប្រតិបត្តិការ ក្នុងការលើកកម្ពស់ការអនុវត្តកិច្ចខិតខំប្រឹងប្រែងនានាក្នុងការទប់ស្កាត់ និងការអប់រំពីអំពើប្រល័យពូជសាសន៍នៅក្នុងតំបន់អាស៊ីអាគ្នេយ៍, អាស៊ីខាងត្បូង និងទូទាំងសកលលោក នៅទីក្រុងគីហ្គាលី ប្រទេសរ៉្វាន់ដា ថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០២៤។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*




**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ**

*ផ្ទះលេខ១១ ផ្លូវ២៥៦ សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរសព្ទ ៖ (៨៥៥) ៧៨ ៦៩៨ ៣៣៣*

DC-Cam/PIR: #11 ◆ Street 256 ◆ Sangkat Chatomuk ◆ Khan Daun Penh ◆ Phnom Penh ◆ Cambodia 1110

Tel: (855) 23 211 875 ◆ dccam@online.com.kh ◆ www.dccam.org

A magazine of the Documentation Center of Cambodia: Searching for the Truth ◆ Issue 299, November 2024 ◆ Funded by USAID
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No. 375 P.M. PRA. KA, 30 October 2018.